ព្រះរាជាណាចក្រកម្ពុជា

KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ

NATION RELIGION KING

ធនាគារជាតិ នៃ កម្ពុជា

NATIONAL BANK OF CAMBODIA

# របាយការណ៍ប្រចាំឆ្នាំ២០១០

# និង

# ទិសដៅការងារឆ្នាំ២០១១

# អារម្ភកថា

ការប្រមើលទៅអនាគតចំពោះសេដ្ឋកិច្ចពិភពលោកមានភាពសុទិដ្ឋិនិយមជាបង្គួរ ។ យោងតាមទស្សនទានសេដ្ឋកិច្ចពិភពលោករបស់មូលនិធិរូបិយវត្ថុអន្តរជាតិ សេដ្ឋកិច្ចពិភពលោកកំពុងតែមានដំណើរងើបឡើងវិញហើយ ប៉ុន្តែកម្រិតនៃភាពងើបឡើងវិញនេះមានសន្ទុះខុសៗគ្នារវាងតំបន់នានា ដែលក្នុងនោះតំបន់អាស៊ីបាននាំមុខគេ ។ កំណើនសេដ្ឋកិច្ចជាសកលសម្រាប់ឆ្នាំ២០១០ ត្រូវបានប៉ាន់ស្មានថា ស្មើ ៤,៨% បន្ទាប់ពីមានការថយចុះ -០,៦% នៅឆ្នាំ២០០៩ ដែលគាំទ្រដោយនយោបាយរូបិយវត្ថុ និងសារពើពន្ធបន្ធូរបន្ថយ ដើម្បីផ្តល់សាច់ប្រាក់ងាយស្រួលចាំបាច់ចំពោះសេដ្ឋកិច្ច ។ កំណើនសេដ្ឋកិច្ចនៅសហរដ្ឋអាមេរិកត្រូវបានរំពឹងថានឹងមានខ្ពស់ជាងនៅតំបន់អឺរ៉ុប ។ កំណើននេះអាចនឹងកើនឡើងដល់ ២,៦% និង ២,៣% រៀងគ្នានៅឆ្នាំ២០១០ និង ២០១១ នៅពេលដែលសកម្មភាពសេដ្ឋកិច្ចនៃតំបន់អឺរ៉ុបអាចនឹងមានអត្រាកំណើន ១,៧% និង ១,៥% ក្នុងរយៈពេលដូចគ្នានេះ ។ សេដ្ឋកិច្ចប្រទេសជប៉ុនត្រូវបានរំពឹងថានឹងកើន ២,៨% នៅឆ្នាំ២០១០ ខណៈដែល ចិន និង ឥណ្ឌាត្រូវបានរំពឹងថានឹងមានអត្រាកំណើន ១០,៥% និង ៩,៧% នៅឆ្នាំនេះ ។ ទន្ទឹមនេះដែរ ធនាគារអភិវឌ្ឍន៍អាស៊ីបានប៉ាន់ស្មានកំណើនសេដ្ឋកិច្ចនៅអាស៊ាន១០ អាចនឹងឈានដល់ ៦,៧% នៅឆ្នាំ២០១០ និង ៥,២% នៅឆ្នាំ២០១១ ។ ទោះបីជាមានដំណើរការវិជ្ជមាន បែបនេះក៏ដោយ ហានិភ័យចំពោះភាពងើបឡើងវិញនៃសេដ្ឋកិច្ចសកលនៅមាននៅឡើយ ដែលពាក់ព័ន្ធនឹងកំណើនបំណុលសាធារណៈនៅក្នុងបណ្តាប្រទេសអភិវឌ្ឍន៍ ស្ថានភាពមិនល្អនៃទីផ្សារការងារ និងភាពងាយរងគ្រោះនៃស្ថិរភាពហិរញ្ញវត្ថុសកល ។ នៅក្នុងបរិការណ៍នេះ អនុសាសន៍នយោបាយដែលបានស្នើឡើង រួមមាន ការពង្រឹងវិស័យសារពើពន្ធ ការលើកកម្ពស់ការគ្រប់គ្រងលំហូរមូលធន ជ្រោមជ្រែងទីផ្សារការងារ ខណៈជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយតុល្យភាព និងការយកចិត្តទុកដាក់លើការកែលម្អ និងកំណែទម្រង់វិស័យហិរញ្ញវត្ថុ ។

នៅកម្ពុជា ការចាត់វិធានការទាន់ពេលវេលារបស់រាជរដ្ឋាភិបាលបានជួយកាត់បន្ថយផលប៉ះពាល់ពីស្ថានភាពអវិជ្ជមាននៃសេដ្ឋកិច្ចសកលលោក ហើយសេដ្ឋកិច្ចរបស់ប្រទេសត្រូវបានប៉ាន់ស្មានថានឹងកើនចំនួន ៥,៥% នៅឆ្នាំ២០១០ ដែលជាល្បឿនលឿនជាងការរំពឹងទុក ទន្ទឹមនឹងនោះការព្យាករណ៍កំណើនសម្រាប់ឆ្នាំ២០១១ ត្រូវបានគ្រោង ៦% ។ លទ្ធផលនៅឆ្នាំ២០១០ បានឆ្លុះបញ្ចាំងផងដែរ នូវកំណែទម្រង់សេដ្ឋកិច្ច និងរចនាសម្ព័ន្ធសំខាន់ៗមួយចំនួន ដែលរាជរដ្ឋាភិបាលបានអនុវត្តនៅប៉ុន្មានឆ្នាំថ្មីៗនេះ ដើម្បីបំពេញឲ្យនយោបាយគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចរបស់ខ្លួន ។ ការងើបឡើងវិញនៃកំណើនសេដ្ឋកិច្ចក្នុងអំឡុងឆ្នាំនេះត្រូវបានជំរុញជាបឋមដោយសន្ទុះឡើងវិញនៃផលិតកម្មកម្មន្តសាលនិងសកម្មភាពទេសចរណ៍ ខណៈដែលវិស័យអចលនទ្រព្យមានភាពប្រសើរឡើងវិញសន្សឹមៗ ។ សូចនាករម៉ាក្រូសេដ្ឋកិច្ចផ្សេងៗទៀត ក៏មានភាពលើកទឹកចិត្ត ។ អត្រាអតិផរណាបានធ្លាក់ចុះដល់ប្រមាណ ៥,៣% នៅខែធ្នូ ឆ្នាំ២០០៩ និងបន្តដល់ ៣,១% នៅឆ្នាំ២០១០ ពី ១២,៥% នៅដំណាច់ឆ្នាំ២០០៨ ដោយសារមូលហេតុមួយចំនួន ដូចជា ការធ្លាក់ចុះនៃថ្លៃប្រេងឥន្ធនៈនិងស្បៀងអាហារជាសកល ល្បឿនយឺតនៃកម្ចីក្នុងស្រុក និងនយោបាយប្រុងប្រយ័ត្នមួយចំនួន ។ ចំពោះអតិផរណាសម្រាប់ឆ្នាំ២០១១ ត្រូវបានប៉ាន់ស្មានថាស្ថិតនៅក្រោម ៥% ។ ព្រមជាមួយនេះដែរ ប្រាក់រៀលបានឡើងថ្លៃជាបង្គួរក្នុងអត្រាឆ្នាំលើឆ្នាំប្រមាណ ៣,២% ។ ការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ដោយធនាគារជាតិនៃកម្ពុជា គឺជាកត្តាចម្បងនៃការវិវត្តក្នុងកម្រិតសន្សឹមៗនៃអត្រាប្តូរប្រាក់រៀល ។ អត្រាកំណើន

ការនាំចេញនៃវិស័យកាត់ដេរត្រូវបានប៉ាន់ស្មានថាស្មើ ១៥,២% នៅឆ្នាំ២០១០ គួបផ្សំនឹងកំណើនការនាំចូលចំនួនប្រមាណ ៩,៨% ចូលរួមជំរុញឲ្យឱនភាពគណនីចរន្តនៃជញ្ជីងទូទាត់កើនឡើងប្រមាណ ២,៩% ។ ឱនភាពជាប្រចាំនេះ គឺជាសញ្ញានៃការពឹងអាស្រ័យយ៉ាងច្រើន របស់សេដ្ឋកិច្ចកម្ពុជាលើការនាំចូល រួមជាមួយនឹងវិស័យនាំចេញដែលពុំសូវមានពិពិធកម្ម ។ ឱនភាពនេះ ត្រូវបានទូទាត់ជាមួយលំហូរចូលដើមទុនដែលនាំឲ្យមានអតិរេកជញ្ជីងទូទាត់ក្នុងទំហំគួរកត់សម្គាល់ ។ ត្រឹមដំណាច់ឆ្នាំនេះ ទុនបម្រុងអន្តរជាតិសុទ្ធបានកើនឡើងចំនួន ១២,៧% គឺច្រើនជាងកម្រិតឆ្នាំមុន និងគ្រប់គ្រាន់សម្រាប់ធានាការនាំចូលប្រមាណ ៤ខែ ។ ជានិច្ចកាល ទុនបម្រុងអន្តរជាតិរបស់ប្រទេសត្រូវបានរក្សានិងគ្រប់គ្រងយ៉ាងប្រុងប្រយ័ត្ន ហើយសុវត្ថិភាពក៏ត្រូវបានធានា ។

ចំពោះវិស័យធនាគារ ដោយសារការពង្រឹងប្រព័ន្ធត្រួតពិនិត្យ បញ្ញត្តិកម្ម និងសមាហរណកម្មដ៏មានកម្រិតនៅក្នុងទីផ្សារហិរញ្ញវត្ថុសកល កម្ពុជាទទួលរងឥទ្ធិពលដោយប្រយោលតិចតួចប៉ុណ្ណោះពីវិបត្តិហិរញ្ញវត្ថុសកល ។ ទន្ទឹមនោះ ធនាគារជាតិបានខិតខំជាបន្តដើម្បីធានាថាវិស័យធនាគារមានភាពត្រឹមត្រូវ រឹងមាំ និងមិនមានទាក់ទងនឹងប្រតិបត្តិការមិនសមស្រប រួមទាំងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានចំពោះភេរវកម្ម ។

ចំពោះកត្តារូបិយវត្ថុវិញ វិស័យធនាគារបន្តបង្ហាញនូវកំណើនជាប្រចាំនៅក្នុងផ្នែកសំខាន់ៗនៃតារាងតុល្យការរបស់ខ្លួន ។ ប្រាក់បញ្ញើរបស់អតិថិជន ឥណទានរបស់ធនាគារ និងទ្រព្យសកម្មសរុប ក្នុងអំឡុងឆ្នាំ ២០១០ នេះ កើនឡើងចំនួន ២៣,៩% ២៦,៦% និង ២៣,៦% រៀងគ្នា ធៀបនឹងឆ្នាំកន្លងទៅ ។ ការកើនឡើងនៃឥណទានអាចជាបឋម បណ្តាលពីកំណើនសកម្មភាពសេដ្ឋកិច្ចនៅក្នុងប្រទេស ។ លើសពីនេះទៀត ដើមទុនសរុបរបស់គ្រឹះស្ថានបានកើនឡើងចំនួន ២៤,៥% ហើយភាគច្រើននៃធនាគារមានដើមទុនលើសពីកម្រិតអប្បបរមាដែលតម្រូវ ។ ធនាគារទាំងនោះក៏មានប្រតិបត្តិការនៅក្នុងបរិស្ថាននៃកម្រិតសាច់ប្រាក់ងាយស្រួលគ្រប់គ្រាន់ និងកម្រិតឥណទានមិនដំណើរការទាប ។ អនុបាតរូបិយវត្ថុទូទៅ (M2) ធៀបនឹងផលិតផលក្នុងស្រុកសរុបបានកើនពី ៣២,៤% នៅឆ្នាំ២០០៩ ទៅ ៣៨,៣% នៅខែធ្នូ ឆ្នាំ២០១០ ។

ធនាគារជាតិនៃកម្ពុជាបន្តការព្យាយាមរបស់ខ្លួនក្នុងការអភិវឌ្ឍប្រព័ន្ធត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលកំពុងមានស្រាប់ ឲ្យទៅជាប្រព័ន្ធត្រួតពិនិត្យមួយដ៏មានប្រសិទ្ធភាព ។ ដើម្បីសម្រេចគោលដៅនេះ របៀបវារៈកែលម្អក្របខ័ណ្ឌត្រួតពិនិត្យ បានបន្តផ្តោតលើការធ្វើទំនើបកម្មប្រព័ន្ធត្រួតពិនិត្យលើឯកសារ និង CAMELS ខណៈដែលសមត្ថភាពត្រួតពិនិត្យដល់ទីកន្លែងត្រូវបានកសាងបន្ថែមទៀតជាប្រចាំ ដើម្បី អនុវត្តប្រកបដោយប្រសិទ្ធភាពនូវវិធីសាស្ត្រត្រួតពិនិត្យផ្អែកលើហានិភ័យ និងការត្រួតពិនិត្យផ្អែកលើទស្សនៈអនាគត ។ ជាងនេះទៅទៀត ដើម្បីសម្រេចបាននូវស្តង់ដារអន្តរជាតិ និងការអនុវត្តល្អប្រសើរក្នុងវិស័យធនាគារ បទបញ្ញាប្រុងប្រយ័ត្នផ្សេងៗត្រូវបានពង្រឹង រួមមាន បទបញ្ញាទាក់ទងនឹងដើមទុនផ្ទាល់សុទ្ធ ការត្រួតពិនិត្យផ្ទៃក្នុង និងវិធីសាស្ត្រត្រួតពិនិត្យផ្អែកលើហានិភ័យ ។

ក្រោមកិច្ចខិតខំប្រឹងប្រែងដែលកំពុងតែបន្តដើម្បីជំរុញទីផ្សាររូបិយវត្ថុ និងកម្ចីអន្តរធនាគារ ក៏ដូចជាដើម្បីគាំទ្រដល់ការគ្រប់គ្រងសាច់ប្រាក់ងាយស្រួលរបស់ធនាគារ បន្ទាប់ពីបានបង្កើតនូវ Repo Master Agreement ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវមូលដ្ឋានច្បាប់ដែលអនុញ្ញាតឲ្យធនាគារអាចប្រើប្រាស់មូលប័ត្ររបស់ធនាគារជាតិជាវត្ថុបញ្ចាំសម្រាប់ប្រតិបត្តិការអន្តរធនាគារក្នុងទីផ្សាររូបិយវត្ថុ ។ បច្ចុប្បន្ន

ធនាគារជាតិនៃកម្ពុជាកំពុងសិក្សាអំពីល័ក្ខខ័ណ្ឌនៃការចេញផ្សាយនេះ ។ នៅពេលត្រូវបានបង្កើតឡើង មូលប័ត្រប្រភេទនេះនឹងផ្តល់ជាឧបករណ៍បន្ថែមទៀត ដើម្បីគាំទ្រការអនុវត្តគោលនយោបាយរូបិយវត្ថុ និងអត្រាប្តូរប្រាក់របស់ធនាគារកណ្តាល ។

ការងារពាក់ព័ន្ធនឹងគម្រោងប្រព័ន្ធទូទាត់ជាតិសម្រាប់ជំរុញប្រព័ន្ធទូទាត់សងប្រាក់ក្នុងស្រុក និងអន្តរជាតិប្រកបដោយគុណភាព និងប្រសិទ្ធភាព បានដំណើរការគួរជាទីពេញចិត្ត ។ ប្រព័ន្ធផាត់ទាត់មូលប្បទានប័ត្រត្រូវបានធ្វើទំនើបកម្ម និងពង្រីកទៅកាន់បណ្តាខេត្តធំៗមួយចំនួន ។ ប្រព័ន្ធទូទាត់សងប្រាក់ក្នុងរូបភាពប្រើប្រាស់បញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទានកំពុងត្រូវបានអភិវឌ្ឍ និងអាចដាក់ឲ្យដំណើរការនៅពាក់កណ្តាលឆ្នាំ២០១១ ។ ការប្រកួតប្រជែងក្នុងវិស័យធនាគារ បានធ្វើឲ្យដំណើរការនៃសេវាទូទាត់កាន់តែប្រសើរឡើង ។ សេវាជាច្រើន ដូចជា ការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក និងការទូទាត់ថ្លៃប្រើប្រាស់ទឹក-ភ្លើង បានទទួលអត្ថប្រយោជន៍ពីការមានអតិថិជនដ៏ច្រើនប្រើប្រាស់សេវាទូរស័ព្ទចល័ត ។ ការផ្តល់លទ្ធភាពឲ្យធនាគារប្រើប្រាស់អ្នកដំណើរការតតិយភាគីបាននាំឲ្យមានការពង្រីកសេវាទូទាត់ដល់ប្រជាជននៅតំបន់ជនបទ ដែលមិនមានគណនីនៅធនាគារ និងពុំមានសេវាធនាគារប្រើប្រាស់ ។ ការនេះនឹងបន្ថែមទៅលើកំណើនសេវាមីក្រូហិរញ្ញវត្ថុ ហើយរួមចំណែកជាវិជ្ជមានចំពោះការផ្តល់សេវាធនាគារទៅកាន់តំបន់ជនបទដាច់ស្រយាល ។

ចំពោះការគ្រប់គ្រងទីផ្សារប្តូរប្រាក់វិញ កិច្ចខិតខំជាច្រើនត្រូវបានធ្វើឡើងដើម្បីអនុវត្តបទបញ្ជាសម្រាប់អាជីវករប្តូរប្រាក់ដែលតម្រូវឲ្យពួកគេមានអាជ្ញាប័ណ្ណប្រកបអាជីវកម្មត្រឹមត្រូវ មានកាតព្វកិច្ចផ្តល់របាយការណ៍ និងគោរពទៅតាមក្រមប្រតិបត្តិ ។ ការខិតខំនេះមានបំណងជំរុញតម្លាភាព និងវិជ្ជាជីវៈក្នុងទីផ្សារប្តូរប្រាក់ ក៏ដូចជាដើម្បីជួយដល់ធនាគារកណ្តាលក្នុងការរៀបចំនិងដឹកនាំគោលនយោបាយរូបិយវត្ថុ និងអត្រាប្តូរប្រាក់ឲ្យមានប្រសិទ្ធភាព ។

នាពេលថ្មីៗនេះ ដោយមានការចូលរួមពីសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ធនាគារជាតិនៃកម្ពុជាបានផ្តើមការងារជាដៃគូជាមួយសមាគមធនាគារិក និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ដើម្បីបង្កើតនូវការិយាល័យឥណទាន ។ គម្រោងថ្មីនេះនឹងជំនួសឲ្យប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដែលបានដាក់ឲ្យដំណើរការក្នុងការសាកល្បងក្នុងរយៈពេលប្រមាណបីឆ្នាំកន្លងមកនេះ ហើយរំពឹងថានឹងជួយបង្កើនគុណភាពការផ្តល់ និងការគ្រប់គ្រងឥណទាន ព្រមទាំងជំរុញទំនុកចិត្តលើប្រព័ន្ធធនាគារបន្ថែមទៀត ។

ពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុជនបទ សកម្មភាពមីក្រូហិរញ្ញវត្ថុកំពុងមានការរីកចម្រើនយ៉ាងខ្លាំង និងបានបង្កើនការផ្តល់សេវាហិរញ្ញវត្ថុច្រើនឡើងចំពោះតំបន់ជនបទ ។ ក្នុងគោលដៅបង្កើនប្រភពហិរញ្ញប្បទានសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានបង្កើនចំនួនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលអាចទទួលប្រាក់បញ្ញើបាន និងលើកទឹកចិត្តគ្រឹះស្ថានធនាគារឲ្យផ្តល់កម្ចីជារូបិយវត្ថុក្នុងស្រុកទៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ ក្នុងគោលបំណងប្រារព្ធកិច្ចប្រជុំកំពូលថ្នាក់ជាតិអំពីមីក្រូហិរញ្ញវត្ថុនៅឆ្នាំ២០១១ ការត្រៀមរៀបចំផ្សេងៗកំពុងត្រូវបានធ្វើឡើងនាដំណាច់ឆ្នាំ២០១០ នេះ ។ គោលបំណងសំខាន់នៃសន្និសីទនេះ គឺដើម្បីចែករំលែកព័ត៌មាន បទពិសោធន៍ និងជោគជ័យក្នុងការជំរុញវិស័យមីក្រូហិរញ្ញវត្ថុជាមួយដៃគូជាតិនិងអន្តរជាតិ ដែលជាវិស័យទទួលការកោតសរសើរចំពោះការអភិវឌ្ឍដោយជោគជ័យនិងចំទិសដៅ ។

ការអភិវឌ្ឍសំខាន់ផ្សេងទៀតនៅក្នុងឆ្នាំ២០១០ ត្រូវបានផ្តួចផ្តើមឡើងដោយធនាគារជាតិនៃកម្ពុជា

ដើម្បីធ្វើបច្ចុប្បន្នកម្ម "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥" ទៅជា "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០" ។ ក្នុងតួនាទីជាភ្នាក់ងារសម្របសម្រួល និងប្រតិបត្តិនៃកម្មវិធីអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ដែលត្រូវបានគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ធនាគាជាតិនៃកម្ពុជាបានចាប់ផ្តើមការងារសំខាន់ៗជាមួយនឹងភាគីទាំងឡាយ ដើម្បីអនុវត្តកម្មវិធីកំណែទម្រង់វិស័យហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និងស្របតាមស្ថានភាពសេដ្ឋកិច្ចដែលកំពុងវិវត្ត ដែលនឹងជួយឲ្យវិស័យហិរញ្ញវត្ថុនិងធនាគារមានការអភិវឌ្ឍ និងកាន់តែទំនើបថែមមួយកម្រិតទៀត ។

លើសពីនេះទៀត ធនាគារជាតិនៃកម្ពុជាបានបន្តសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នពាក់ព័ន្ធក្នុងគោលដៅជំរុញកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឲ្យកាន់តែប្រសើរឡើង ។ ក្នុងបរិការណ៍នេះ ធនាគារជាតិនៃកម្ពុជាគាំទ្រពេញទំហឹងដល់ការពង្រឹងប្រព័ន្ធគណនីទោល និងការប្រើប្រាស់ប្រព័ន្ធធនាគារសម្រាប់មូលហេតុនេះ ។ ក្នុងក្របខ័ណ្ឌនេះដែរ ធនាគារជាតិនៃកម្ពុជាបានផ្តល់ការសម្រួលគ្រប់បែបយ៉ាងដល់ការបើក និងការគ្រប់គ្រងគណនីសម្រាប់ស្ថាប័ន និងភ្នាក់ងារសាធារណៈនានា ។

ជាកិច្ចរំលឹកដល់ខួបទី ៣០ នៃការបោះផ្សាយឡើងវិញនូវរូបិយវត្ថុជាតិ ក្នុងគោលបំណងផ្សព្វផ្សាយជាសាធារណៈ អំពីប្រវត្តិរូបិយវត្ថុនៅក្នុងប្រទេសកម្ពុជា និងដើម្បីជំរុញការប្រើប្រាស់ប្រាក់រៀល ធនាគារជាតិនៃកម្ពុជាបានបោះពុម្ពផ្សាយសៀវភៅដែលមានចំណងជើងថា "រូបិយវត្ថុ និងអធិបតេយ្យភាព" ។

ជារួម ជាមួយនឹងការខិតខំប្រកបដោយការប្តេជ្ញាចិត្តរបស់មន្ត្រីបុគ្គលិកគ្រប់ជាន់ថ្នាក់ និងការគាំទ្រប្រកបដោយប្រសិទ្ធភាពរបស់ក្រុមប្រឹក្សាភិបាលនៃធនាគារជាតិនៃកម្ពុជា រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ទាំងឡាយ លទ្ធផលនៃប្រតិបត្តិការឆ្នាំ២០១០ នេះ បានសម្រេចផលល្អប្រសើរ ។ ខ្ញុំសូមសម្តែងការអរគុណដ៏ជ្រាលជ្រៅដល់គ្រប់ស្ថាប័នពាក់ព័ន្ធដែលបានចូលរួមវិភាគទានដ៏មានតម្លៃ ក្នុងការសម្រេចបាននូវជោគជ័យទាំងអស់នេះ ។

ទោះជាយ៉ាងណាក៏ដោយ នៅមានការងារជាច្រើនទៀតដែលត្រូវធ្វើក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ពោលគឺ ត្រូវដោះស្រាយបញ្ហាជាច្រើនទៀតដើម្បីបង្កើតអន្តរការីយកម្មរឹងមាំ សកម្ម និងមានប្រសិទ្ធភាពនៅក្នុងប្រទេស ដែលខ្លួនខ្ញុំផ្ទាល់តាំងចិត្តប្តេជ្ញាអនុវត្តក្នុងគោលដៅនេះ ។ វិស័យធនាគារបានបម្រើដល់ប្រទេសយើងយ៉ាងល្អប្រសើរក្នុងអំឡុងប៉ុន្មានឆ្នាំកន្លងមកនេះ ។ ខ្ញុំមានជំនឿយ៉ាងមុតមាំថា ផ្អែកលើកិច្ចសហការដ៏ជិតស្និទ្ធ យើងនឹងអាចទទួលបានជ័យជំនះថែមទៀតនាពេលអនាគត តាមរយៈការដោះស្រាយរួមគ្នានូវបញ្ហាដែលជាផលប្រយោជន៍រួមនេះ ។

**ទេសាភិបាល**

# មាតិកា

* * *

ក- របាយការណ៍ប្រចាំ ឆ្នាំ២០១០ ១

សេចក្តីផ្តើម ២

I- ការអនុវត្តគោលនយោបាយរូបិយវត្ថុ និងប្រតិបត្តិការធនាគារជាតិនៃកម្ពុជា ៣

១- ស្ថានភាពថ្លៃ និងតម្លៃប្រាក់រៀល ៣

១.១- ការវិវត្តថ្លៃទំនិញ និងអតិផរណា ៣

១.២- ស្ថានភាពអត្រាប្តូរប្រាក់ ៦

១.២.១- ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក ៦

១.២.២- ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងរូបិយប័ណ្ណផ្សេងៗមួយចំនួន ៧

១.២.៣- ស្ថានភាពអត្រាប្តូរប្រាក់ដុល្លារធៀបនឹងរូបិយប័ណ្ណសំខាន់ៗមួយចំនួន ៨

២- ការវិវត្តរូបិយវត្ថុ ៩

២.១- ការផ្គត់ផ្គង់រូបិយវត្ថុ ១០

២.២- កត្តាជះឥទ្ធិពលដល់បរិមាណរូបិយវត្ថុ ១១

២.២.១- ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា ១២

២.២.២- ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារពាណិជ្ជ ១២

២.៣- អត្រាការប្រាក់លើប្រាក់កម្ចី និងប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ ១៣

៣- ជញ្ជីងទូទាត់ ១៤

៣.១- គណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្លូវការ) ១៤

៣.២- គណនីបង្វែរផ្លូវការ និងហិរញ្ញវត្ថុ ១៦

៤- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ ១៧

៤.១- ការងារវិនិយោគទុនបម្រុងអន្តរជាតិ ១៧

៤.២- អន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់ ១៨

៤.៣- ការគ្រប់គ្រងអាជីវកម្មមាស និងប្តូរប្រាក់ ១៨

៥- សម្ព័ន្ធការជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ១៩

៥.១- ការត្រួតពិនិត្យធនាគារពាណិជ្ជ និងធនាគារឯកទេស ១៩

៥.២- ការត្រួតពិនិត្យលើឯកសារ ១៩

៥.៣- ការត្រួតពិនិត្យដល់ទីកន្លែង ១០

៥.៤- ការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ២០

៥.៥- ការរៀបចំបទប្បញ្ញត្តិ ២២

៥.៦- អាជ្ញាប័ណ្ណ និងការចុះបញ្ជី ២២

៦- ការផ្តល់ផ្គត់ផ្គង់សេវាធនាគារកណ្តាល ២២

៦.១- សេវាផ្នែកគណនី ២២

៦.១.១- សេវាផ្នែកគណនីចំពោះស្ថាប័នរដ្ឋ ២២

៦.១.២- សេវាផ្នែកគណនីចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ២៣

៦.១.៣- សេវាផ្ទេរប្រាក់ក្នុងប្រទេស ២៣

៦.២- សេវាផាត់ទាត់ ២៣

៦.២.១- ការផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល ២៣

៦.២.២-ការផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់ដុល្លារ ២៣

៦.៣- ការងារឥណទានចំពោះរាជរដ្ឋាភិបាល ២៤

៦.៤- ការងារអនុវត្តហិរញ្ញប្បទាន និងកម្ចីរាជរដ្ឋាភិបាល ២៤
៧- ការគ្រប់គ្រងចរាចរណ៍ធនប័ត្រ ២៥
៨- ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ និងការបំពាក់ប្រព័ន្ធធនាគារស្នូលរបស់
ធនាគារជាតិនៃកម្ពុជា ២៦
II- ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា ២៧
១- សកម្មភាពក្រុមប្រឹក្សាភិបាល ២៧
២- ការអភិវឌ្ឍធនធានមនុស្ស ២៨
២.១- ស្ថិតិមន្ត្រីបុគ្គលិក ២៨
២.២- ការងារបណ្តុះបណ្តាល ២៨
៣- ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ៣០
៤- ការងារគ្រប់គ្រងសាខាធនាគារជាតិនៃកម្ពុជា ៣១
III- ទំនាក់ទំនងអន្តរជាតិ ៣១
១- ទំនាក់ទំនងពហុភាគី ៣១
១.១- ទំនាក់ទំនងជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ ៣១
១.២- ទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ៣២
១.៣- ទំនាក់ទំនងជាមួយអាស៊ាន ៣៣
១.៣.១- សហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន ៣២
១.៣.២- សហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន+៣ ៣៣
១.៤- ទំនាក់ទំនងជាមួយមជ្ឈមណ្ឌលធនាគារកណ្តាលអាស៊ីអាគ្នេយ៍
( ស៊ាសិន - SEACEN ) ៣៤

១.៥- ទំនាក់ទំនងជាមួយសមាគមធនាគារកណ្ដាលនៃបណ្ដាប្រទេសនិយាយ
ភាសាបារាំង (Francophone: ហ្វ្រង់កូហ្វូន) ៣៥
២- ទំនាក់ទំនងទ្វេភាគី ៣៥
សន្និដ្ឋាន ៣៧
ខ- ទិសដៅការងារ ឆ្នាំ២០១១ ៤០
១- ការងាររូបិយវត្ថុ ៤១
២- ការងារប្តូរប្រាក់ និងគ្រប់គ្រងទុនបម្រុង ៤១
៣- ការងារអភិវឌ្ឍប្រព័ន្ធទូទាត់ និងប្រព័ន្ធធនាគារស្នូល ៤១
៤- ការងារត្រួតពិនិត្យ ៤១
៥- ការងារគណនេយ្យ ៤១
៦- ការងារប្រតិបត្តិការ ៤២
៧- ការងារបោះផ្សាយ និងឃ្លាំងបេឡា ៤២
៨- ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ៤២
៩- ការងារបណ្តុះបណ្តាល ៤២
ឧបសម្ព័ន្ធ ៤៣
ឧបសម្ព័ន្ធ ១ ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញ និងសេវា ៤៤
ឧបសម្ព័ន្ធ ២ ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញ និងសេវា (ធ្នូ២០០៦ - ធ្នូ២០១០) ៤៥
ឧបសម្ព័ន្ធ ៣ ប្រាក់រៀលធៀបជាមួយរូបិយប័ណ្ណផ្សេងៗ ៤៦
ឧបសម្ព័ន្ធ ៤ ស្ថានភាពរូបិយវត្ថុ (គិតជាពាន់លានរៀល) ៤៧
ឧបសម្ព័ន្ធ ៥ ស្ថានភាពរូបិយវត្ថុ (បម្រែបម្រួលប្រចាំឆ្នាំជាភាគរយ) ៤៨
ឧបសម្ព័ន្ធ ៦តារាងគណនីវិភាគធនាគារជាតិនៃកម្ពុជា ៤៩

ឧបសម្ព័ន្ធ ៧ តារាងគណនីវិភាគធនាគារពាណិជ្ជ ៥០

ឧបសម្ព័ន្ធ ៨ ឥណទានតាមប្រភេទជំនួញក្នុងវិស័យសេដ្ឋកិច្ច និងសរុបប្រតិបត្តិការប្រាក់បញ្ញើធនាគារពាណិជ្ជ ៥១

ឧបសម្ព័ន្ធ ៩ ជញ្ជីងទូទាត់ប្រទេសកម្ពុជា ឆ្នាំ២០០៧ ដល់ ឆ្នាំ២០១០ ៥២

# ក- របាយការណ៍ប្រចាំឆ្នាំ២០១០

## សេចក្ដីផ្ដើម

សន្ទុះភាពនៃការងើបឡើងវិញនៃសេដ្ឋកិច្ចសកលបានកើនឡើងចាប់តាំងពីដើមឆ្នាំ២០១០ ជាពិសេសក្នុងចំណោមប្រទេសនៃសេដ្ឋកិច្ចកំពុងងើបឡើង ។ ចំពោះប្រទេសកម្ពុជាក៏មានសញ្ញាថាការថមថយចុះនៃសកម្មភាពសេដ្ឋកិច្ចត្រូវបានបញ្ចប់ដែរ ។ ទស្សនវិស័យប្រសើរចំពោះកំណើនសេដ្ឋកិច្ចនៅឆ្នាំ២០១០ បានវិលត្រឡប់មកវិញ ខណៈដែលសេដ្ឋកិច្ចមានការរីកចម្រើនជាច្រើនវិស័យ ជាពិសេស ការកើនឡើងការនាំចេញផលិតផលកាត់ដេរ និងវិស័យទេសចរណ៍ ។ បន្ទាប់ពីមានកំណើនដ៏តិចតួចត្រឹមកម្រិត 0,១% ក្នុងឆ្នាំ២០០៩ ផលិតផលក្នុងស្រុកសរុបពិត ត្រូវបានប៉ាន់ស្មានថានឹងកើនដល់ ៥,៥% នាឆ្នាំនេះ ។ បន្សំរវាងស្ថិរភាពអត្រាប្ដូរប្រាក់ និងកម្រិតអតិផរណាទាបកំពុងបន្តជំរុញដល់ការពង្រីកសកម្មភាពអាជីវកម្មឯកជន ។

វិធានការនយោបាយឆ្លើយតបសមស្របរបស់រាជរដ្ឋាភិបាលចំពោះវិបត្តិសកល គឺជាឫសគល់ចម្បង និងដ៏សំខាន់នៃការប្រែត្រឡប់នៃសេដ្ឋកិច្ចកម្ពុជាដោយជោគជ័យ ។ សេចក្ដីសម្រេចចិត្ត និងការចាត់វិធានការទាន់ពេលវេលារបស់រាជរដ្ឋាភិបាល បានបញ្ចៀសផលប៉ះពាល់ខាងក្រៅធ្ងន់ធ្ងរចំពោះសេដ្ឋកិច្ចក្នុងស្រុក ។ ជាមួយគ្នានេះដែរ នយោបាយរូបិយវត្ថុនៅតែរក្សាភាពប្រុងប្រយ័ត្នចំពោះសម្ពាធអតិផរណា ។ កិច្ចប្រឹងប្រែងនៅតែមានជាបន្តដើម្បីគ្រប់គ្រង និងជៀសវាងកំណើនលើសនៃរូបិយវត្ថុក្នុងចរាចរណ៍ និងរក្សាស្ថិរភាពអត្រាប្ដូរប្រាក់ ។ បន្ទាប់ពីបានថយចុះគួរឲ្យកត់សម្គាល់ក្នុងឆ្នាំ២០០៩ អតិផរណារួមបានកើនឡើងខ្លះវិញក្នុងឆ្នាំ២០១០ ដោយមូលហេតុកំណើនថ្លៃម្ហូបអាហារ និងប្រេងឥន្ធនៈ ។ ខណៈនេះដែរ អតិផរណាស្នូលមិនរាប់បញ្ចូលថ្លៃម្ហូបអាហារ និងប្រេងឥន្ធនៈមានស្ថិរភាពយ៉ាងល្អប្រសើរ ។

ដំណើរការអភិវឌ្ឍវិស័យហិរញ្ញវត្ថុបានប្រព្រឹត្តទៅគួរជាទីពេញចិត្ត ទោះបីជាចេញពីមូលដ្ឋានទាបក៏ដោយ ។ ភាពស៊ីជម្រៅនៃវិស័យហិរញ្ញវត្ថុត្រូវបានពង្រឹង ដែលឆ្លុះបញ្ចាំងពីស្ថិរភាពហិរញ្ញវត្ថុ និងការជំរុញសេវាហិរញ្ញវត្ថុតាមរយៈកំណែទម្រង់ស្ថាប័ន និងក្របខ័ណ្ឌច្បាប់នៅក្រោមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញ-វត្ថុរយៈកាលវែង ។ វិស័យហិរញ្ញវត្ថុបច្ចុប្បន្នកំពុងដើរតួនាទីសំខាន់ឡើងៗក្នុងការធ្វើអន្តរការីយកម្មសញ្ច័យ ការបង្កើនល្បឿនវិនិយោគ និងការផ្ដល់សេវាធនាគារច្រើនប្រភេទដល់វិស័យឯកជន ។ បន្ទាប់ពីរងការថមថយមួយរយៈ តម្រូវការឥណទានរបស់វិស័យឯកជន បានវិលត្រឡប់មករកសភាពប្រក្រតីវិញ ។ លទ្ធភាពប្រើសេវាហិរញ្ញវត្ថុក៏បានកើនឡើងជាមួយនឹងការរីកចម្រើនតួនាទីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា ។ លើសពីនេះទៀត ហានិភ័យក្នុងវិស័យធនាគារត្រូវបានកាត់បន្ថយ ខណៈដែលគ្រឹះស្ថានធនាគារត្រូវបានតម្រូវឲ្យបង្កើនមូលដ្ឋានដើមទុន ។ យោងតាមអនុសាសន៍នៃការវាយតម្លៃវិស័យហិរញ្ញវត្ថុរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (FSAP) ការខិតខំផ្សេងៗកំពុងប្រព្រឹត្តទៅដើម្បីអនុវត្តរបៀបវារៈកំណែទម្រង់ ។ ច្បាប់សម្រាប់វិស័យធនាគារក៏កំពុងស្ថិតក្នុងការពិនិត្យកែលម្អ ដែលនឹងជួយដល់ការពង្រឹងក្របខ័ណ្ឌបទបញ្ញា ។ ដំណើរការនេះនឹងជួយពង្រឹងប្រព័ន្ធហិរញ្ញវត្ថុ ព្រមទាំងធានាឲ្យធនាគារអាចដើរតួនាទីដ៏សំខាន់របស់ខ្លួនក្នុងការផ្ដល់ឥណទានចំពោះវិស័យឯកជន ។

ធនាគារជាតិនៃកម្ពុជាបានបន្តផ្ដោតការយកចិត្តទុកដាក់ជាសំខាន់ផងដែរ ទៅលើការអភិវឌ្ឍទំនាក់ទំនងជាមួយស្ថាប័នហិរញ្ញវត្ថុក្នុងតំបន់ និងអន្តរជាតិ ធនាគារកណ្ដាលនៃប្រទេសដទៃ និងមជ្ឈមណ្ឌលបណ្ដុះបណ្ដាលផ្សេងទៀត ។ ធនាគារជាតិនៃកម្ពុជាបានចូលរួមក្នុងគំនិតផ្ដួចផ្ដើមផ្សេងៗក្នុងតំបន់ និងទទួលបានអត្ថប្រយោជន៍ជាច្រើនពីជំនួយបច្ចេកទេសតាមរយៈទំនាក់ទំនងទាំងនេះ ។

# I- ការអនុវត្តគោលនយោបាយរូបិយវត្ថុ និងប្រតិបត្តិការធនាគារជាតិនៃកម្ពុជា

## ១- ស្ថានភាពថ្លៃ និងតម្លៃប្រាក់រៀល

### ១.១- ការវិវត្តថ្លៃទំនិញ និងអតិផរណា

អត្រាអតិផរណាប្រចាំឆ្នាំដែលបានធ្លាក់ចុះជាអវិជ្ជមានជាច្រើនខែនៅក្នុងឆ្នាំ២០០៩ ហើយមានកម្រិតទាបបំផុតស្មើនឹង -៥,៧% នៅខែឧសភា ឆ្នាំ២០០៩ នោះ បានបញ្ចប់នៅខែតុលា ក្នុងអត្រា -១,៦% និងបានចាប់ផ្តើមកើនឡើងសន្សឹមៗចាប់ពីខែវិច្ឆិកា ឆ្នាំ២០០៩ មក ដោយមានកម្រិតវិជ្ជមាន ១,៣% នៅ ខែវិច្ឆិកា និងបានកើនឡើងដល់ ៥,៣% នៅចុងឆ្នាំ២០០៩ ។

ពិនិត្យលើចលនាអតិផរណានៅក្នុងឆ្នាំ២០១០ ឃើញថា បម្រែបម្រួលឆ្នាំលើឆ្នាំនៃសន្ទស្សន៍ថ្លៃទំនិញ និងសេវា បានបន្តកើនជាបន្តបន្ទាប់ចាប់ពីដើមឆ្នាំគឺ ៦,៩% នៅខែមករា និងរហូតដល់ ៧,៣% នៅខែកុម្ភៈ ហើយបានថយចុះមកវិញបន្តិចម្តងៗដល់កម្រិតទាបបំផុតនៃឆ្នាំស្មើនឹង ១,៦% នៅក្នុងខែកក្កដា និងមានអត្រាស្មើនឹង ៣,១% នាដំណាច់ឆ្នាំ ។ ប៉ុន្តែទោះជាដូច្នេះក្តី អត្រាអតិផរណាឆ្នាំលើឆ្នាំ ក្នុងឆ្នាំ២០១០ នេះ មានស្ថិរភាពល្អជាង ឆ្នាំ២០០៩ និង២០០៨ ដោយរក្សាបាននៅក្នុងកម្រិតមួយខ្ទង់ និងប្រែប្រួលជាមធ្យមក្នុងកម្រិត ៤,១% ធៀបនឹងបម្រែបម្រួលជាមធ្យម -០,៤% នៅឆ្នាំ២០០៩ និង ២៥,១% នៅឆ្នាំ២០០៨ ។ ដោយឡែកអត្រាអតិផរណាប្រចាំឆ្នាំមធ្យមរំកិល ១២ខែ មានកម្រិត ៤% នៅដំណាច់ឆ្នាំ២០១០ ធៀបនឹង -០,៧% នៅគ្រាដូចគ្នា ឆ្នាំ២០០៩ និង ២៥% នៅឆ្នាំ២០០៨ ។

ក្រាហ្វស្ថិតិ ១ : **អតិផរណាឆ្នាំលើឆ្នាំ**




ក្នុងខណៈដែលការធ្លាក់ចុះនៃអត្រាអតិផរណានៅឆ្នាំ២០០៩ បណ្តាលជាបឋមពីឥទ្ធិពលនៃកម្រិតថ្លៃស្បៀងអាហារ និងប្រេងឥន្ធនៈខ្ពស់នាឆ្នាំមូលដ្ឋាន២០០៨ ការងើបឡើងវិញនៃអតិផរណានៅដើមឆ្នាំ២០១០ គឺជាលទ្ធផលនៃកំណើនជាថ្មីនៃថ្លៃម្ហូបអាហារ ទំនិញ សេវាក្នុងក្រុមដឹកជញ្ជូន ព្រមទាំងផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈ ។

គិតតាមបម្រែបម្រួលឆ្នាំលើឆ្នាំ នាឆ្នាំ២០១០ នេះ ក្នុងចំណោមថ្លៃទំនិញទាំង ១២ក្រុម មាន ១១ ក្រុមបានកើនឡើង និង ១ក្រុមបានថយចុះ ។ ក្រុមមុខទំនិញដែលបានឡើងថ្លៃរួមមាន ទំនិញនិងសេវាកម្មផ្សេងៗ ១០% ម្ហូបអាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង ៣,៦ % ការដឹកជញ្ជូន ៣,៤% ផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ននិងឥន្ធនៈដទៃទៀត ២,៩% សម្លៀកបំពាក់និងស្បែកជើង ២,៦% ភោជនីយដ្ឋាន ២,៤% គ្រឿងសង្ហារិម សម្ភារៈប្រើប្រាស់គ្រួសារនិងការថែទាំផ្ទះជាប្រចាំ ១,៥% ការសិក្សា ១% សុខាភិបាល ០,៧% គមនាគមន៍ ០,៥% និង ការសម្បាន្តនិងវប្បធម៌ ០,៥% ខណៈដែល ក្រុមភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ថយចុះ ០,៥% ។

ក្រាហ្វស្ថិតិ ២ : **ក្រុមមុខទំនិញដែលឡើងថ្លៃខ្លាំងជាងគេក្នុងឆ្នាំ២០១០** (ឆ្នាំលើឆ្នាំ)




ក្រុមធំទំនិញដែលបានកើនឡើងថ្លៃខ្លាំងជាងគេក្នុងឆ្នាំ២០១០នេះ គឺក្រុមធំទំនិញនិងសេវាកម្មផ្សេងៗ ម្ហូបអាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង និងការដឹកជញ្ជូន ខណៈដែលក្រុមធំភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់បានថយចុះ ។ ការកើនឡើងនៃក្រុមធំទំនិញ និងសេវាកម្មផ្សេងៗ គឺដោយសារការកើនឡើង នៃក្រុមរងសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួន ចំនួន ១៩,២% និងសេវាកម្មដទៃទៀតចំនួន ៣% ។ រីឯការកើនឡើង នៃក្រុមធំម្ហូបអាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង គឺដោយសារការកើនឡើងនៃថ្លៃ សាច់មាន់ស្រស់ ៤.៧% ត្រីស្រស់ ៥,៧% ត្រីកែច្នៃ ៦,៩% ផ្លែឈើស្រស់ ៨,១% បន្លែ ៥% និងផលិតផលម្ហូបអាហារ ១៨.៣% ។ ចំណែកឯការកើនឡើងនៃក្រុមធំការដឹកជញ្ជូន គឺដោយសារការកើនឡើងនៃក្រុមរងការប្រតិបត្តិ ឧបករណ៍ដឹកជញ្ជូន ១៣,២% និងថ្លៃសេវាកម្មដឹកជញ្ជូន ២,៩% ។ ជាមួយគ្នានេះដែរការថយចុះនៃក្រុមធំភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ គឺដោយសារការថយចុះនៃថ្លៃ ស្រា ៣,២% និងស្រាបៀរ ០,៤% ។

ក្រាហ្វស្ថិតិ ៣ : **ការរួមចំណែកក្នុងអតិផរណា** (ឆ្នាំលើឆ្នាំ)




កត្តាមួយចំនួនដែលបានរួមចំណែកក្នុងអតិផរណារួមប្រចាំឆ្នាំនាខែធ្នូ ឆ្នាំ២០១០ ដែលស្មើនឹង ៣,១% គឺ ក្រុមម្ហូបអាហារ និងភេសជ្ជៈពុំមានជាតិស្រវឹងមានចំណែក ១,៦% (ត្រូវនឹងសមាមាត្រ ៥២,៨% នៃអត្រាអតិផរណាប្រចាំឆ្នាំ) ក្រុមផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ននិងឥន្ធនៈដទៃទៀត ០,៥% (ត្រូវនឹងសមាមាត្រ ១៦,១% នៃអត្រាអតិផរណាប្រចាំឆ្នាំ) ក្រុមដឹកជញ្ជូន ០,៤% (ត្រូវនឹងសមាមាត្រ ១៣,៤% នៃអត្រាអតិផរណាប្រចាំឆ្នាំ) និង នៅសល់ក្រុមមុខទំនិញ ៨ ក្រុម ទៀតបានចូលរួមចំណែកតែ ០,៥% ប៉ុណ្ណោះ (ត្រូវនឹងសមាមាត្រ ១៧,៧% នៃអត្រាអតិផរណាប្រចាំឆ្នាំ) ។

ក្រាហ្វស្ថិតិ ៤ : **អតិផរណាមិនរាប់បញ្ចូលក្រុមទំនិញសំខាន់ៗ** (ឆ្នាំលើឆ្នាំ)



នាដំណាច់ឆ្នាំ២០១០ នេះ អត្រាអតិផរណាមិនរាប់បញ្ចូលក្រុមម្ហូបអាហារមានកម្រិត ២,៧% ពោលគឺបានធ្លាក់ចុះពីអត្រា ៥,៨% កាលពីឆ្នាំមុន ខណៈដែលអតិផរណាជាទូទៅស្មើនឹង ៣,១% ដែលបញ្ជាក់ឲ្យឃើញថា ការប្រែប្រួលថ្លៃម្ហូបអាហារមានឥទ្ធិពលខ្លាំងទៅលើអត្រាអតិផរណាជារួម ។

ក្នុងពេលជាមួយគ្នានេះដែរ សម្ពាធអតិផរណាមិនរាប់បញ្ចូលផលិតផលប្រេងឥន្ធនៈនិងសេវាកម្មស្មើនឹង ២,៣% នៅពេលដែលអតិផរណាមិនរាប់បញ្ចូលម្ហូបអាហារនិងប្រេងឥន្ធនៈមានកម្រិត ០,៦% នាដំណាច់ឆ្នាំ ។ កត្តានេះបានបញ្ជាក់ជាថ្មីថា ថ្លៃម្ហូបអាហារ ប្រេងឥន្ធនៈ និងគមនាគមន៍ រួមគ្នា គឺជាប្រភពសំខាន់ដែលនាំឲ្យមានអតិផរណា នៅប្រទេសកម្ពុជា ។

## ១.២- ស្ថានភាពអត្រាប្តូរប្រាក់

### ១.២.១- ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក

ក្នុងអំឡុងឆ្នាំ ២០១០ អត្រាប្តូរប្រាក់រៀលមានស្ថិរភាពជាបង្គួរដោយរងការប្រែប្រួលក្នុងគម្លាតមួយទាប ហើយប្រាក់រៀលបានឡើងថ្លៃថែមទៀតផងក្នុងរយៈពេលពីរ ឬ បីខែចុងក្រោយនៃឆ្នាំនេះ ។ ពិនិត្យលើអត្រាប្តូរប្រាក់មធ្យមរវាងប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក ដែលជាមធ្យមភាគនៃអត្រាប្តូរប្រាក់ប្រចាំថ្ងៃក្នុងអំឡុងឆ្នាំ ២០១០ នេះ រូបិយវត្ថុក្នុងស្រុកបានចុះខ្សោយជាមធ្យម ១% ប៉ុណ្ណោះធៀបជាមួយប្រាក់ដុល្លារអាមេរិក ។ អត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំ ២០១០ មានកម្រិត ៤.១៩៨ រៀលក្នុងមួយដុល្លារ ប្រៀបធៀបនឹង ៤.១៥៤ ក្នុងមួយដុល្លារកាលពីឆ្នាំ ២០០៩ ពោលគឺ មានការប្រែប្រួលប្រចាំឆ្នាំប្រហែល ៤៤ រៀល ឬ ១% ដែលជាការវិវត្តដ៏ប្រសើរមួយធៀបទៅនឹងបម្រែបម្រួលប្រមាណ ៩០ រៀល ឬ ២,២% កាលពីឆ្នាំ ២០០៩ ។

អត្រាប្តូរប្រាក់រៀលមានការប្រែប្រួលខ្លាំង នៅក្នុងពាក់កណ្តាលឆ្នាំ ដែលកើនរហូតដល់ចំណុចកំពូលគឺ ៤.២៦៧ រៀលក្នុងមួយដុល្លារនៅថ្ងៃទី ១ ខែកក្កដា ហើយក៏បានស្ថិតនៅក្នុងរង្វង់ ៤.២៥០ រៀលក្នុងមួយដុល្លាររហូតដល់ដំណាច់ខែតុលា បន្ទាប់ពីមានការធ្វើអន្តរាគមន៍ដ៏សកម្មរបស់ធនាគារជាតិនៃកម្ពុជាដើម្បីរក្សាស្ថិរភាពអត្រាប្តូរប្រាក់ ។ គួរកត់សម្គាល់ផងដែរថា ជាទូទៅ កត្តារដូវកាលគឺជាចំណុចសំខាន់មួយក្នុងការបកស្រាយពីការធ្លាក់ថ្លៃនៃរូបិយវត្ថុក្នុងស្រុក ក្នុងអំឡុងពេលចាប់ពីខែឧសភា រហូតដល់ចុងខែតុលា ។ ជាបន្ទាប់ នាអំឡុងខែក្រោយៗមកទៀត តម្រូវការកើនឡើងចំពោះរូបិយវត្ថុជាតិនៅក្នុងរដូវកាលច្រូតកាត់ និងសម្រាប់ធ្វើការទូទាត់កាតព្វកិច្ចពន្ធ បានធ្វើឲ្យតម្លៃប្រាក់រៀលកើនឡើងនៅពេលដែលអត្រាប្តូរប្រាក់មធ្យមក្នុងរយៈពេល ២ ខែចុងក្រោយធ្លាក់ចុះដល់ ៤.០៧២ រៀលក្នុងមួយដុល្លារ ។

អត្រាចុងគ្រាបំផុតសម្រាប់ឆ្នាំ ២០១០ គឺ ៤.០៤៨ រៀល ។ ទិន្នន័យនេះ បង្ហាញនូវការឡើងថ្លៃនៃប្រាក់រៀលចំនួន ៣,២% ធៀបនឹងអត្រាប្តូរចុងគ្រានាឆ្នាំ ២០០៩ ដែលប្រាក់រៀលនៅពេលនោះរងការធ្លាក់ថ្លៃ ១,៨% ។

ក្រាហ្វស្ថិតិ ៥ : **ការវិវត្តនៃអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក**




| | អត្រាប្តូរប្រាក់ប្រចាំខែ (ចុងខែ) | | | | | |
|---|---|---|---|---|---|---|
| | អត្រាទីផ្សារ | | | អត្រាផ្លូវការ | | |
| | ទិញ | លក់ | មធ្យម | ទិញ | លក់ | មធ្យម |
| ធ្នូ-០៩ | ៤.១៨១ | ៤.១៩០ | ៤.១៨៦ | ៤.១៦៥ | ៤.១៧៣ | ៤.១៦៩ |
| មករា-១០ | ៤.១៨៥ | ៤.១៩៣ | ៤.១៨៩ | ៤.១៦៧ | ៤.១៧៥ | ៤.១៧១ |
| កុម្ភៈ-១០ | ៤.១៩៤ | ៤.២០១ | ៤.១៩៨ | ៤.១៨៣ | ៤.១៩១ | ៤.១៨៧ |
| មីនា-១០ | ៤.១៨៩ | ៤.១៩៥ | ៤.១៩២ | ៤.១៨២ | ៤.១៩០ | ៤.១៨៦ |
| មេសា-១០ | ៤.២១៧ | ៤.២២៨ | ៤.២២៣ | ៤.២០០ | ៤.២០៨ | ៤.២០៤ |
| ឧសភា-១០ | ៤.២៤៨ | ៤.២៥៩ | ៤.២៥៣ | ៤.២១៥ | ៤.២២៣ | ៤.២១៩ |
| មិថុនា-១០ | ៤.២៦៦ | ៤.២៧៦ | ៤.២៧១ | ៤.២២២ | ៤.២៣០ | ៤.២២៦ |
| កក្កដា-១០ | ៤.២៥៦ | ៤.២៦៨ | ៤.២៦២ | ៤.២៣៣ | ៤.២៤១ | ៤.២៣៧ |
| សីហា-១០ | ៤.២៦០ | ៤.២៦៤ | ៤.២៥៩ | ៤.២៣៥ | ៤.២៤៣ | ៤.២៣៩ |
| កញ្ញា-១០ | ៤.២៤៥ | ៤.២៥៦ | ៤.២៥១ | ៤.២២៩ | ៤.២៣៧ | ៤.២៣៣ |
| តុលា-១០ | ៤.២១៦ | ៤.២២៤ | ៤.២២០ | ៤.២២២ | ៤.២៣០ | ៤.២២៦ |
| វិច្ឆិកា-១០ | ៤.១៤០ | ៤.១៥០ | ៤.១៤៥ | ៤.១៣០ | ៤.១៤០ | ៤.១៣៥ |
| ធ្នូ-១០ | ៤.០៤៨ | ៤.០៥៣ | ៤.០៥០ | ៤.០៥១ | ៤.០៥៥ | ៤.០៥៣ |

## ១.២.២- ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងរូបិយប័ណ្ណផ្សេងៗមួយចំនួន

ដោយឡែក បើពិនិត្យលើរូបិយប័ណ្ណរបស់ប្រទេសដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជា អត្រាខ្វែងនៃឯកតារូបិយប័ណ្ណទាំងនោះធៀបនឹងប្រាក់រៀល ដែលបានវាស់វែងតាមរយៈប្រាក់ដុល្លារ បានបង្ហាញនូវបម្រែបម្រួលយ៉ាងខ្លាំងក្នុងគម្លាតរវាង +១០% និង -១០% ពីអត្រានាឆ្នាំគោល (ចុងខែធ្នូ ឆ្នាំ២០០៩ - មើលក្រាហ្វខាងក្រោម) ។ ក្នុងចំណោមរូបិយប័ណ្ណដែលបានតាមដានទាំងឡាយ រូបិយ-ប័ណ្ណខាងក្រោមបានឡើងថ្លៃធៀបនឹងប្រាក់រៀល បើធៀបនឹងគ្រាគោល ៖ ប្រាក់ដុល្លារអូស្ត្រាលី និងប្រាក់យ៉េនជប៉ុនចំនួន ១០,១% ប្រាក់រីងហ្គិតម៉ាឡេចំនួន ៨,៤% ប្រាក់បាតថៃចំនួន ៧,២% ប្រាក់ដុល្លារសាំងហ្គាពួរចំនួន ៦% ប្រាក់រូពីឥណ្ឌូណេស៊ីនិងប្រាក់ប៉េសូហ្វីលីពីន ចំនួន ២,៥% និង ប្រាក់វ៉ុនកូរ៉េនិងប្រាក់យ៉ាន់ចិនចំនួន ០,៥% ។ នៅពេលជាមួយគ្នាដែរ អត្រាខ្វែង ចុងគ្រានៃប្រាក់អឺរ៉ូ និងប្រាក់ដុងវៀតណាមបានធ្លាក់ថ្លៃធៀបនឹងប្រាក់រៀល ក្នុងចំនួន ៩,៩% និង ៧,៦% រៀងគ្នា លើតម្លៃរបស់រូបិយប័ណ្ណទាំងពីរកាលពីមួយឆ្នាំមុន ។

ក្រាហ្វស្ថិតិ ៦ : **ការវិវត្តនៃតម្លៃប្រាក់រៀលធៀបនឹងរូបិយប័ណ្ណមួយចំនួន**




## ១.២.៣- ស្ថានភាពអត្រាប្តូរប្រាក់ដុល្លារធៀបនឹងរូបិយប័ណ្ណសំខាន់ៗមួយចំនួន

ការប្រៀបធៀបអត្រាប្តូរប្រាក់ដុល្លារជាមួយរូបិយប័ណ្ណផ្សេងៗមួយចំនួន ជាពិសេស រូបិយប័ណ្ណនៃប្រទេសជាដៃគូពាណិជ្ជកម្មរបស់កម្ពុជាក្នុងឆ្នាំ២០១០ នេះ បានបង្ហាញថា ប្រាក់ដុល្លារបានចុះថ្លៃធៀបនឹងរូបិយប័ណ្ណមួយចំនួន ដូចជា ប្រាក់ដុល្លារអូស្ត្រាលី ១២% ប្រាក់យ៉េនជប៉ុន ១១,៤% ប្រាក់រីងហ្គិតម៉ាឡេស៊ី ១០,៥% ប្រាក់ដុល្លារតៃវ៉ាន់ ៩,៩% ប្រាក់បាតថៃ ៩,៨% ប្រាក់ដុល្លារសិង្ហបុរី ៨,៣% ប្រាក់ប៉េសូហ្វីលីពីន ៥,២% ប្រាក់រ៉ូពីឥណ្ឌូណេស៊ី ៤,៧% ប្រាក់វ៉ុនកូរ៉េ ៣,៨% និងប្រាក់យ៉ាន់ចិន ៣,៣% ។ ទន្ទឹមនឹងនោះដែរ ប្រាក់ដុល្លារបានឡើងថ្លៃធៀបនឹងប្រាក់អឺរ៉ូ ៧,៧% ប្រាក់ដុងវៀតណាម ៥,៥% និងប្រាក់ដុល្លារហុងកុង ០,៤% ។ ប្រាក់អឺរ៉ូក្នុងឆ្នាំនេះ ទទួលរងសម្ពាធធ្លាក់ថ្លៃយ៉ាងខ្លាំងដែលបង្កឡើង ជាពិសេសពីវិបត្តិឱនភាព

ថវិកានៅប្រទេសក្រិច ហើយដែលធ្វើឲ្យទីផ្សារសញ្ញាប័ណ្ណក្នុងសហគមន៍អឺរ៉ុបទទួលការវាយលុក និងធ្លាក់ថ្លៃគួរឲ្យកត់សម្គាល់ ។ ចំណែកឯប្រាក់ដុងវៀតណាមវិញ ការធ្លាក់ថ្លៃធៀបនឹងប្រាក់ដុល្លារគឺ បណ្ដាលមកពីមានតម្រូវការរូបិយប័ណ្ណច្រើន ដើម្បីទូទាត់ឱនភាពនៃជញ្ជីងទូទាត់ដែលបានកើនឡើង ។

ក្រាហ្វស្ថិតិ ៧ : **ការវិវត្តនៃតម្លៃប្រាក់ដុល្លារធៀបនឹងរូបិយប័ណ្ណមួយចំនួន**




## ២- ការវិវត្តរូបិយវត្ថុ

សភាពប្រសើរឡើងនៃទិដ្ឋភាពសេដ្ឋកិច្ចសកលលោក រួមទាំងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា បានចូលរួមបង្កើនទំនុកចិត្តវិស័យឯកជនមកលើប្រព័ន្ធធនាគារ ហើយបានរួមចំណែកធ្វើឲ្យការអភិវឌ្ឍរូបិយវត្ថុក្នុងប្រទេសមានសន្ទុះជាធម្មតាឡើងវិញ ។ ជាក់ស្ដែងបរិមាណឥណទានចំពោះវិស័យឯកជនមានកំណើនជាបណ្ដើរៗឡើងវិញ រួមនឹងអត្រាកំណើននៃរូបិយវត្ថុទូទៅ (M2) ដែលក្នុងនោះមានប្រាក់បញ្ញើរបស់និវាសជននៅក្នុងប្រព័ន្ធធនាគារជាចំណែកដ៏សំខាន់ ផងដែរ ។ ចំណែកឯទ្រព្យសកម្មបរទេសសុទ្ធព្រមទាំងដើមទុនរបស់ប្រព័ន្ធធនាគារនៅតែបន្តរក្សាបានកំណើនជាបង្គួរតទៅទៀត ។

ក្រាហ្វស្ថិតិ ៨ : **ស្ថានភាពរូបិយវត្ថុ**



## ២.១- ការផ្គត់ផ្គង់រូបិយវត្ថុ

ក្នុងឆ្នាំ២០១០ នេះ រូបិយវត្ថុទូទៅ (M2) របស់ប្រព័ន្ធធនាគារបានកើនឡើងចំនួន ៣.២៤៨,៥ ពាន់លានរៀល (២០%) ពោលគឺ កើនពី ១៦.២២៨,៣ ពាន់លានរៀល ក្នុងខែធ្នូ ឆ្នាំ២០០៩ ទៅ ១៩.៤៧៦,៨ ពាន់លានរៀល ក្នុងខែធ្នូ ឆ្នាំ២០១០ ។ រូបិយវត្ថុទូទៅនេះ ធ្លាប់មានកំណើនដល់ទៅ ៣៦,៨% នាខែដូចគ្នា ឆ្នាំ២០០៩ និងមានកំណើនត្រឹមតែ ៤,៨% នាខែដូចគ្នា ឆ្នាំ២០០៨ ។ ប្រភពចម្បងនៃកំណើនក្នុងខែធ្នូ ឆ្នាំ២០១០ នេះ គឺប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស ដែលមានកំណើនចំនួន ៣.០៩៨,៣ ពាន់លានរៀល (២៤,៣%) គួបផ្សំនឹងការកើនឡើងនៃរូបិយវត្ថុក្នុងចរាចរណ៍ចំនួន ៩៧ ពាន់លានរៀល (៣,២%) ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំចំនួន ៤៩,៥ ពាន់លានរៀល (១៣,៨%) និងប្រាក់បញ្ញើចរន្តចំនួន ៣,៧ ពាន់លានរៀល (៣,១%) ។ គួរកត់សម្គាល់ផងដែរថា នៅក្នុងអំឡុងឆ្នាំ២០១០ ប្រាក់បញ្ញើជារូបិយប័ណ្ណមានការកើនឡើងស្ទើរតែរៀងរាល់ខែ ដែលមានអត្រាមធ្យមប្រចាំខែស្មើ ១,៨% ធៀបនឹងអត្រាកំណើន ២,៧% នារយៈពេលដូចគ្នាឆ្នាំ២០០៩ ។ នៅក្នុងកំណើននៃប្រាក់បញ្ញើជារូបិយប័ណ្ណសរុបមាន ប្រាក់បញ្ញើសន្សំ ៥១% ប្រាក់បញ្ញើមានកាលកំណត់ ៣៥% និងប្រាក់បញ្ញើចរន្ត ១៤% ។ ការវិវត្តនៃរូបិយវត្ថុក្នុងឆ្នាំនេះ បានឆ្លុះបញ្ចាំងឲ្យឃើញនូវកំណើននៃការប្រើប្រាស់សេវាធនាគារបន្ទាប់ពីមានធនាគារចំណូលថ្មី ការបន្តធ្វើទំនើបនីយកម្មប្រព័ន្ធទូទាត់របស់ធនាគារពាណិជ្ជធំៗមួយចំនួន និងការជំរុញឲ្យប្រើប្រាស់សេវាកម្មធនាគារដោយរាជរដ្ឋាភិបាលក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមក ។

ក្រាហ្វស្ថិតិ ៩ : **សមាសធាតុនៃការផ្គត់ផ្គង់រូបិយវត្ថុ**



## តារាងបម្រែបម្រួលជាភាគរយនៃស្ថិតិរូបិយវត្ថុសំខាន់ៗ និងសន្ទស្សន៍ថ្លៃទំនិញ និងសេវា

(បម្រែបម្រួលប្រចាំឆ្នាំជាភាគរយ)

| | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ |
|---|---|---|---|---|---|---|
| ឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាល | -១០១,៨ | -១២៦,៦ | -៩០,៥ | -៦៤,៥ | ២៤,៦ | ៥,៦ |
| ឥណទានផ្នែកឯកជន | ៣១,៨ | ៥១,៦ | ៧៦,០ | ៥៥,០ | ៦,៥ | ២៦,៦ |
| រូបិយវត្ថុទូទៅ (M2) | ១៦,១ | ៣៨,២ | ៦២,៩ | ៤,៨ | ៣៦,៨ | ២០,០ |
| រូបិយវត្ថុក្នុងចរាចរណ៍ | ១៥,០ | ២៤,៨ | ២៤,៤ | ១៥,៣ | ៣០,៨ | ៣,២ |
| អតិផរណាប្រចាំឆ្នាំ | ៨,៤ | ៤,២ | ១៤,០ | ១២,៣ | ៥,៣ | ៣,១ |

### ២.២- កត្តាជះឥទ្ធិពលដល់បរិមាណរូបិយវត្ថុ

ក្នុងឆ្នាំ២០១០ នេះ រូបិយវត្ថុទូទៅមានអត្រាកំណើនទាបជាងឆ្នាំ២០០៩ ១៦,៨% និងលើសឆ្នាំ ២០០៨ ១៥,២% ។ ការកើនឡើងនៃរូបិយវត្ថុទូទៅនេះ ដោយសារកំណើននៃទ្រព្យសកម្មបរទេសសុទ្ធរបស់ប្រព័ន្ធធនាគារចំនួន ២.០៤២,៩ ពាន់លានរៀល (១៣,៩%) គួបផ្សំនឹងកំណើននៃទ្រព្យសកម្មក្នុងស្រុកសុទ្ធចំនួន ១.២០៥,៦ ពាន់លានរៀល (៧៦,៦%) ផងដែរ ។ ការកើនឡើងនៃទ្រព្យសកម្មបរទេសសុទ្ធរបស់ប្រព័ន្ធធនាគារនេះ ជាចម្បងបណ្តាលមកពីការកើនឡើងព្រមគ្នានៃទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិនៃកម្ពុជាចំនួន ១.៧២០,៦ ពាន់លានរៀល (១៣%) និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារទទួលប្រាក់បញ្ញើ (ធនាគារពាណិជ្ជ និងធនាគារឯកទេស) ចំនួន ៣២២,៣ ពាន់លានរៀល (២៣,១%) ។ ចំណែកឯការកើនឡើងនៃទ្រព្យសកម្មក្នុងស្រុកសុទ្ធ គឺបណ្តាលមកពីកំណើននៃឥណទានចំពោះវិស័យឯកជន[១] ចំនួន ២.៧៩៩,២ ពាន់លានរៀល (២៦,៦%) ឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាលចំនួន ១២៥,១ ពាន់លានរៀល (៥,៦%) ខណៈដែលដើមទុននិងទុនបម្រុងរបស់ប្រព័ន្ធធនាគារបានកើនឡើងចំនួន ១.៤១៥,៣ ពាន់លានរៀល (១៩,៥%) ។ នៅក្នុងកំណើនឥណទានចំពោះវិស័យឯកជនសរុប វិស័យដែលរួមចំណែកធំជាងគេមានឥណទានចំពោះវិស័យ ជួញដូរដុំ (៣៦%) ជួញដូររាយ (១៧%) សេវាកម្មមិនមែនហិរញ្ញវត្ថុផ្សេងៗ (១៦%) និងកម្មន្តសាល (៩%)។ ដោយឡែក ឥណទានចំពោះវិស័យកសិកម្មមានកំណើន ២៤,៧% នៅឆ្នាំ ២០១០ នេះ ។

---

១ ឥណទានដុល=ឥណទានសរុប+ការប្រាក់បង្គរ

## ២.២.១- ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា

ទ្រព្យសកម្មក្នុងស្រុកសុទ្ធរបស់ធនាគារជាតិនៃកម្ពុជាបានថយចុះចំនួន ២១៧,១ ពាន់លានរៀល (៤,៨%) ពោលគឺ ថយចុះពី -៤.៥២០,៥ ពាន់លានរៀល ក្នុងខែធ្នូ ឆ្នាំ២០០៩ មក -៤.៧៣៧,៦ ពាន់លានរៀល ក្នុងឆ្នាំ២០១០ នេះ បន្ទាប់ពីបានកើនឡើងចំនួន ១៥៥,៧ ពាន់លានរៀល (៣,៣%) នាឆ្នាំកន្លងទៅ ។ ការថយចុះនៃទ្រព្យសកម្មក្នុងស្រុកសុទ្ធបណ្តាលមកពីការថយចុះនៃខ្ទង់ផ្សេងៗសុទ្ធចំនួន ២៦៣,៥ ពាន់លានរៀល (១១,៧%) និងឥណទេយ្យសុទ្ធពីបណ្តាធនាគារពាណិជ្ជចំនួន ១៤២,៧ ពាន់លានរៀល (៤៨,១%) ខណៈដែលខ្ទង់ឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាលកើនឡើងចំនួន ១៩១ ពាន់លានរៀល (៩,៧%) ។ ការកើនឡើងនៃឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាលជារួមឆ្លុះបញ្ចាំងនូវការថយចុះនៃប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាល ខណៈដែលឥណទានចំពោះរាជរដ្ឋាភិបាលមិនមានការប្រែប្រួល ។

ក្នុងអំឡុងឆ្នាំ២០១០ នេះដែរ ទ្រព្យសកម្មបរទេសសុទ្ធបានកើនឡើងចំនួន ១.៧២០,៦ ពាន់លានរៀល (១៣%) ។ ការវិវត្តនេះបណ្តាលមកពីកំណើននៃទ្រព្យសកម្មបរទេសចំនួន ១.៧០០,៥ ពាន់លានរៀល (១២,៤%) រួមផ្សំនឹងការថយចុះតិចតួចនៃទ្រព្យអកម្មបរទេសចំនួន ២០,១ ពាន់លានរៀល (៤,៥%) ។ គួរកត់សម្គាល់ថា នៅក្នុងឆ្នាំនេះ មាសដែលជាធាតុផ្សំមួយនៃទ្រព្យសកម្មបរទេសនៅតែបន្តឡើងថ្លៃ ។

## ២.២.២- ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារពាណិជ្ជ

ក្នុងឆ្នាំ២០១០ នេះ ទ្រព្យសកម្មសរុបរបស់បណ្តាធនាគារពាណិជ្ជមានការកើនឡើងគួរឲ្យកត់សម្គាល់ចំនួន ៥.០២៨,៦ ពាន់លានរៀល (២៣,៦%) ខណៈដែលទ្រព្យអកម្មក្នុងរូបភាពជាប្រាក់បញ្ញើបានកើនឡើងចំនួន ៣.១៥៦ ពាន់លានរៀល (២៣,៩%) (មាន ៩៨% ជាប្រាក់បញ្ញើជារូបិយប័ណ្ណ) ឆ្លុះបញ្ចាំងឲ្យឃើញនូវកំណើនសាច់ប្រាក់ងាយស្រួលដែលជាកត្តាសំខាន់មួយគាំទ្រដល់សកម្មភាពឥណទានរបស់ធនាគារ និងរួមចំណែកជួយសម្រួលដល់ការវិនិយោគនៅក្នុងប្រទេស ផងដែរ ។

ទ្រព្យសកម្មក្នុងស្រុកសុទ្ធ បានកើនឡើងចំនួន ១.៤៥១,៨ ពាន់លានរៀល (២៥,៣%) ។ បម្រែបម្រួលនេះ ជាចម្បងបណ្តាលមកពីការកើនឡើងនៃខ្ទង់ឥណទានចំពោះវិស័យឯកជនចំនួន ២.៨០១,២ ពាន់លានរៀល (២៦,៦%) ខណៈដែលមានការថយចុះនៃខ្ទង់ទ្រព្យសកម្មផ្សេងៗសុទ្ធចំនួន ១.២៨៥,២ ពាន់លានរៀល (២៨,៤%) និងឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាលចំនួន ៦៥,៩ ពាន់លានរៀល (២៣,៩%) ។ ការថយចុះនៃទ្រព្យសកម្មផ្សេងៗសុទ្ធជាលទ្ធផលនៃការកើនឡើងនៃខ្ទង់ដើមទុន និងទុនបម្រុងចំនួន ១.១៤៨,២ ពាន់លានរៀល (២៦%) ទ្រព្យអកម្មផ្សេងៗចំនួន ១៦៧,១ ពាន់លានរៀល (១៤%) និងបំណុលអន្តរធនាគារ (Inter-bank liabilities) ចំនួន ១០៩,១ ពាន់លានរៀល (១២,៩%) ខណៈដែលទ្រព្យសកម្មកើនឡើងតែចំនួន ១៤០ ពាន់លានរៀល (៧,២%) ។ ទន្ទឹមនេះដែរ ប្រាក់បញ្ញើរបស់បណ្តាធនា-គារពាណិជ្ជនៅធនាគារជាតិនៃកម្ពុជា ដែលជាធាតុផ្សំនៃទុនបម្រុងអន្តរជាតិបានកើនឡើងចំនួន ១.៣២៧,៩ ពាន់លានរៀល (២២,២%) ។

ទ្រព្យសកម្មបរទេសសុទ្ធរបស់បណ្តាធនាគារពាណិជ្ជ បានកើនឡើងចំនួន ៣២២,៣ ពាន់លានរៀល

(២៣,១%) ពោលគឺ ពី ១.៣៩៣,២ ពាន់លានរៀល ក្នុងខែធ្នូ ឆ្នាំ២០០៩ មក ១.៧១៥,៥ ពាន់លានរៀល ក្នុងខែធ្នូ ឆ្នាំ២០១០ ។ កំណើននេះបណ្តាលមកពីការកើនឡើងនៃទ្រព្យសកម្មបរទេសចំនួន ៧០៣,៧ ពាន់លានរៀល (២៥,១%) ខណៈដែលទ្រព្យអកម្មបរទេសកើនចំនួន ៣៨១,៥ ពាន់លានរៀល (២៧%) ។

## ២.៣- អត្រាការប្រាក់លើប្រាក់កម្ចី និងប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ

សេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មាននឹងមានកំណើន ៥,៥% នៅឆ្នាំ២០១០ ហើយអត្រាអតិផរណាឆ្នាំលើឆ្នាំស្ថិតក្នុងកម្រិតមួយខ្ពង់ប្រមាណ ៣,១% ខណៈអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារមានស្ថិរភាពជាបង្គួរ ។ ធនាគារជាតិនៃកម្ពុជាបានសម្រេចបន្តរក្សាអត្រាទុនបម្រុងកាតព្វកិច្ចជារូបិយប័ណ្ណក្នុងកម្រិត ១២% ដែលជាកម្រិតមួយត្រូវបានបន្ថយចុះពី ១៦% កាលពីដើមឆ្នាំ២០០៩ ។ ដោយឡែក អត្រាទុនបម្រុងកាតព្វកិច្ចជារៀលត្រូវបានរក្សាក្នុងកម្រិត ៨% ដែលជាកម្រិតមួយដូចនឹងកម្រិតនៃគ្រាមុនពេលមានវិបត្តិសកលលោក ។

ដោយពិនិត្យលើចលនាអត្រាការប្រាក់លើប្រាក់កម្ចី និងប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជបានបង្ហាញឱ្យឃើញថា ក្នុងឆ្នាំ២០១០ នេះ អត្រាការប្រាក់បញ្ញើដែលវាស់ដោយកម្រិតមធ្យមថ្លឹងតាមទំហំនៃប្រតិបត្តិការធនាគារសម្រាប់រយៈពេល ៦ខែ ជាប្រាក់រៀល បានកើនឡើងតិចតួចប្រមាណ ០,២១% ពី ៥,២៨% នាដំណាច់ឆ្នាំ២០០៩ ដល់ ៥,៤៩% នៅដំណាច់ឆ្នាំ២០១០ និងជាប្រាក់ដុល្លារបានថយចុះប្រមាណ ០,៨៥% ពី ៤,៣៣% នាដំណាច់ឆ្នាំ២០០៩ មក ៣,៤៨% នៅដំណាច់ឆ្នាំ២០១០ ។ ការថយចុះអត្រាការប្រាក់បញ្ញើជាប្រាក់ដុល្លារ ឆ្លុះបញ្ចាំងនូវសំណល់សាច់ប្រាក់ងាយស្រួលជាដុល្លារនៅក្នុងប្រព័ន្ធធនាគារ ។



ក្រាហ្វិស្ថិតិ ១០ : អត្រាការប្រាក់កម្ចី និងប្រាក់បញ្ញើ (អត្រាមធ្យម ៦ ខែ)

ដោយឡែក ក្នុងអំឡុងពេលដូចគ្នានេះដែរ អត្រាការប្រាក់កម្ចីដែលវាស់ដោយកម្រិតមធ្យមថ្លឹងតាមទំហំនៃប្រតិបត្តិការធនាគារសម្រាប់រយៈពេល ៦ខែ ជាប្រាក់រៀល បានថយចុះប្រមាណ ០,៦០% ពី ២២,៦៤% នាដំណាច់ឆ្នាំ២០០៩ មក ២២,០៤% នៅដំណាច់ឆ្នាំ២០១០ និងជាប្រាក់ដុល្លារ បានកើនឡើងប្រមាណ ១,៩៧% ពី ១៧,១៧% នាដំណាច់ឆ្នាំ២០០៩ មក ១៩,១៤% នៅឆ្នាំ២០១០ នេះ ។ ការថយចុះអត្រាការ

ប្រាក់កម្ចីជារៀលនឹងជួយដល់វិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ ព្រមទាំងចូលរួមជំរុញការប្រើប្រាស់ប្រាក់រៀល ផងដែរ ។ ផ្ទុយទៅវិញ ការកើនឡើងនៃអត្រាការប្រាក់កម្ចីជាដុល្លារ អាចជាលទ្ធផលនៃនយោបាយឥណទានប្រុងប្រយ័ត្នរបស់គ្រឹះស្ថានធនាគារ ។

ក្នុងអំឡុងឆ្នាំ២០១០ នេះ គម្លាតអត្រាការប្រាក់ជារៀល បានថយចុះពី ១៧,៣៦% នាដំណាច់ឆ្នាំ២០០៩ មក ១៦,៥៥% នៅដំណាច់ឆ្នាំ២០១០ ។ ដោយឡែក គម្លាតអត្រាការប្រាក់ជាដុល្លារ បានកើនឡើងពី ១២,៨៤% នាដំណាច់ឆ្នាំ២០០៩ ទៅ ១៥,៦៦% នៅដំណាច់ឆ្នាំ២០១០ នេះ ។ ទំហំនៃគម្លាតនេះបង្ហាញពីចំណាយប្រតិបត្តិការរបស់ប្រព័ន្ធធនាគារនៅខ្ពស់នៅឡើយ ខណៈសេដ្ឋកិច្ចវិមាត្រក៏នៅមានទំហំតូចបើធៀបនឹងសកម្មភាពធនាគារនានានៅប្រទេសជិតខាង ។

### តារាងអត្រាការប្រាក់លើប្រាក់កម្ចី និងប្រាក់បញ្ញើ
### ( អត្រាមធ្យម ៦ខែ - ជាភាគរយ )

| | ធ្នូ- ០៩ | មករា | កម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| អត្រាការប្រាក់បញ្ញើជារៀល | ៥,២៨ | ៥,១៤ | ៥,១២ | ៥,១៣ | ៥,៤៧ | ៥,៤៨ | ៥,៥០ | ៥,៥១ | ៥,៤៩ | ៥,៤៨ | ៥,៥០ | ៥,៤៨ | ៥,៤៩ |
| អត្រាការប្រាក់កម្ចីជារៀល | ២២,៦៤ | ២២,៧០ | ២២,៧០ | ២២,៦៨ | ២២,៦៥ | ២២,៤២ | ២២,៣៩ | ២២,៣៧ | ២២,២៦ | ២២,២៦ | ២២,២០ | ២២,០៨ | ២២,០៤ |
| គម្លាត | ១៧,៣៦ | ១៧,៥៦ | ១៧,៥៨ | ១៧,៥៥ | ១៧,១៨ | ១៦,៩៤ | ១៦,៨៩ | ១៦,៨៦ | ១៦,៧៧ | ១៦,៧៨ | ១៧,០០ | ១៦,៦០ | ១៦,៥៥ |
| | | | | | | | | | | | | | |
| អត្រាការប្រាក់បញ្ញើជាដុល្លារ | ៤,៣៣ | ៤,១៤ | ៤,១៤ | ៤,០៧ | ៤,០១ | ៣,៨៥ | ៣,៨៦ | ៣,៦៩ | ៣,៥៩ | ៣,៧០ | ៣,៥០ | ៣,៤៨ | ៣,៤៨ |
| អត្រាការប្រាក់កម្ចីជាដុល្លារ | ១៧,១៧ | ១៧,២១ | ១៧,២២ | ១៧,២៦ | ១៧,១៧ | ១៧,១៧ | ១៧,១៣ | ១៧,១០ | ១៧,១៧ | ១៧,១៨ | ១៧,០៦ | ១៨,៩៤ | ១៩,១៤ |
| គម្លាត | ១២,៨៤ | ១៣,០៧ | ១៣,០៨ | ១៣,១៩ | ១៣,១៦ | ១៣,១២ | ១៣,២៧ | ១៣,៤១ | ១៣,៥១ | ១៣,៤៨ | ១៣,៥៦ | ១៥,៤៦ | ១៥,៦៦ |

## ៣- ជញ្ជីងទូទាត់

នៅឆ្នាំ២០១០ ប្រតិបត្តិការជញ្ជីងទូទាត់របស់ប្រទេសកម្ពុជាមានស្ថានភាពល្អប្រសើរឡើងវិញ ។ សមតុល្យគណនីបង្វែរផ្លូវការ និងគណនីហិរញ្ញវត្ថុមានអតិរេក ១.៤៣៤,៣ លានដុល្លារអាមេរិក ខណៈដែលសមតុល្យគណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្លូវការ) មានឱនភាព ១.២៣៧,៩ លានដុល្លារអាមេរិក ។ ជាលទ្ធផលសមតុល្យរួម មានអតិរេកចំនួន ១៤៣,២ លានដុល្លារអាមេរិក បន្ទាប់ពីមានឱនភាពចំនួន ៤,៧ លានដុល្លារអាមេរិក នៅឆ្នាំ២០០៩ ។ ក្នុងឆ្នាំ២០១០ នេះ ផលធៀបនៃសមតុល្យរួម និងផលិតផលក្នុងស្រុកសរុបមានកម្រិត ១,៣% ។

### ៣.១- គណនីចរន្ត ( មិនរាប់បញ្ចូលបង្វែរផ្លូវការ )

សមតុល្យគណនីចរន្តមានឱនភាពប្រមាណ ១.២៣៧,៩ លានដុល្លារអាមេរិក បានកើនឡើង ៣៥ លានដុល្លារអាមេរិក (២,៩%) ធៀបនឹងឆ្នាំ២០០៩ ។ ឱនភាពគណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្លូវការ) មានចំណែកប្រមាណ ១១,២% នៃផលិតផលក្នុងស្រុកសរុប ។ ការកើនឡើងឱនភាពគណនីទំនិញប្រមាណ ៣,៩% និងឱនភាពគណនីប្រាក់ចំណូលសុទ្ធប្រមាណ ២,៨% ជាមូលហេតុចម្បងដែលបណ្តាលឲ្យមានការកើនឡើងឱនភាពគណនីចរន្ត ។ ឱនភាពគណនីចរន្តនេះ ត្រូវបានជាត់ទាត់ដោយកំណើនអតិរេកនៃគណនី

បង្វែរឯកជនសុទ្ធ ៥% និងគណនីសេវាសុទ្ធ ៤,៤% ។



ក្រាហ្វស្ថិតិ ១១ : **ជញ្ជីងពាណិជ្ជកម្ម** (**ឆ្នាំ១៩៩៨-២០១០**)

ក្នុងឆ្នាំ២០១០ នេះ ដោយសារវិបត្តិសេដ្ឋកិច្ចសកលបានធូរស្រាលបន្តិច នាំឲ្យមានសញ្ញាវិជ្ជមានចំពោះតម្រូវការនៅក្រៅប្រទេស ។ ស្ថានភាពនេះ បានផ្តល់លទ្ធភាពដល់ប្រទេសកម្ពុជាក្នុងការនាំចេញផលិតផលក្នុងស្រុកប្រមាណ ៤.៣៦៣,៤ លានដុល្លារអាមេរិក កើនឡើង ៤៨៤ លានដុល្លារអាមេរិក (១២,៥%) ធៀបនឹងឆ្នាំ២០០៩ ។ ការនាំចេញសម្លៀកបំពាក់ និងវាយនភ័ណ្ឌ បានកើនឡើងចាប់ពីត្រីមាសទី១ រហូតដល់ដំណាច់ឆ្នាំ២០១០ បន្ទាប់ពីតម្រូវការប្រើប្រាស់នៅក្រៅប្រទេសបានរួមតូចកាលពីឆ្នាំ២០០៩ ។ ក្នុងអំឡុងឆ្នាំ២០១០ នេះ ការនាំចេញសម្លៀកបំពាក់ និងវាយនភ័ណ្ឌមានចំនួនប្រមាណ ២.៨៩៨,៣ លានដុល្លារអាមេរិក បានកើនឡើង ៣៨៣,៥ លានដុល្លារអាមេរិក (១៥,២%) បន្ទាប់ពីបានធ្លាក់ចុះ ១៦,៤% នៅឆ្នាំ២០០៩ ។ ស្របពេលនេះដែរ ការនាំចេញផលិតផលក្នុងស្រុកផ្សេងទៀតកើនឡើង ៧,៤% ។ ការកើនឡើងថ្លៃនៃផលិតផលស្រូវ ត្រី និងកៅស៊ូ បានរួមចំណែកក្នុងការកើនឡើងតម្លៃនៃការនាំចេញផលិតផលក្នុងស្រុកនេះ ។

ក្នុងឆ្នាំ២០១០ ការនាំចូលទំនិញសម្រាប់ប្រើប្រាស់ក្នុងស្រុកមានតម្លៃប្រមាណ ៦.១០៩,៥ លានដុល្លារអាមេរិក បានកើនឡើង ៥៤៤,១ លានដុល្លារអាមេរិក (៩,៨%) ធៀបនឹងឆ្នាំ២០០៩ ។ ការកើនឡើងនៃការនាំចូលវត្ថុធាតុដើមសម្រាប់ឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ ១៤,៧% និងការនាំចូលសម្ភារៈសាងសង់ ២,៣% ជាសមាសធាតុសំខាន់នាំឲ្យមានកំណើននៃការនាំចូលទំនិញសម្រាប់ប្រើប្រាស់ក្នុងស្រុកនេះ ។

ក្នុងអំឡុងពេលដូចគ្នានេះ អតិរេកនៃគណនីសេវាសុទ្ធបានកើនពី ៦០៦,៤ លានដុល្លារអាមេរិក នៅឆ្នាំ២០០៩ ដល់ ៦៣៣ លានដុល្លារអាមេរិក ។ ការកើនឡើងអតិរេកនេះ ដោយសារប្រាក់ចំណូលពីផ្នែកសេវាបានកើនឡើង ២៧,៧ លានដុល្លារអាមេរិក (១,៧%) ខណៈដែលចំណាយទូទាត់សេវាទៅឲ្យអនិវាសជនបានកើនឡើង ១,១ លានដុល្លារអាមេរិក (០,១%) ។ ចំណូលពីសេវាទេសចរណ៍មានចំនួនប្រមាណ ១.២៤៩,៨ លានដុល្លារអាមេរិក បានកើនឡើង ៥% ធៀបនឹងឆ្នាំកន្លងទៅ ។ ចំនួនភ្ញៀវទេសចរបរទេសដែលបានចូល

មកទស្សនាប្រទេសកម្ពុជា ត្រូវបានប៉ាន់ស្មានថាមានចំនួន ២,៤ លាននាក់ កើនឡើងប្រមាណ ១០% ទោះបី កំណើនសេដ្ឋកិច្ចពិភពលោករងសម្ពាធពីវិបត្តិសកលនៅឆ្នាំ២០០៩ និងដំណើរងើបឡើងសន្សឹមៗនៅឆ្នាំ២០១០ នេះក៏ដោយ ។ តាមរយៈការវាយតម្លៃថ្មីៗបានបង្ហាញថា ប្រទេសជាច្រើននៅទ្វីបអាស៊ីមិនទទួលរងផល វិបាកធ្ងន់ធ្ងរពីវិបត្តិសកលទេ ដែលនាំឲ្យអ្នកទេសចរនៅតំបន់អាស៊ីដែលបានចូលមកប្រទេសកម្ពុជានៅតែ បន្តកើនឡើង ក្នុងនោះ ភ្ញៀវទេសចរវៀតណាមមានសមាមាត្រខ្ពស់ជាងគេ (១៣,៥%) បន្ទាប់គឺ កូរ៉េ (១២,១%) និងជប៉ុន (៧,៧%) ។ ក្នុងអំឡុងពេលនេះដែរ គណនីប្រាក់ចំណូលសុទ្ធមានឱនភាពប្រមាណ ៤៨១,២ លានដុល្លារអាមេរិក បានកើនឡើង ១៣ លានដុល្លារអាមេរិក (២,៨%) ធៀបនឹងឆ្នាំ២០០៩ ។ ការកើនឡើងការផ្ទេរប្រាក់ចំណូលពីការវិនិយោគនៅកម្ពុជាបានកើនឡើង ៣% បណ្តាលឲ្យមានកំណើន ឱនភាពប្រាក់ចំណូលសុទ្ធនេះ ។ គណនីបង្វែរឯកជនសុទ្ធមានអតិរេកប្រមាណ ៣០៧,៨ លានដុល្លារ អាមេរិក បានកើនឡើង ១៤,៧ លានដុល្លារអាមេរិក (៥%) ។ ការកើនឡើងនេះដោយសារកំណើនប្រាក់បង្វែរ របស់ជនជាតិកម្ពុជាធ្វើការងារនៅក្រៅប្រទេស ។

### ៣.២- គណនីបង្វែរផ្លូវការ និងហិរញ្ញវត្ថុ

នៅឆ្នាំ២០១០ នេះ សមតុល្យនៃគណនីចរន្ត និងបង្វែរផ្លូវការមានឱនភាព ៤៣៨,១ លានដុល្លារអាមេរិក ធៀបនឹងឱនភាពនៅឆ្នាំ២០០៩ ដែលមានចំនួន ៦១០,៣ លានដុល្លារអាមេរិក ។ ការថយចុះសមតុល្យនេះ ដោយសារមានការកើនឡើងលំហូរចូលនៃគណនីបង្វែរផ្លូវការសុទ្ធ ៣៥% ខណៈដែលគណនីចរន្តបានកើន ឡើង ២,៩% ។ គណនីបង្វែរផ្លូវការក្នុងរូបភាពជាហិរញ្ញប្បទានសហប្រតិបត្តិការឥតសំណងមានលំហូរចូល ប្រមាណ ៧៩៩,៧ លានដុល្លារអាមេរិក បានកើនឡើង ២០៧,១ លានដុល្លារអាមេរិក ធៀបនឹងលំហូរចូល ក្នុងឆ្នាំ២០០៩ ។ ក្នុងអំឡុងពេលដដែលនេះ ហិរញ្ញប្បទានសហប្រតិបត្តិការជាប្រាក់កម្ចីផ្លូវការសុទ្ធមានចំនួន ប្រមាណ ១៨៨ លានដុល្លារអាមេរិក បានកើនឡើង ៣៤,៩ លានដុល្លារអាមេរិក (២២,៨%) ធៀបនឹង ឆ្នាំកន្លងទៅ ។ ទន្ទឹមនឹងនេះ លំហូរវិនិយោគផ្ទាល់បរទេសសុទ្ធមានចំនួនប្រមាណ ៥៥៣ លានដុល្លារ អាមេរិក បានកើនឡើង ៤១,៧ លានដុល្លារអាមេរិក (៨,១%) ធៀបនឹងលំហូរចូលក្នុងឆ្នាំ២០០៩ ក្នុងនោះ លំហូរវិនិយោគផ្ទាល់បរទេសផ្នែក កសិឧស្សាហកម្ម កាត់ដេរសម្លៀកបំពាក់ ឧស្សាហកម្មផលិតស្បែកជើង និងភេសជ្ជៈបានកើនឡើងគួរឲ្យកត់សម្គាល់ ។




ជាទូទៅ ប្រតិបត្តិការជញ្ជីងទូទាត់របស់ប្រទេសកម្ពុជាក្នុងឆ្នាំ២០១០ នេះ បានបង្ហាញថាសមតុល្យរួមមានអតិរេកប្រមាណ ១៤៣,២ លានដុល្លារអាមេរិក ដែលមានលទ្ធភាពទ្រទ្រង់ដើម្បីផាត់ទាត់ឲ្យឱនភាពគណនីចរន្តបាន ។ អតិរេកនៃសមតុល្យរួមនេះ ឆ្លុះបញ្ចាំងពីកំណើនទុនបម្រុងបរទេសដែលអាចធានាឲ្យការទូទាត់ទំនិញនាំចូលបានប្រមាណ ៤ ខែ ។




## ៤- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ

### ៤.១. ការងារវិនិយោគទុនបម្រុងអន្តរជាតិ

ធនាគារជាតិនៃកម្ពុជាវិនិយោគទុនបម្រុងអន្តរជាតិក្រោមរូបភាពជា Overnight ប័ណ្ណរតនាគារអាមេរិក (US Treasury Bills) ឧបករណ៍ហិរញ្ញវត្ថុរយៈកាលមធ្យម (MTI) សញ្ញាប័ណ្ណរយៈពេលវែង និងប្រាក់បញ្ញើរយៈកាលខ្លី ជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ធនាគារកណ្តាលនៃប្រទេសអភិវឌ្ឍធំៗ និង

គ្រឹះស្ថានធនាគារពាណិជ្ជដែលមានស្តង់ដារ និងចំណាត់ថ្នាក់ឥណទានខ្ពស់នៅប្រទេសបារាំង លុចហ្សំបួរ ស្វីស សហរដ្ឋអាមេរិក ហុងកុង ជប៉ុន និងសឹង្ហបូរី ជាដើម ។ ទន្ទឹមនេះ ទុនបម្រុងមួយចំនួនក៏ត្រូវបាន វិនិយោគតាមរយៈអ្នកចាត់ការខាងក្រៅ ផងដែរ ។

នៅក្នុងឆ្នាំ២០១០ សេដ្ឋកិច្ចសហរដ្ឋអាមេរិក អឺរ៉ុប និងអង់គ្លេស មិនទាន់មានភាពប្រសើរឡើងវិញទាំងស្រុងនៅឡើយទេ ហើយមិនមានការតម្លើងអត្រាការប្រាក់គោល ប្រាក់ដុល្លារអាមេរិក ប្រាក់អឺរ៉ូ និងប្រាក់ផោនអង់គ្លេសទេ ពោលគឺ នៅរក្សាត្រឹម ០,២៥% , ១% និង ០,៥% រៀងគ្នា ដដែល ។ ដោយឡែកធនាគារកណ្តាលអូស្ត្រាលីបានតម្លើងអត្រាការប្រាក់គោល ប្រាក់ដុល្លារអូស្ត្រាលី ៤ លើក ចំនួន ១០០ពិន្ទុ គឺពី ៣,៧៥% ទៅ ៤,៧៥% ។ អត្រាការប្រាក់គោលដុល្លារអូស្ត្រាលីនេះ អាចនឹងត្រូវបានតម្លើងពី ៥០ពិន្ទុ ទៅ ៧៥ពិន្ទុ សម្រាប់ឆ្នាំ២០១១ ដើម្បីទប់ទល់នឹងការកើនឡើងនៃអតិផរណា ។ ជាមួយនឹងស្ថានភាពនេះ អត្រាការប្រាក់ដែលទទួលបានពីការវិនិយោគទុនបម្រុងអន្តរជាតិជា Overnight ជាមួយធនាគារកណ្តាលអាមេរិក (FED) ទទួលបានក្នុងរង្វង់ពី ០,០១% ទៅ ០,២៧% និងជាមួយធនាគារ Wachovia ទទួលបាន ០,៣០% ។ ទន្ទឹមនេះ ការវិនិយោគជាប្រាក់បញ្ញើមានកាលកំណត់ជាប្រាក់ដុល្លារអាមេរិកទទួលបានក្នុងរង្វង់ពី ០,០៥% ទៅ ០,៧៤% ជាប្រាក់អឺរ៉ូទទួលបានក្នុងរង្វង់ពី ០,១៣% ទៅ ១,២១% ជាប្រាក់ផោនអង់គ្លេសទទួល បានក្នុងរង្វង់ពី ០,៣% ទៅ ០,៥% និងជាប្រាក់ដុល្លារអូស្ត្រាលីទទួលបានក្នុងរង្វង់ពី ៣,៦៨% ទៅ ៤,៧% ។

គិតត្រឹមដំណាច់ឆ្នាំ២០១០ ទុនបម្រុងអន្តរជាតិសរុបដែលបានវិនិយោគគិតជាប្រាក់ដុល្លារអាមេរិក (ដោយមិនរាប់បញ្ចូលមាសចំនួន១២.៤៣៦,០៧៩៥១ គីឡូក្រាម និងប្រាក់ SDR ចំនួន ៦៨,៤៨ លាន SDR) មានចំនួន ៣.០៦៤,២៧ លានដុល្លារអាមេរិក កើនឡើងចំនួន ១៨,២២% ធៀបនឹងចុងខែធ្នូ ឆ្នាំ ២០០៩ (២.៥៩២ លានដុល្លារអាមេរិក) ។

### ៤.២. អន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់

ដើម្បីបំពេញតម្រូវការនៅលើទីផ្សារ និងក្នុងគោលបំណងរក្សាស្ថិរភាពតម្លៃប្រាក់រៀលនៅឆ្នាំ២០១០ នេះ ធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍ដាក់លក់ដេញថ្លៃប្រាក់ដុល្លារអាមេរិកចំនួន ៤៨ លើក មានចំនួនប្រាក់សរុប ៤៨ លានដុល្លាអាមេរិក ដោយស្រូបយកសាច់ប្រាក់រៀលពីទីផ្សារបានចំនួន ២០៣,៣៨ ពាន់លានរៀល ។ ម្យ៉ាងទៀត ធនាគារជាតិនៃកម្ពុជាបានទិញប្រាក់ដុល្លារអាមេរិកចំនួន ៤២ លើកដែលមានទឹកប្រាក់សរុបចំនួន ១២២,៧៩ លានដុល្លារអាមេរិក ដោយចំណាយប្រាក់រៀលអស់ ៥០៤,៤៥ ពាន់លានរៀល ។ ទន្ទឹមនោះ ធនាគារជាតិនៃកម្ពុជាបានទិញប្រាក់ដុល្លារអាមេរិកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំនួន ១២៣,៣៨ លានដុល្លារអាមេរិក និងលក់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំនួន ៧២,៤២ លានដុល្លារអាមេរិក និងលក់ជូនអគ្គិសនីកម្ពុជាចំនួន ១២០,៥ លានដុល្លារអាមេរិក ផងដែរ ។

### ៤.៣. ការគ្រប់គ្រងអាជីវកម្មមាស និងប្តូរប្រាក់

អនុលោមតាមប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតប្រកបអាជីវកម្ម នៅក្នុងឆ្នាំ២០១០ ធនាគារជាតិនៃកម្ពុជាបានផ្តល់អាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតប្រកបអាជីវកម្មប្តូរប្រាក់ចំនួន ១៤ច្បាប់ និង

៤២ច្បាប់ រៀងគ្នា ។ រីឯការផ្តល់អាជ្ញាប័ណ្ណប្រកបអាជីវកម្មនាំចេញ-នាំចូល លោហធាតុ និងត្បូងថ្មមានតម្លៃមានចំនួន ១២ច្បាប់ ។

ចំពោះការផ្តល់លិខិតអនុញ្ញាតប្រកបអាជីវកម្មប្តូរប្រាក់នៅសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត មានចំនួន ១.២៧០ ច្បាប់ ។

## ៥- សម្ព័ន្ធភាពជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

### ៥.១- ការត្រួតពិនិត្យធនាគារពាណិជ្ជ និងធនាគារឯកទេស

ប្រព័ន្ធធនាគារនៅកម្ពុជាមានស្ថានភាពអាជីវកម្មកាន់តែល្អប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ ជាមួយនឹងការងើបឡើងបន្តិចម្តងៗចេញពីវិបត្តិហិរញ្ញវត្ថុសកល ។ ជាក់ស្តែងទិន្នន័យក្នុងឆ្នាំ២០១០ ធៀបទៅនឹងទិន្នន័យឆ្នាំ២០០៩ បង្ហាញពីចំណុចវិជ្ជមានជាច្រើន ដូចជា អនុបាតសាធនភាពមាន ៣១,៤% ខ្ពស់ជាង ការតម្រូវដោយប្រកាសដែលកំណត់ត្រឹម ១៥% រីឯឥណទានមិនដំណើរការមានការថយចុះពី ៦% មក ៣% ចំណែកឯអនុបាតសាច់ប្រាក់ងាយស្រួលពុំមានការប្រែប្រួលទេគឺស្មើនឹង ៩០,៦% ។ ការផ្តល់ឥណទានសរុបរបស់គ្រឹះស្ថានធនាគារមានការកើនឡើងពី ១០.២៦២,៨ ពាន់លានរៀល ដល់ ១៣ ពាន់លានរៀល ដែលស្មើនឹង ២៦,៧% ចំណែកឯអ្នកសុំខ្ចីសរុបមានការកើនឡើងពីចំនួន ២៦៦.២៩៩ នាក់ ទៅ ២៨៦.៣៤៦ នាក់ ស្មើនឹង ៧,៥% និងប្រាក់បញ្ញើសរុបកើនឡើងពី ១៣.៨៤១,៦ ពាន់លានរៀល ដល់ ១៧.៤៧៩,២ ពាន់លានរៀល ស្មើនឹង ២៦,៣% ឯអ្នកដាក់ប្រាក់បញ្ញើសរុបមានការកើនឡើងពីចំនួន ៩៦៨.៤៧២ នាក់ ទៅចំនួន ១.០៦៧.៤០៤ នាក់ កើនឡើង ១២,២% ធៀបនឹងឆ្នាំ២០០៩ ។ ប្រព័ន្ធធនាគារមានការកើនឡើងនូវម៉ាស៊ីនដកប្រាក់ដោយស្វ័យប្រវត្តិ ATM ពីចំនួន ៣៧១ កន្លែង ទៅ ចំនួន ៥០១ កន្លែងស្មើនឹង ៣៥% នៅទូទាំងរាជធានី និងខេត្ត-ក្រុង ។

មកដល់បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាបានចេញផ្សាយ "របាយការណ៍ត្រួតពិនិត្យធនាគារ" បានចំនួន ៥ឆ្នាំហើយ ដែលបានបង្ហាញអំពីតួលេខសរុបនៃប្រតិបត្តិការសំខាន់ៗមួយចំនួនរបស់គ្រឹះស្ថានធនាគារសម្រាប់ជាប្រយោជន៍ដល់សាធារណជនទូទៅស្វែងយល់អំពីប្រតិបត្តិការនៃប្រព័ន្ធធនាគារនៅកម្ពុជា និងបង្ហាញអំពីមុខងារភារកិច្ចរបស់អាជ្ញាធរត្រួតពិនិត្យធ្វើយ៉ាងណាឱ្យប្រព័ន្ធធនាគារមានសុវត្ថិភាព និងសុខភាពល្អ ដើម្បីជំរុញការអភិវឌ្ឍប្រព័ន្ធធនាគារ និងការពារផលប្រយោជន៍ដល់អតិថិជនជាអ្នកដាក់ប្រាក់បញ្ញើ រួមចំណែកទ្រទ្រង់កំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ។

### ៥.២- ការត្រួតពិនិត្យលើឯកសារ

ចំពោះការត្រួតពិនិត្យសកម្មភាពប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារ ត្រូវបានអនុវត្តជាប្រចាំដើម្បីពិនិត្យលើការអនុវត្តច្បាប់ និងបទបញ្ញាប្រុងប្រយ័ត្នរបស់គ្រឹះស្ថានធនាគារ ។ ការត្រួតពិនិត្យនេះ បានធ្វើតាមរយៈការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីរកឱ្យឃើញនូវសកម្មភាពប្រតិបត្តិការណាដែលមានភាពមិនប្រក្រតីដើម្បីមានវិធានការកែតម្រូវឲ្យទាន់ពេលវេលា ។ ការត្រួតពិនិត្យត្រូវបានយកចិត្តទុកដាក់ ជាពិសេស

ទៅលើភាពគ្រប់គ្រាន់នៃដើមទុន គុណភាពទ្រព្យសកម្ម ស្ថានភាពប្រាក់ចំណេញ និងការគ្រប់គ្រងសាច់ប្រាក់ងាយស្រួល ។ ជារួម ស្ថានភាពហិរញ្ញវត្ថុរបស់បណ្តាគ្រឹះស្ថានធនាគារមានភាពល្អប្រសើរគួរឱ្យកត់សម្គាល់ ដោយគ្រឹះស្ថានទាំងនោះបានអនុវត្តស្របតាមបទប្បញ្ញត្តិនានារបស់ធនាគារជាតិនៃកម្ពុជា ។

## ៥.៣- ការត្រួតពិនិត្យដល់ទីកន្លែង

នៅឆ្នាំ២០១០ នេះ ផែនការត្រួតពិនិត្យដល់ទីកន្លែងបានកំណត់គ្រឹះស្ថានធនាគារចំនួន ២១ ក្នុងនោះមានធនាគារចំនួន ១១ ត្រូវអនុវត្តការត្រួតពិនិត្យជាវិសាលភាពពេញលេញ និងធនាគារចំនួន ១០ ត្រូវអនុវត្តការត្រួតពិនិត្យតាមជាវិសាលភាពតាមមុខសញ្ញា ។ ផែនការនេះ ត្រូវបានធ្វើឡើងដោយគ្របដណ្តប់ចំពោះធនាគារធំៗ ដើម្បីបង្ការហានិភ័យជាប្រព័ន្ធ ។

ការអនុវត្តការត្រួតពិនិត្យដល់ទីកន្លែង ធ្វើឡើងដោយពិនិត្យ និងតាមដានលើស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្មរបស់ធនាគារ ដើម្បីវាយតម្លៃ និងបង្ការហានិភ័យរបស់ធនាគារ និងការអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិដែលបានដាក់ចេញដោយធនាគារជាតិនៃកម្ពុជា ព្រមទាំងដើម្បីបំពេញនូវរាល់ចម្ងល់ដែលបានលើកឡើងដោយការិយាល័យត្រួតពិនិត្យលើឯកសារ ។

ជាលទ្ធផល រហូតមកដល់ពេលនេះ ធនាគារជាតិនៃកម្ពុជាបានអនុវត្ត និងបញ្ចប់ការត្រួតពិនិត្យដល់ទីកន្លែងចំពោះធនាគារចំនួន ២៥ ដែលរួមមាន ១១ ធនាគារ ជាការត្រួតពិនិត្យពេញលេញ ១០ ធនាគារជាការត្រួតពិនិត្យតាមមុខសញ្ញា និង ៤ ធនាគារ ជាការត្រួតពិនិត្យតាមឯកទេស ។

លទ្ធផលនេះ បានបង្ហាញថា ស្ថានភាពហិរញ្ញវត្ថុ និងការអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិរបស់ធនាគារមានលក្ខណៈល្អប្រសើរ ។ ប៉ុន្តែ ធនាគារមួយចំនួនបានបង្កើនដើមទុនថ្មីនៅដំណាច់ឆ្នាំ២០១០ ។ ទន្ទឹមនឹងនេះ ធនាគារមួយចំនួនទៀតនៅមានបញ្ហាប្រឈម ដូចជា ផែនការយុទ្ធសាស្ត្រ ការត្រួតពិនិត្យផ្ទៃក្នុង ការជ្រើសរើសក្រុមប្រឹក្សាភិបាលឯករាជ្យ ការបង្កើតគណៈកម្មការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម និងគណៈកម្មការសវនកម្ម និងការប្រកាន់ខ្ជាប់នូវការអនុវត្តតាមគោលនយោបាយ និងនីតិវិធីជាលាយលក្ខណ៍អក្សរ ។ រាល់ចំណុចខ្វះខាតទាំងនេះ ធនាគារជាតិនៃកម្ពុជាបានផ្តល់អនុសាសន៍ចំពោះធនាគារសាមី ដើម្បីកែតម្រូវ និងមានវិធានការដោះស្រាយតាមស្ថានភាពជាក់ស្តែង ។

## ៥.៤- ការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

គិតត្រឹមដំណាច់ឆ្នាំ២០១០ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួន ២៥ (ក្នុងនោះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជនមានចំនួន ៦) និងប្រតិបត្តិករឥណទានជនបទមានចំនួន ២៨ ។ ឥណទានសរុបដែលបានផ្តល់មានប្រមាណ ១.៧៨០ ពាន់លានរៀល ដល់អតិថិជនចំនួន ១.០២០.៧៨៤ នាក់ សមាមាត្រនឹង ៤០% នៃចំនួនគ្រួសារសរុប ពោលគឺ កើនឡើងចំនួន ៤០% និង ២១% រៀងគ្នា បើធៀបនឹងឆ្នាំ២០០៩ ។ ចំពោះប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទប្រមូលប្រាក់សន្សំបានប្រមាណ ១៧២ ពាន់លានរៀល ពីអ្នកផ្ញើប្រាក់ចំនួន ២៤០.១៥៣ នាក់ កើនឡើង

ចំនួន ៤ដង និង ៤៣% រៀងគ្នា បើធៀបនឹងឆ្នាំ២០០៩ ។ ការកើនឡើងនេះ បង្ហាញឲ្យឃើញពីការរីកលូតលាស់នៃវិស័យសេដ្ឋកិច្ចជនបទ ជំនឿទុកចិត្តពីសាធារណជន និងវិនិយោគិនទាំងក្នុងស្រុក និងបរទេស និងស្ថិរភាពសេដ្ឋកិច្ចនិងនយោបាយ ។

ផ្អែកលើការវិវត្តរីកចម្រើននៃវិស័យធនាគារទាំងមូល អត្រាប្រជាពលរដ្ឋប្រើប្រាស់សេវាធនាគារនិងហិរញ្ញវត្ថុគិតត្រឹមដំណាច់ឆ្នាំ២០១០ មានចំនួនប្រមាណ ១៥% នៃចំនួនប្រជាពលរដ្ឋសរុប សបញ្ជាក់នូវកិច្ចព្យាយាមប្រឹងប្រែងប្រកបដោយជោគជ័យរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការកៀងគរប្រភពទុនក្នុងស្រុក និងទាក់ទាញប្រជាពលរដ្ឋដែលមិនប្រើប្រាស់សេវាធនាគារ ងាកមកប្រើប្រាស់សេវាធនាគារវិញ ។

ក្រៅពីការត្រួតពិនិត្យលើឯកសារជាប្រចាំចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ការងារត្រួតពិនិត្យដល់ទីកន្លែងបានបង្ហាញឲ្យឃើញថា ការផ្តល់ឥណទានត្រួតគ្នានៅតែមានជាបន្តក្នុងកម្រិតតិចតួច ហើយអត្រាឥណទានមិនដំណើរការបានថយចុះពី ២,៨% ក្នុងឆ្នាំ២០០៩ មកប្រមាណ ១,២% ក្នុងឆ្នាំ២០១០ ។

ដើម្បីរក្សាបានស្ថិរភាពកំណើន និងចីរភាពវិស័យមីក្រូហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបន្តត្រួតពិនិត្យតាមដាន និងដាក់ចេញបទបញ្ញានានាដែលអនុលោមតាមស្តង់ដារ និងការអនុវត្តជាអន្តរជាតិ ដើម្បីឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានមូលដ្ឋានច្បាស់លាស់ក្នុងប្រតិបត្តិការអាជីវកម្មរបស់ខ្លួន នៅក្នុងទីផ្សារប្រកួតប្រជែងស្មើភាព ។

ធនាគារជាតិនៃកម្ពុជាបន្តពង្រឹងសមត្ថភាពមន្ត្រីត្រួតពិនិត្យ និងបន្តកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិ ដើម្បីកៀងគរប្រភពទុនបន្ថែមទៀតដែលជាប្រយោជន៍ក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុជនបទឲ្យកាន់តែទូលំទូលាយថែមទៀត និងរួមចំណែកលើកកំពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន និងកាត់បន្ថយភាពក្រីក្រ ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

ដើម្បីពង្រឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឲ្យកាន់តែមានប្រសិទ្ធភាព និងឈានទៅរកការកេណ្ឌប្រមូលប្រភពទុនក្នុងស្រុកផងនោះ ធនាគារជាតិនៃកម្ពុជាបានផ្តល់អាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើពីសាធារណជន ឲ្យដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៤ រួមមាន ហត្ថាកសិករ អង្គរមីក្រូហិរញ្ញវត្ថុ ប្រាសាក់ និង ក្រេឌីត ។

ក្នុងត្រីមាសទី៣ ឆ្នាំ២០១០ ធនាគារជាតិនៃកម្ពុជាបានដាក់ឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអនុវត្តសាកល្បងនូវប្រព័ន្ធព័ត៌មានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (Microfinance Information System) ដែលតាមរយៈប្រព័ន្ធនេះ របាយការណ៍ហិរញ្ញវត្ថុ គ្រឹះស្ថានត្រូវបានផ្ញើមកធនាគារជាតិនៃកម្ពុជាតាមប្រព័ន្ធវេបសាយ ដោយគ្រោងនឹងអនុវត្តប្រព័ន្ធនេះចាប់ពីឆ្នាំ២០១១ ទៅ ។

នៅថ្ងៃទី០៦-០៧ ខែកញ្ញា ឆ្នាំ២០១០ ធនាគារជាតិនៃកម្ពុជាសហការជាមួយសមាគមឥណទានកសិកម្មជនបទប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក (APRACA) បានសហការរៀបចំវេទិកាជាតិសម្រាប់អភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ ការពិនិត្យឡើងវិញ និងការជំរុញតួនាទីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងការកាត់បន្ថយភាពក្រីក្រ ក្នុងគោលបំណងបន្តជំរុញការលើកទឹកចិត្តតាមគ្រប់រូបភាពដល់គ្រប់អង្គការក្រៅរដ្ឋាភិបាល ដែលធ្វើសកម្មភាពលើវិស័យហិរញ្ញវត្ថុជនបទឲ្យប្រែក្លាយខ្លួនទៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលបានអាជ្ញាប័ណ្ណពី

ធនាគារជាតិនៃកម្ពុជា ដើម្បីធានានូវតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព ទិន្នផលហិរញ្ញវត្ថុ ពង្រឹងគុណភាពសេវាកម្មអតិថិជន និងអាចការការពារផលប្រយោជន៍របស់អតិថិជន ។

ធនាគារជាតិនៃកម្ពុជានៅតែបន្តសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីទទួលបាននូវការគាំទ្រផ្នែកជំនួយបច្ចេកទេស សម្រាប់ពង្រឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាប័ណ្ណ ផ្តល់ជំនាញការដែលមានបទពិសោធន៍សម្រាប់បណ្តុះបណ្តាលមន្ត្រីបុគ្គលិក អំពីការងារត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែង ។

## ៥.៥- ការរៀបចំបទប្បញ្ញត្តិ

ធនាគារជាតិនៃកម្ពុជាបានចេញសារាចរណែនាំស្តីពីការកំណត់ចំណាត់ថ្នាក់វិនិយោគ ប្រកាសស្តីពីការត្រួតពិនិត្យផ្ទៃក្នុងរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រកាសស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ។

## ៥.៦- អាជ្ញាប័ណ្ណ និងការចុះបញ្ជី

ក្នុងឆ្នាំ២០១០ នេះ ធនាគារជាតិនៃកម្ពុជាបានផ្តល់អាជ្ញាប័ណ្ណធនាគារពាណិជ្ជថ្មីចំនួន ៣ និងផ្តល់អជ្ញាប័ណ្ណសាខាធនាគារចំនួន ២២ តាមរាជធានី-ខេត្ត ផ្តល់អាជ្ញាប័ណ្ណដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុថ្មីចំនួន ៦ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ៤ និងចុះបញ្ជីជាប្រតិបត្តិករឥណទានជនបទថ្មីចំនួន ២ ។

# ៦- ការផ្គត់ផ្គង់សេវាធនាគារកណ្តាល

## ៦.១- សេវាផ្នែកគណនី

ធនាគារជាតិនៃកម្ពុជាគ្រប់គ្រងគណនីជារូបិយវត្ថុជាតិ និងជាដុល្លារអាមេរិកចំនួន ១.០៧៦ គណនី ។ គណនីទាំងនោះជារបស់ស្ថាប័នរដ្ឋ អង្គភាពរដ្ឋបាលកណ្តាល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលទទួលបានការអនុញ្ញាតឲ្យធ្វើអាជីវកម្ម និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ។

### ៦.១.១- សេវាផ្នែកគណនីចំពោះស្ថាប័នរដ្ឋ

ដើម្បីរួមចំណែកអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការបង្កើនប្រសិទ្ធភាពកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ធនាគារជាតិនៃកម្ពុជាបានទទួលបើកគណនីជូនស្ថាប័នរដ្ឋបាលកណ្តាល ផ្តល់សេវាដកសាច់ប្រាក់ ផ្ទេរគណនី បើកប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ និងចាត់សម្រួលសាច់ប្រាក់តាមរយៈការបង្វែរប្រាក់របស់រតនាគារជាតិ ។

ការបង់ពន្ធដារ និងពន្ធគយដោយផ្ទាល់នៅធនាគារជាតិនៃកម្ពុជាពីសំណាក់អ្នកជាប់ពន្ធ បានប្រព្រឹត្តទៅដោយរលូនមានបរិមាណ ៣.០២៩ ពាន់លានរៀល ក្នុងឆ្នាំ២០១០ ។

### ៦.១.២- សេវាផ្នែកគណនីចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

គណនីដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានបើកនៅធនាគារជាតិនៃកម្ពុជា រួមមាន គណនីចរន្ត គណនីប្រាក់បញ្ញើមានកាលកំណត់ គណនីប្រាក់បញ្ញើធានាលើដើមទុន និងគណនីប្រាក់បម្រុងកាតព្វកិច្ច ។ សមតុល្យសរុបនៃប្រាក់បញ្ញើទាំងនោះមានចំនួន ១៦០ ពាន់លានរៀល និង ១.៦៩៨ លានដុល្លារអាមេរិក ។

### ៦.១.៣- សេវាផ្ទេរប្រាក់ក្នុងប្រទេស

**.ការផ្ទេរចូលមកទីស្នាក់ការកណ្តាលៈ**

-ជាប្រាក់រៀលមានចំនួន ២.៨៥៧ ពាន់លានរៀល

-ជាប្រាក់ដុល្លារមានចំនួន ១.០៥៩ លានដុល្លារអាមេរិក

**.ការផ្ទេរចេញទៅសាខារាជធានី-ខេត្តៈ**

-ជាប្រាក់រៀលមានចំនួន ៦.០៣៤ ពាន់លានរៀល

-ជាប្រាក់ដុល្លារមានចំនួន ៩៤ លានដុល្លារអាមេរិក ។

## ៦.២- សេវាផាត់ទាត់

ប្រតិបត្តិការផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិក ត្រូវបានអនុវត្តជារៀងរាល់ថ្ងៃធ្វើការ ។ ការទូទាត់តាមរយៈសភាផាត់ទាត់នេះ បានដំណើរការប្រកបដោយប្រសិទ្ធភាព ។

### ៦.២.១- ការផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល

សភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀលមានសមាជិកចំនួន ២៨ ក្នុងនោះ មានធនាគារពាណិជ្ជចំនួន ២៦ ធនាគារឯកទេសចំនួន ១ និងធនាគារជាតិនៃកម្ពុជា ។

ក្នុងឆ្នាំ២០១០ ការផាត់ទាត់បានដំណើរការចំនួន ២៣៦ថ្ងៃ ហើយបានផាត់ទាត់មូលប្បទានប័ត្រចំនួន ៣២.៨៥៤ សន្លឹក ស្មើនឹង ១.៦២៧,១៨ ពាន់លានរៀល ។ ប្រៀបធៀបនឹងឆ្នាំ២០០៩ ចំនួនមូលប្បទានប័ត្រមានការកើនឡើង ៥% និងចំនួនប្រាក់បានកើន ២៣ % ។

### ៦.២.២- ការផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់ដុល្លារ

សភាផាត់ទាត់មូលប្បទានប័ត្រជាប្រាក់ដុល្លារអាមេរិកមានសមាជិកចំនួន ៣៤ ក្នុងនោះ មានធនាគារពាណិជ្ជចំនួន ៣០ ធនាគារឯកទេស ៣ និងធនាគារជាតិនៃកម្ពុជា ។

ក្នុងឆ្នាំ២០១០ ការផាត់ទាត់បានដំណើរការចំនួន ២៣៦ថ្ងៃ ហើយបានផាត់ទាត់មូលប្បទានប័ត្រចំនួន ៤៨៥.១៨៩ សន្លឹក ស្មើនឹង ៧.០០៨,៧៣ លានដុល្លារអាមេរិក ។ ប្រៀបធៀបនឹងឆ្នាំ២០០៩ ចំនួនមូលប្បទានប័ត្រមានការកើនឡើង ១៥% និងចំនួនប្រាក់បានកើន ២០% ។

## ៦.៣- ការខារឥណទានចំពោះរាជរដ្ឋាភិបាល

ក្នុងឆ្នាំ២០១០ ធនាគារជាតិនៃកម្ពុជាមិនបានផ្តល់ឥណទានចំពោះរាជរដ្ឋាភិបាលឡើយ ។

## ៦.៤- ការខារអនុវត្តហិរញ្ញប្បទាន និងកម្ចីរាជរដ្ឋាភិបាល

### ក- ហិរញ្ញប្បទានឥតសំណងពីរដ្ឋាភិបាលជប៉ុន

#### ក.១- ហិរញ្ញប្បទានឥតសំណងជាគម្រោង

នៅក្នុងឆ្នាំ២០១០ នេះ រដ្ឋាភិបាលជប៉ុនបានផ្តល់ហិរញ្ញប្បទានឥតសំណងសម្រាប់គម្រោងថ្មីចំនួន ២ គម្រោង ទី១-គម្រោងសាងសង់ស្ពានអ្នកលឿង (Bridge 2014) មានទឹកប្រាក់ចំនួន ១១.៩៤០ លានយ៉េន និង ទី២-គម្រោងអាហារូបករណ៍អភិវឌ្ឍន៍ធនធានមនុស្ស (Scholarship 2012) មានទឹកប្រាក់ ចំនួន ៣០៦ លានយ៉េន ។ ចំពោះគម្រោងដែលបានផ្តល់នាឆ្នាំកន្លងមក និងកំពុងអនុវត្តមិនទាន់ចប់មាន ដូចខាងក្រោម ៖

១- គម្រោងជួសជុលទ្វារទឹករលាំងជ្រៃ ខេត្តកំពង់ស្ពឺ មានទឹកប្រាក់ចំនួន ៨១៩ លានយ៉េន (ពុំទាន់ប្រើប្រាស់នៅឡើយ) ។

២-គម្រោងអភិវឌ្ឍន៍មន្ទីរពេទ្យខេត្តកំពង់ចាម មានទឹកប្រាក់ចំនួន ១.០៣៩ លានយ៉េន អនុវត្តដល់ខែមីនា ឆ្នាំ២០១១ ។

៣-គម្រោងជីកអណ្តូងទឹកស្អាត ស្រុកមេមត់ ខេត្តកំពង់ចាម មានទឹកប្រាក់ចំនួន ៣៦៩ លានយ៉េន អនុវត្តដល់ខែមីនា ឆ្នាំ២០១១ ។

៤-គម្រោងសាងសង់សាលាបឋមសិក្សានៅរាជធានីភ្នំពេញ មានទឹកប្រាក់ចំនួន ៥២៤ លានយ៉េន អនុវត្តដល់ខែមេសា ឆ្នាំ២០១១ ។

៥-គម្រោងសាងសង់មជ្ឈមណ្ឌលអភិវឌ្ឍន៍វារីវប្បកម្មសមុទ្រ មានទឹកប្រាក់ចំនួន ៩១៣ លានយ៉េន អនុវត្តដល់ខែឧសភា ឆ្នាំ២០១១ ។

៦-គម្រោងអាហារូបករណ៍អភិវឌ្ឍន៍ធនធានមនុស្ស SCHOLARSHIP 0710 មានទឹកប្រាក់ចំនួន ៣៦៤ លានយ៉េន និង SCHOLARSHIP 0811 មានទឹកប្រាក់ចំនួន ៣៥៣ លានយ៉េន អនុវត្តដល់ ឆ្នាំ ២០១១ និង ឆ្នាំ២០១២ រៀងគ្នា ។

គម្រោងដែលបានបញ្ចប់នៅក្នុងឆ្នាំ២០១០ មានគម្រោងសិក្សាលម្អិតក្នុងការសាងសង់ស្ពានអ្នកលឿង (Bridge 2009) មានទឹកប្រាក់ចំនួន ២៣៩ លានយ៉េន ។

#### ក.២- ហិរញ្ញប្បទានឥតសំណងមិនមែនគម្រោង

នៅក្នុងឆ្នាំ២០១០ នេះ រាជរដ្ឋាភិបាលជប៉ុនបានផ្តល់ហិរញ្ញប្បទានឥតសំណងមិនមែនគម្រោងដល់រាជរដ្ឋាភិបាលកម្ពុជាចំនួន ៣ គឺ ទី១-កម្មវិធីអភិរក្សព្រៃឈើ មានទឹកប្រាក់ចំនួន ៩០០ លានយ៉េន ទី២-កម្មវិធីអភិវឌ្ឍន៍គ្រោះធម្មជាតិដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុមានទឹកប្រាក់ចំនួន ១.០០០ លាន

យ៉េន និងទី៣- កម្មវិធីបង្ហាញពីថាមពលបរិស្ថានល្អដោយប្រើប្រាស់ប្រព័ន្ធអគ្គិសនីស្រូបពីពន្លឺព្រះអាទិត្យមានទឹកប្រាក់ចំនួន ៧២០ លានយ៉េន ។

### ខ- កម្ចីសម្បទានរាជរដ្ឋាភិបាលជប៉ុន

នៅក្នុងឆ្នាំ២០១០ នេះ ធនាគារជាតិនៃកម្ពុជាបានទទួលឯកសារកម្ចីសម្បទានសម្រាប់គម្រោងចំនួន ២ គឺ គម្រោងផ្គត់ផ្គង់ទឹកនៅនិរោធន៍ (L/A No.CP-P9) មានទឹកប្រាក់ចំនួន ៣.៥១៣ លានយ៉េន និង គម្រោងអភិវឌ្ឍន៍ផែពហុបំណងរបស់កំពង់ផែក្រុងព្រះសីហនុ មានទឹកប្រាក់ចំនួន ៧.១៧៦ លានយ៉េន ។

ចំពោះគម្រោងដែលបានផ្តល់កន្លងមកកំពុងតែអនុវត្តមិនទាន់ចប់ មានដូចជា ៖

១- គម្រោងអភិវឌ្ឍន៍ខ្សែបណ្តាញថាមពលអគ្គិសនីមហាអនុតំបន់ទន្លេមេគង្គ (L/ANo.CP-P7) មានទឹកប្រាក់ចំនួន ២.៦៣២ លានយ៉េន (ចុះហត្ថលេខាឆ្នាំ២០០៧) ។

២- គម្រោងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ (L/A No.CP-P6) មានទឹកប្រាក់ចំនួន ៣១៨ លានយ៉េន (ចុះហត្ថលេខាឆ្នាំ២០០៦) ។

៣- គម្រោងបង្កើតបណ្តាញទូរគមនាគមន៍មហាអនុតំបន់ទន្លេមេគង្គ (L/A No.CP-P5) មានទឹកប្រាក់ចំនួន ៣.០២៩ លានយ៉េន (ចុះហត្ថលេខាឆ្នាំ២០០៥) ។

## ៧- ការគ្រប់គ្រងចរាចរណ៍ធនប័ត្រ

ក្នុងឆ្នាំ២០១០ ចំណូលសាច់ប្រាក់រៀលតាមបេឡាប្រតិបត្តិការ មានចំនួន ៦.៥៧៥,៦ ពាន់លានរៀល បើធៀបនឹងគ្រាដូចគ្នាឆ្នាំ២០០៩ ថយចុះចំនួន ៥,២% ក្នុងនោះ ចំណូលពីឃ្លាំងសម្របសម្រួលបោះផ្សាយថយចុះ ២៤,៦ ពាន់លានរៀល (០,៨%) ចំណូលពន្ធដារ-ពន្ធគយ ថយចុះ ៥៤៨,៣ ពាន់លានរៀល (៥៦,៥%) ចំណូលប្រាក់កក់ដេញថ្លៃ និងលក់ដុល្លារ ថយចុះ ១៨៥,៦ ពាន់លានរៀល (៨៣,៧%) ។ ផ្ទុយទៅវិញ ក៏មានចំណូលមួយចំនួនកើនឡើងដែរ ដូចជា ប្រាក់បញ្ញើចរន្ត កើនឡើង ៣៨,៩ ពាន់លានរៀល (២,៣%) ប្រាក់បញ្ញើអគ្គិសនីកម្ពុជា កើនឡើង ៨០,៧ ពាន់លានរៀល (១៦,៥%) ចំណូលពីសាខាធនាគារជាតិនៃកម្ពុជា កើនឡើង ១០,៦ ពាន់លានរៀល (៣%) និងចំណូលសាច់ប្រាក់ផ្សេងៗ កើនឡើង ២១៥,៦ ពាន់លានរៀល (៩៤ដង) បើធៀបនឹងគ្រាដូចគ្នាឆ្នាំ២០០៩ ។

រីឯចំណាយសាច់ប្រាក់តាមបេឡាប្រតិបត្តិការវិញ មានចំនួន ៦.៥៧៤,៤ ពាន់លានរៀល បើធៀបនឹងគ្រាដូចគ្នាឆ្នាំ២០០៩ ថយចុះ ៥,៤% ក្នុងនោះ ចំណាយលើការដកប្រាក់បញ្ញើចរន្ត ថយចុះ ៥៧០,២ ពាន់លានរៀល (៥១,៥%) ចំណាយលើការដកប្រាក់បញ្ញើអគ្គិសនីកម្ពុជា ថយចុះ ២៩១,៨ ពាន់លានរៀល (៩៧,៣%) ចំណាយទិញរូបិយប័ណ្ណបរទេស ថយចុះ ៣០៣,៩ ពាន់លានរៀល (១០០%) និងចំណាយឲ្យសាខាធនាគារជាតិនៃកម្ពុជា ថយចុះ ១,៥ ពាន់លានរៀល (០,១%) ។ ផ្ទុយទៅវិញ ក៏មានចំណាយមួយចំនួនកើនឡើងដែរ ដូចជា ចំណាយបញ្ជូនទៅឃ្លាំងសម្របសម្រួលបោះផ្សាយ កើនឡើង ៥២៥,៩ ពាន់លានរៀល (២១%) ចំណាយឲ្យរតនាគារជាតិ កើនឡើង ៤៣,៦ ពាន់លានរៀល (២,៧%) ចំណាយដកប្រាក់កក់ដេញថ្លៃដុល្លារ កើនឡើង ៩ ពាន់លានរៀល (២ដង) និងចំណាយផ្សេងៗ កើនឡើងចំនួន ២១០,៤ ពាន់លានរៀល (៦ដង) បើធៀបនឹងគ្រាដូចគ្នាឆ្នាំ២០០៩ ។

ក្នុងគ្រាដដែលនេះដែរ សកម្មភាពប្រាក់ដុល្លារអាមេរិកបង់ចូលតាមបេឡាប្រតិបត្តិការសរុប មានចំនួន ២.៨២៥,២ លានដុល្លារអាមេរិក បើធៀបនឹងគ្រាដូចគ្នាឆ្នាំ២០០៩ ថយចុះ ២៨១,៤ លានដុល្លារអាមេរិក (៩,១%) ហើយចំណាយតាមរយៈបេឡាប្រតិបត្តិការ មានចំនួន ២.៨២៥,៣ លានដុល្លារ ថយចុះ ២៨០,៨ លានដុល្លារ (៩%) បើធៀបនឹងគ្រាដូចគ្នាឆ្នាំ២០០៩ ។

ដើម្បីសម្រួលដល់ចរាចរណ៍ក្រដាសប្រាក់រៀល ធនាគារជាតិនៃកម្ពុជា បានផ្តល់ក្រដាសប្រាក់ថ្មីឲ្យសាខាធនាគារជាតិនៃកម្ពុជា ដើម្បីដូរយកក្រដាសប្រាក់ចាស់ ទក់ រហែក ចំនួន ២៧៣,៣ ពាន់លានរៀល បើធៀបនឹងគ្រាដូចគ្នាឆ្នាំ២០០៩ កើនឡើង ៥៧,៩ ពាន់លានរៀល (២៦,៩%) ។

លើសពីនេះទៀត ធនាគារជាតិនៃកម្ពុជាបានធ្វើការកាត់កម្ទេច និងបំផ្លាញចោលក្រដាសប្រាក់ចាស់ ទក់ រហែក ដោយម៉ាស៊ីនធម្មតា ចំនួន ៨១៣,៤ ពាន់លានរៀល បើធៀបនឹងគ្រាដូចគ្នាឆ្នាំ២០០៩ កើនឡើង ១៦៦,២ ពាន់លានរៀល (២៥,៧%) និងសាច់ប្រាក់ដែលបានកាត់កម្ទេចដោយម៉ាស៊ីនស្វ័យប្រវត្តិ (BPS) មានចំនួន ៤៣០,៩ ពាន់លានរៀល បើធៀបនឹងគ្រាដូចគ្នាឆ្នាំ២០០៩ កើនឡើងចំនួន ១៨៩,៦ ពាន់លានរៀល (៧៨,៦%) ។

ចំពោះការងារគ្រប់គ្រងសាច់ប្រាក់ និងការងាររាំងខ្ទប់ក្រដាសប្រាក់ក្លែងក្លាយ ធនាគារជាតិនៃកម្ពុជាតែងតែតាមដាន និងធ្វើការអង្កេតជាប្រចាំ ។ ក្នុងឆ្នាំ២០១០ នេះ ធនាគារជាតិនៃកម្ពុជាបានដកហូតក្រដាសប្រាក់ក្លែងក្លាយដែលជាប្រភេទថតចម្លង ចំនួន ៥៦៣ សន្លឹក និងក្រដាសប្រាក់គំរូ ០៤សន្លឹក តាមរយៈការិយាល័យរាប់-ស្រាល់ជ្រើស សាខាធនាគារជាតិនៃកម្ពុជាខេត្តបាត់ដំបង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ AMK និង ធនាគារ ANZ Royal ។

ធនាគារជាតិនៃកម្ពុជាសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីរាំងខ្ទប់ចរាចរណ៍ប្រាក់ក្លែងក្លាយទាំងនៅធនាគារជាតិនៃកម្ពុជា និងសាខាធនាគារជាតិនៃកម្ពុជា ។

## ៨- ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ និងការបំពាក់ប្រព័ន្ធធនាគារស្នូលរបស់ធនាគារជាតិនៃកម្ពុជា

បន្ទាប់ពីមូលប្បទានប័ត្រស្តង់ដារ និងប្រព័ន្ធផាត់ទាត់បណ្តោះអាសន្នសម្រាប់សភាផាត់ទាត់ ត្រូវបានដាក់ឲ្យប្រើប្រាស់នៅខែឧសភា ឆ្នាំ២០០៩ និងបានដំណើរការទៅដោយរលូនរួចមក នៅឆ្នាំ២០១០ ធនាគារ-ជាតិនៃកម្ពុជាបានចាប់ផ្តើមរៀបចំគម្រោងអភិវឌ្ឍន៍ប្រព័ន្ធទូទាត់ និងផាត់ទាត់ដែលមានលក្ខណៈប្រមូលផ្តុំដែលជាជំហានមួយទៀតនៃការអភិវឌ្ឍប្រព័ន្ធជាតិទូទាត់សងប្រាក់ ។ តាមរយៈប្រព័ន្ធថ្មីនេះ មូលប្បទានប័ត្រនឹងត្រូវបានផាត់ទាត់ជាលក្ខណៈប្រមូលផ្តុំដែលកាន់តែមានប្រសិទ្ធភាពជាងមុន ហើយការទូទាត់ និងផាត់ទាត់ នូវឧបករណ៍ទូទាត់ថ្មីៗទៀតដែលនឹងត្រូវបានបង្កើតឡើងនៅពេលអនាគតក៏អាចធ្វើបាន ។

ក្នុងការអភិវឌ្ឍគម្រោងប្រព័ន្ធជាតិទូទាត់សងប្រាក់ ធនាគារជាតិនៃកម្ពុជាបានរៀបចំឯកសារលទ្ធកម្មសម្រាប់ដេញថ្លៃគម្រោងនេះដោយបានផ្សព្វផ្សាយជាសាធារណៈនៅខែកក្កដា ឆ្នាំ២០១០ និងបានបង្កើតគណៈកម្មការពិនិត្យ និងវាយតម្លៃឯកសារលទ្ធកម្មសម្រាប់អភិវឌ្ឍន៍ប្រព័ន្ធជាតិទូទាត់សងប្រាក់ ក្រុមការងារ

ដាក់ពិន្ទុលើឯកសារដេញថ្លៃ និងក្រុមការងារវាយតម្លៃលើលទ្ធផលនៃការដាក់ពិន្ទុ ។ ក្រុមហ៊ុន ចំនួន ៥ បាន ដាក់ឯកសារចូលរួមដេញថ្លៃផ្គត់ផ្គង់ប្រព័ន្ធ ។ ដំណើរការនៃការដេញថ្លៃនេះដោយគិតចាប់ពីការបើកពិនិត្យ ឯកសារទាំងផ្នែកបច្ចេកទេស និងផ្នែកហិរញ្ញវត្ថុ ការដាក់ពិន្ទុលើការផ្គត់ផ្គង់ប្រព័ន្ធ ការវាយតម្លៃលើលទ្ធផល នៃការដាក់ពិន្ទុនេះ និងការចរចាជាមួយក្រុមហ៊ុនដែលត្រូវបានជ្រើសរើស តាមរយៈលទ្ធផលនៃការដេញថ្លៃ នេះបានប្រព្រឹត្តទៅដោយរលូន និងបានបញ្ចប់តាមការគ្រោងទុក ។

ដោយទទួលបានជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធនាគារជាតិនៃកម្ពុជាបានធ្វើទំនើបកម្ម ប្រតិបត្តិការធនាគាររបស់ខ្លួន ដោយបានដាក់ឲ្យដំណើរការប្រព័ន្ធធនាគារស្នូលដោយជោគជ័យនៅទីស្នាក់ការ កណ្តាល និងកំពុងពង្រីកទៅតាមសាខាទូទាំងប្រទេស ។ តាមរយៈប្រព័ន្ធថ្មីនេះ បានបង្កលក្ខណៈឲ្យ ប្រតិបត្តិការ និងការផ្តល់សេវាកម្មរបស់ធនាគារជាតិនៃកម្ពុជាបានឆាប់រហ័ស និងចូលរួមចំណែកក្នុងការអនុវត្ត កម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកាន់តែមានប្រសិទ្ធភាពខ្ពស់ ។

ទន្ទឹមនឹងការអភិវឌ្ឍប្រព័ន្ធទូទាត់នេះ ធនាគារជាតិនៃកម្ពុជាសហការជាមួយសាជីវកម្មហិរញ្ញវត្ថុ អន្តរជាតិបាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធទូទាត់សងប្រាក់ ដើម្បីសម្រួលដល់ការគ្រប់គ្រង និង ត្រួតពិនិត្យប្រព័ន្ធទូទាត់ផ្សេងៗឲ្យមានសុវត្ថិភាព និងប្រសិទ្ធភាព ។

នៅក្នុងឆ្នាំ២០១០ នេះដែរ ការបង្កើតឡើងនូវសេវាទូទាត់ផ្សេងៗតាមប្រព័ន្ធទូរស័ព្ទចល័តក៏មានការ រីកចម្រើនជាលំដាប់ ។ ក្នុងគោលដៅគ្រប់គ្រង និងសម្រួលដល់ការទូទាត់សងប្រាក់ និងការពារផល- ប្រយោជន៍ដល់អ្នកប្រើប្រាស់សេវាថ្មីនេះ កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០ ធនាគារជាតិនៃកម្ពុជាបាន ចេញប្រកាសចំនួនពីរគឺ ប្រកាសស្តីពីអ្នកដំណើរការតតិយភាគី និងប្រកាសស្តីពីការដាក់ឲ្យប្រើគំរូបញ្ជាទូទាត់ សម្រាប់ការផ្ទេរឥណទាន ។ ប្រកាសស្តីពីអ្នកដំណើរការតតិយភាគី ជាបទប្បញ្ញត្តិថ្មីមួយដើម្បីគ្រប់គ្រងក្រុម ហ៊ុន ឬគ្រឹះស្ថានមិនមែនធនាគាររួមទាំងក្រុមហ៊ុនទូរស័ព្ទចល័ត ដែលមានបំណងធ្វើជាអ្នកដំណើរការតតិយ ភាគីក្នុងការផ្តល់សេវាផ្ទេរប្រាក់ ឬសេវាទូទាត់ផ្សេងៗទៀត ។

## II- ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា

### ១- សកម្មភាពក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជានាពេលបច្ចុប្បន្ន មានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| - ឯកឧត្តម ជា ចាន់តូ | ទេសាភិបាលធនាគារជាតិនៃកម្ពុជា | ជាប្រធាន |
| - លោកជំទាវ នាវ ច័ន្ទថាណា | ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា | ជាសមាជិក |
| - ឯកឧត្តម អូន ព័ន្ធមុន្នីរ័ត្ន | តំណាងប្រមុខរាជរដ្ឋាភិបាល | ជាសមាជិក |
| - ឯកឧត្តម អ៊ីវ ថុង | តំណាងមជ្ឈដ្ឋានឧត្តមសិក្សា | ជាសមាជិក |
| - ឯកឧត្តម ជូ គឹមឡេង | តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| - លោក ឡាយ ម៉េងស៊ុន | តំណាងមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច | ជាសមាជិក |
| - លោកស្រី ម៉ៅ សុន | តំណាងបុគ្គលិកធនាគារជាតិនៃកម្ពុជា | ជាសមាជិក |

ក្នុងឆ្នាំ២០១០ នេះ ក្រុមប្រឹក្សាភិបាលបានប្រជុំចំនួន ៦ លើក ដើម្បីពិភាក្សា និងអនុម័តលើការងារមួយចំនួន ដូចខាងក្រោម ៖

- កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៧៨ នាថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១០ ពិនិត្យ និងអនុម័តលើសេចក្តីព្រាងសេចក្តីសម្រេច ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យបញ្ជីគណនេយ្យធនាគារជាតិនៃកម្ពុជា សម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០០៩ ។
- កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៧៩ នាថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ ពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ស្តីពីស្ថានភាពថវិកាឆ្នាំ២០០៩ និងផែនការឆ្នាំ២០១០ របស់ធនាគារជាតិនៃកម្ពុជា ។
- កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៨០ នាថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១០ ពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១០ របស់ធនាគារជាតិនៃកម្ពុជា ។
- កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៨១នាថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០ ពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ ស្តីពីស្ថានភាពចំណូល-ចំណាយថវិកាឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១០ របស់ធនាគារជាតិនៃកម្ពុជា ។
- កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៨២ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១០ ពិនិត្យ និងអនុម័តប្រកាស ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់អង្គភាពក្រោមឱវាទ ។
- កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី ៨៣ នាថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១០ ពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំ២០១០ និងទិសដៅការងារឆ្នាំ២០១១ ។

## ២- ការអភិវឌ្ឍធនធានមនុស្ស

### ២.១- ស្ថិតិមន្ត្រីបុគ្គលិក

សរុបក្របខ័ណ្ឌមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាទូទាំងប្រទេសក្នុងដំណាច់ឆ្នាំ២០១០ នេះ មានចំនួន ១.២៥៥ រូប (ប្រុស ៧១០ រូប ស្រី ៥៤៥ រូប) ទីស្នាក់ការកណ្តាលចំនួន ៨៦៩ រូប (ប្រុស ៤៨៨ រូប ស្រី ៣៨១ រូប) សាខាធនាគារជាតិនៃកម្ពុជាមានចំនួន ៣៨៦ រូប (ប្រុស ២២២ រូប ស្រី ១៦៤ រូប) ។

បើប្រៀបធៀបជាមួយក្របខ័ណ្ឌក្នុងខែធ្នូ ឆ្នាំ២០០៩ ដែលមានចំនួន ១.២៤៧ រូប (ប្រុស ៧០៣ រូប ស្រី ៥៤៤ រូប) មានការប្រែប្រួលដូចតទៅ ៖

+ ទីស្នាក់ការកណ្តាល គឺកើនចំនួន ២០ រូប (ចូល ៥២ រូប ចេញ ៣២ រូប)
+ សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត គឺថយចុះចំនួន ១២ រូប (ចូល ០៥ រូប ចេញ ១៧ រូប) ។

### ២.២- ការទារបណ្តុះបណ្តាល

ឈរលើស្មារតីលើកកម្ពស់ការកសាងសមត្ថភាពធនធានមនុស្សក្នុងឆ្នាំ២០១០ នេះ ធនាគារជាតិនៃកម្ពុជា បានបើកវគ្គសុក្រឹតការសម្រាប់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាជំនាន់ទី១១ មួយវគ្គ មានមន្ត្រីបុគ្គលិកចូលរួមចំនួន ៨០ រូប ក្នុងនោះ មន្ត្រីបុគ្គលិកទីស្នាក់ការកណ្តាលចំនួន ៣៣ រូប និងមន្ត្រីបុគ្គលិកសាខា

ធនាគារជាតិនៃកម្ពុជាចំនួន ៤៧ រូប ។ នៅក្នុងឆ្នាំ២០១០ នេះដែរ នៅមណ្ឌលសិក្សាបានបំពេញភារកិច្ចក្នុងការបណ្ដុះបណ្ដាលនិស្សិតថ្នាក់ "ប្រកាសនីយបត្រជាន់ខ្ពស់បច្ចេកទេសធនាគារ" សរុបចំនួន ៤២៨ នាក់ (ស្រី ២៤១ នាក់, ប្រុស ១៨៧ នាក់) និស្សិតក្នុងប្រព័ន្ធធនាគារជាតិចំនួន ២២ នាក់ ។ វគ្គបណ្ដុះបណ្ដាលភាសាអង់គ្លេសនៅសាខាធនាគារជាតិនៃកម្ពុជាចំនួន ០២ (ខេត្តកំពង់ធំ និងខេត្តពោធិ៍សាត់) មានមន្ត្រី បុគ្គលិកចូលរួមសរុបចំនួន ២៧ រូប ព្រមទាំងបានរៀបចំសិក្ខាសាលាចំនួន ០៧ លើក នៅធនាគារជាតិនៃកម្ពុជា មានមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាចូលរួមសរុបចំនួន ៤៤៧ រូប ។

ម៉្យាងទៀត ធនាគារជាតិនៃកម្ពុជាក៏បានចាត់បញ្ជូនមន្ត្រីបុគ្គលិកទៅចូលរួមរៀនសូត្ររយៈពេលវែងដូចជា ៖

- វគ្គវិក្រឹតការមន្ត្រីជាន់ខ្ពស់ចំនួន ០១ រូប និងមន្ត្រីមធ្យមចំនួន ០១ រូប នៅសាលាភូមិន្ទរដ្ឋបាល
- សិក្សាភាសាអង់គ្លេសនៅ ACE ចំនួន ១៤ រូប
- វគ្គបណ្ដុះបណ្ដាលនៅមណ្ឌលសិក្សាបច្ចេកទេសធនាគារក្នុងឆ្នាំ២០១០ នេះ មានមន្ត្រីបុគ្គលិកកំពុងសិក្សាសរុបចំនួន ១៣ រូប ក្នុងនោះ ជំនាន់ទី១៩ ចំនួន ០៥ រូប និងជំនាន់ទី ២០ ចំនួន ០៨ រូប ។

ទន្ទឹមនេះដែរ ធនាគារជាតិនៃកម្ពុជាក៏បានចាត់បញ្ជូនមន្ត្រីបុគ្គលិកទៅចូលរួមសិក្ខាសាលា វគ្គបណ្ដុះបណ្ដាល និងកិច្ចប្រជុំផ្សេងៗ តាមការអញ្ជើញពីបណ្ដាក្រសួង-ស្ថាប័ននានា ផងដែរ ដូចជា ៖

- សិក្ខាសាលាចំនួន ០១ លើក ស្ដីពី Financial Vulnerability and Vulnerability Indicators and Early Warning System ( មានមន្ត្រីបុគ្គលិកចូលរួមសរុបចំនួន ១០ រូប នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ )
- វគ្គបណ្ដុះបណ្ដាលចំនួន ០២ លើក ដោយមានមន្ត្រីបុគ្គលិកចូលរួមសរុបចំនួន ០៣ រូប គឺ ៖
  + អ្នកគ្រប់គ្រងធនធានមនុស្សរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដោយមានមន្ត្រីបុគ្គលិកចូលរួមសរុបចំនួន ០២ រូប នៅទីក្រុងភ្នំពេញ
  + ទ្រឹស្ដីទូទៅលើការវាយតម្លៃដីធ្លីបែបជារួម (មន្ត្រីបុគ្គលិកចូលរួម ០១ រូប) នៅសណ្ឋាគារ Nagaworld
- កិច្ចប្រជុំនានា និងពិធីប្រកាសផ្សព្វផ្សាយផ្សេងៗ នៅតាមបណ្ដាអង្គភាព និងស្ថាប័ននានា ចំនួន ១០ លើក (មានមន្ត្រីបុគ្គលិកចូលរួមសរុបចំនួន ១៩ រូប ) ។

ក្រៅពីការបើកវគ្គបណ្ដុះបណ្ដាល និងសិក្ខាសាលាខាងលើនេះ ធនាគារជាតិនៃកម្ពុជាក៏បានរៀបចំត្រៀមប្រឡងឆ្លងចូលក្របខ័ណ្ឌមន្ត្រីក្រមការ ដែលមានមន្ត្រីបុគ្គលិកដាក់ពាក្យចូលរួមប្រឡងចំនួន ១០៦ រូប ផងដែរ ។

ទន្ទឹមនឹងការបណ្ដុះបណ្ដាលក្នុងប្រទេស ធនាគារជាតិនៃកម្ពុជាក៏បានបន្តបង្កើនសមត្ថភាព និងអភិវឌ្ឍន៍ធនធានមនុស្សនៅក្រៅប្រទេស តាមការចាត់បញ្ជូនមន្ត្រីបុគ្គលិកទៅចូលរួមសិក្ខាសាលា ចំនួន ១១៣ លើក (មានមន្ត្រីបុគ្គលិកចូលរួមចំនួន ១៩៨ រូប) ទស្សនកិច្ចសិក្សាចំនួន ០៩ លើក (មានមន្ត្រីបុគ្គលិកចូលរួមចំនួន ២០ រូប) វគ្គសិក្សារយៈពេលខ្លីចំនួន ២២ លើក (មានមន្ត្រីបុគ្គលិកចូលរួម ចំនួន ៤៣ រូប) វគ្គសិក្សារយៈពេលវែងថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ចំនួន ០៩ លើក (មានមន្ត្រីបុគ្គលិកចូលរួមចំនួន ១២ រូប) និងកិច្ចប្រជុំនានាចំនួន ៥៥ លើក (មានមន្ត្រីបុគ្គលិកចូលរួមចំនួន ១៣៦ រូប) តាមការអញ្ជើញ និង

ឧបត្ថម្ភរបស់ប្រទេស និងស្ថាប័នអន្តរជាតិនានា ដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារពិភពលោក ធនាគារកណ្តាលម៉ាឡេស៊ី ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារ Citi Bank រដ្ឋាភិបាលឥណ្ឌា រដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ ធនាគារកូរ៉េ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ធនាគារកណ្តាលលុចហ្សំបួរ អាជ្ញាធររូបិយវត្ថុសឹង្ហបុរី ( MAS) មជ្ឈមណ្ឌល SEACEN រដ្ឋាភិបាលអូស្ត្រាលី រដ្ឋាភិបាលចិន Asia/Pacific Group , សាកលវិទ្យាល័យ NANYANG , Bank for International Settlements , ក្រុមហ៊ុន InterFlex រដ្ឋាភិបាលប៉ាគីស្ថាន ធនាគារកណ្តាលប្រទេសបារាំង ធនាគារកណ្តាលប្រទេសវៀតណាម, International Finance Corporation, ធនាគារកណ្តាលប្រទេសថៃ , ASEAN , Central Banking Publication, ធនាគារកណ្តាលអាល្លឺមង់, Bank of Armenia, Japan Development Scholarship, Hong Kong and Shanghai Banking Corporation (HSBC), និងធនាគារ ANZ Royal ។

## ៣- ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច

នៅក្នុងឆ្នាំ២០១០ នេះ ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងការងារសវនកម្មផ្ទៃក្នុងឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ដោយបានបន្តបំពាក់បំប៉ននូវគោលការណ៍ត្រួតពិនិត្យផ្ទៃក្នុងដល់មន្ត្រីបុគ្គលិកសាខាធនាគារជាតិនៃកម្ពុជាឲ្យកាន់តែយល់ច្បាស់ថែមទៀត ។ ទន្ទឹមនឹងនេះ ការបណ្តុះបណ្តាលត្រូវបានធ្វើឡើងជាបន្តបន្ទាប់ ជាក់ស្តែង មន្ត្រីសវនកម្មបានចុះធ្វើសវនកម្មនៅសាខាធនាគារជាតិនៃកម្ពុជាខេត្តព្រះសីហនុ រតនគីរី កំពង់ចាម កំពង់ធំ សៀមរាប បាត់ដំបង បន្ទាយមានជ័យ និងរាជធានីភ្នំពេញ ព្រមទាំង នាយកដ្ឋានរោងពុម្ព ខុទ្ទកាល័យ និងនាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡា បានបញ្ជូនមន្ត្រីពីររូបទៅហ្វឹកហាត់ការងារសវនកម្មជាក់ស្តែងលើរបាយការណ៍ហិរញ្ញវត្ថុនៅប្រទេសលុចហ្សំបួរ រយៈពេលពីរខែ ។

មន្ត្រីសវនកម្មក៏បានចុះប្រមូលព័ត៌មានលើប្រតិបត្តិការមួយចំនួនក្នុងនាយកដ្ឋាននៅទីស្នាក់ការកណ្តាល ដែលទាក់ទងទៅនឹងដំណើរការប្រព័ន្ធធនាគារស្នូលនៅធនាគារជាតិនៃកម្ពុជា ដើម្បីពិនិត្យពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ប្រតិបត្តិការនីមួយៗឲ្យបានល្អប្រសើរ ។ បន្ទាប់ពីការធ្វើសវនកម្ម សេចក្តីព្រាងរបាយការណ៍ដែលរួមមានចំណុចរកឃើញ និងអនុសាសន៍មួយចំនួនផង ត្រូវបានដាក់ចេញដើម្បីផ្ញើជូនថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ។

ក្រៅពីការចុះធ្វើសវនកម្ម មន្ត្រីសវនកម្មបានចុះតាមដានការអនុវត្តតាមអនុសាសន៍ ដែលបានដាក់ចុះនៅតាមសាខាធនាគារជាតិនៃកម្ពុជាជាប្រចាំ ។

ចំពោះការងារអធិការកិច្ចវិញបានដំណើរការតាមរយៈការចុះឆ្មក់ត្រួតពិនិត្យ ដោយមិនជូនដំណឹងមុនលើសាខាធនាគារជាតិនៃកម្ពុជាចំនួន ១៦ ដែលការចុះត្រួតពិនិត្យបានផ្តោតជាសំខាន់លើការងារធានាសុវត្ថិភាពឃ្លាំងប្រាក់ ការងារគ្រប់គ្រងសាច់ប្រាក់ និងការអនុវត្តរាល់សេចក្តីណែនាំរបស់នាយកដ្ឋានជំនាញដែលបានដាក់ចុះ ព្រមទាំងពង្រឹងគុណវុឌ្ឍិ និងវិន័យការងារមន្ត្រីបុគ្គលិកនៅតាមសាខាឲ្យបានកាន់តែប្រសើរ ។

ទន្ទឹមនឹងនេះ ការត្រួតពិនិត្យលើឯកសារក៏បានដំណើរការជាប្រចាំ តាមរយៈរបាយការណ៍ប្រចាំខែរបស់បណ្តានាយកដ្ឋាននៅទីស្នាក់ការកណ្តាល និងនៅសាខាធនាគារជាតិនៃកម្ពុជា ដោយបានពិនិត្យឡើង

វិញអំពីការអនុវត្តតាមមុខងារភារកិច្ច និងផ្ទៀងផ្ទាត់នូវទិន្នន័យរបស់បណ្តាអង្គភាពពាក់ព័ន្ធ ដើម្បីរកឲ្យឃើញនូវភាពត្រឹមត្រូវប្រាកដប្រជា ។

### ៤- ការងារគ្រប់គ្រងសាខាធនាគារជាតិនៃកម្ពុជា

ធនាគាជាតិនៃកម្ពុជា បានកំពុងបន្តពង្រឹងប្រតិបត្តិការរបស់ខ្លួនជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងកិច្ចសហប្រតិបត្តិការតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលជំហានទី២ឲ្យកាន់តែមានប្រសិទ្ធភាព និងបានដាក់ឲ្យអនុវត្តកម្មវិធីប្រព័ន្ធធនាគារស្នូល (CBS) បានចំនួន ៨ សាខារាជធានី-ខេត្ត រួមមាន រាជធានីភ្នំពេញ កំពង់ចាម បាត់ដំបង សៀមរាប ស្វាយរៀង កំពង់ឆ្នាំង ព្រះសីហនុ បន្ទាយមានជ័យ និងបន្តដាក់ប្រព័ន្ធធនាគារស្នូលនៅតាមសាខាផ្សេងទៀត ព្រមទាំងបានបណ្តុះបណ្តាល និងផ្គត់ផ្គង់ធនធានមនុស្សដើម្បីអនុវត្តភារកិច្ចនេះ ។ ដោយឡែក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាននឹងកំពុងបន្តសាកល្បងជំហានទី១ លើការគ្រប់គ្រងចំណូល-ចំណាយថវិការដ្ឋចំពោះខេត្តពីរ គឺខេត្តកណ្តាល និងខេត្តបន្ទាយមានជ័យ ដែលតម្រូវឲ្យរតនាគារខេត្តទាំងពីរ បើកគណនីប្រតិបត្តិការចំណូល-ចំណាយថវិការដ្ឋនៅធនាគារអេស៊ីលីដា ទន្ទឹមនឹងនេះ ក៏បានសាកល្បងជំហានទី២ ផងដែរ គឺធនាគារអេស៊ីលីដាបន្តធ្វើប្រតិបត្តិការចំណូល-ចំណាយថវិការរដ្ឋជាមួយរតនាគារខេត្តកំពង់ចាម មណ្ឌលគិរី ស្ទឹងត្រែង កោះកុង ព្រះវិហារ ឧត្តរមានជ័យ និងធនាគារកាណាឌីយ៉ា ជាមួយរតនាគារខេត្តសៀមរាប បាត់ដំបង និងព្រះសីហនុ ។

## III- ទំនាក់ទំនងអន្តរជាតិ

### ១- ទំនាក់ទំនងពហុភាគី

#### ១.១- ទំនាក់ទំនងជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ

ធនាគារជាតិនៃកម្ពុជាមានទំនាក់ទំនងជាមួយភាគីអន្តរជាតិជាច្រើន ដែលក្នុងនោះ មូលនិធិរូបិយវត្ថុអន្តរជាតិគឺជាដៃគូដ៏សំខាន់មួយដែលតែងតែអញ្ជើញមកបំពេញបេសកកម្មជារៀងរាល់ឆ្នាំ ។ នៅថ្ងៃទី៩-៣០ ខែមីនា ឆ្នាំ២០១០ នេះ តំណាងមូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក បានអញ្ជើញមកបំពេញបេសកកម្ម " កម្មវិធីវាយតម្លៃលើវិស័យហិរញ្ញវត្ថុ " (Financial Sector Assessment Programme: FSAP) ដើម្បីធ្វើការវាយតម្លៃលើស្ថានភាពបច្ចុប្បន្ននៃវិស័យហិរញ្ញវត្ថុ រួមទាំងក្របខ័ណ្ឌបទប្បញ្ញត្តិ ។ ជារួម ការវាយតម្លៃរបស់ FSAP បានឆ្លុះបញ្ចាំងនូវស្ថានភាពកំពុងអភិវឌ្ឍជាបណ្តើរៗរបស់វិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា ហើយអនុសាសន៍មួយចំនួនត្រូវបានលើកឡើងសំដៅពង្រឹងស្ថិរភាពវិស័យហិរញ្ញវត្ថុ លើកកម្ពស់ការត្រួតពិនិត្យនិងបញ្ញត្តិកម្ម បង្កើនការផ្តល់សេវាហិរញ្ញវត្ថុដល់ប្រជាជនទូទៅ និងបង្កើតក្របខ័ណ្ឌសម្រាប់គ្រប់គ្រងស្ថានភាពវិបត្តិហិរញ្ញវត្ថុ ជាដើម ។

ក្នុងពេលជាមួយគ្នានោះដែរ មូលនិធិរូបិយវត្ថុអន្តរជាតិក៏បានលើកឡើងពីសារៈសំខាន់នៃការរៀបចំសូចនាករភាពរឹងមាំនៃវិស័យហិរញ្ញវត្ថុ (Financial Soundness Indicators) ការធ្វើតេស្តរកសញ្ញាហានិភ័យ (Stress Testing) និងវិធីសាស្ត្រត្រួតពិនិត្យដោយផ្អែកលើហានិភ័យ (Risk Based Examination) ផងដែរ ។

ទន្ទឹមនោះដែរ នៅក្នុងឆមាសទីពីរនៃឆ្នាំនេះ តំណាងមូលនិធិរូបិយវត្ថុអន្តរជាតិក៏បានអនុវត្តបេសកកម្មមាត្រាទី IV នៅប្រទេសកម្ពុជា ដែលចាប់ផ្តើមពីថ្ងៃទី៣០ ខែសីហា ដល់ ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១០ ។ បេសកកម្មខាងលើនេះ បានវាយតម្លៃជារួមលើស្ថានភាពសេដ្ឋកិច្ច/ហិរញ្ញវត្ថុថា កម្ពុជាងើបចេញផុតពីផលវិបាកនៃវិបត្តិសកលលោកដោយសន្ទុះរឹងមាំសមរម្យមួយ ហើយសេដ្ឋកិច្ចអាចមានកំណើន ៤,៥% - ៥% នៅឆ្នាំ២០១០ ដោយសារកំណើនវិស័យនាំចេញ និងទេសចរណ៍ ។ ប៉ុន្តែ ឧបសគ្គ និងហានិភ័យរបស់កម្ពុជា គឺមូលដ្ឋានកំណើនសេដ្ឋកិច្ចនៅតូច ប្រព័ន្ធហិរញ្ញវត្ថុទន់ខ្សោយ កម្រិតដុល្លារូបនីយកម្មខ្ពស់ និងលទ្ធភាពវិស័យសារពើពន្ធមានកម្រិត ។ លើសពីនេះ បេសកកម្មបានផ្តល់អនុសាសន៍ល្អៗមួយចំនួនដែរលើវិស័យសារពើពន្ធ គោលនយោបាយរូបិយវត្ថុនិងអត្រាប្តូរប្រាក់ និងវិស័យត្រួតពិនិត្យ ។

### ១.២- ទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី

នៅឆ្នាំ២០១០ នេះ នៅក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយធនាគារអភិវឌ្ឍន៍អាស៊ីលើកម្មវិធីការងារនៃផែនការ **"យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥"** ធនាគារជាតិនៃកម្ពុជាដែលជាភ្នាក់ងារប្រតិបត្តិគម្រោង រួមជាមួយបណ្តាក្រសួងពាក់ព័ន្ធនានាបានបន្តអនុវត្តកំណែទម្រង់នៅក្នុងកម្មវិធីឥណទានអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុទី២ (FSPL II) ។ កម្មវិធីឥណទាននេះមានទឹកប្រាក់ ៤០ លានដុល្លារអាមេរិក និងត្រូវបានបែងចែកជា ៤ អនុកម្មវិធី ដែលអនុវត្តចាប់ពីខែកញ្ញា ឆ្នាំ២០០៦ ដល់ខែធ្នូ ឆ្នាំ២០១០ ។ អនុកម្មវិធីនីមួយៗ ក្រសោបនូវកំណែទម្រង់លើផ្នែកសំខាន់ៗនៃវិស័យធនាគារនិងហិរញ្ញវត្ថុដែលត្រូវអនុវត្តជាដំណាក់កាលៗ ។ កន្លងមក រាជរដ្ឋាភិបាលកម្ពុជាបានទទួលការបើកផ្តល់ឥណទានចំនួន ៣ ដង រួចមកហើយ ដែលមានទឹកប្រាក់សរុបចំនួន ៣០ លានដុល្លារអាមេរិក បន្ទាប់ពីបានបំពេញចប់នូវកំណែទម្រង់មួយចំនួននៅក្នុងអនុកម្មវិធីទី១ ទី២ និងទី៣ ។ កាលពីថ្ងៃទី៥ ខែតុលា ឆ្នាំ២០១០ ថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាដែលមានធនាគារជាតិនៃកម្ពុជាជាតំណាង បានចុះហត្ថលេខាជាមួយធនាគារអភិវឌ្ឍន៍អាស៊ីលើកំណត់ហេតុនៃកិច្ចចរចាឥណទាន និងជំនួយឥតសំណងនៅទីក្រុងម៉ានីឡា ប្រទេសហ្វីលីពីន ដោយធនាគាអភិវឌ្ឍន៍អាស៊ីសន្យាផ្តល់ឥណទានចំនួន ១៥ លានដុល្លារអាមេរិក សម្រាប់ការងារកំណែទម្រង់នៅក្នុងអនុកម្មវិធីទី៤ ដែលក្នុងនោះ ១០ លានដុល្លារអាមេរិក ជាប្រាក់កម្ចីមានអត្រាការប្រាក់ ១,៥% ក្នុងមួយឆ្នាំ និង ៥ លានដុល្លារអាមេរិកទៀតជាជំនួយឥតសំណងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។

កំណែទម្រង់នៃអនុកម្មវិធីទី៤ បានផ្តោតលើការងារ ដូចជា ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ ការកែប្រែប្រព័ន្ធចែករំលែកព័ត៌មានឥណទានឲ្យទៅជាការិយាល័យឥណទាន ការជំរុញការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ ការធ្វើវិសោធនកម្មច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងការលើកកម្ពស់ប្រតិបត្តិការរបស់គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ ជាដើម ។

ទន្ទឹមនឹងនោះ ដោយមានជំនួយឧបត្ថម្ភពីធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងគណៈកម្មការមូលប័ត្រកម្ពុជា បានឯកភាពផ្តួចផ្តើមធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ ឲ្យទៅជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួល និងការវិវត្តសេដ្ឋកិច្ចកម្ពុជានាពេលបច្ចុប្បន្ន

និងតម្រូវការនាអនាគត ។ លើសពីនេះទៀត ក្រុមការងារបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ីកំពុងសិក្សាដើម្បីរៀបចំសំណុំកម្មវិធីឥណទានអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុទី៣ (FSPL III) សម្រាប់ឆ្នាំ ២០១១ តទៅទៀត ។

### ១.៣- ទំនាក់ទំនងជាមួយអាស៊ាន

#### ១.៣.១- សហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន

ក្នុងកិច្ចសហប្រតិបត្តិការអាស៊ាន ធនាគារជាតិនៃកម្ពុជាបន្តគាំទ្រការប្តេជ្ញាក្នុងតំបន់ ចូលរួមយ៉ាងយកចិត្តទុកដាក់ និងជាប្រចាំក្នុងកិច្ចប្រជុំថ្នាក់នយោបាយ និងបច្ចេកទេសសំខាន់ៗ ។ គណៈប្រតិភូជាន់ខ្ពស់នៃធនាគារជាតិនៃកម្ពុជាបានចូលរួមកិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ានលើកទី៦ កិច្ចប្រជុំថ្នាក់ទេសាភិបាលរងធនាគារកណ្តាលនិងហិរញ្ញវត្ថុរបស់អាស៊ានលើកទី១៨ និងកិច្ចប្រជុំពាក់ព័ន្ធផ្សេងៗទៀត ក្រោមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការក្នុងចំណោមអាស៊ាន១០ ព្រមទាំងអាស៊ាន+៣ (ចិន ជប៉ុន និងកូរ៉េ) ដែលបានរៀបចំឡើងនៅថ្ងៃទី៤-៨ ខែមេសា ឆ្នាំ២០១០ នៅប្រទេសវៀតណាម ។ ជាលទ្ធផលនៃកិច្ចប្រជុំចង្អុលទិសសំខាន់ៗ ការខិតខំប្រឹងប្រែងផ្សេងៗត្រូវបានធ្វើឡើងដើម្បីសម្រេចបាននូវសមាហរណកម្មលើវិស័យចម្បងបី រួមមាន ការអភិវឌ្ឍទីផ្សារទុន សេរីភាវូបនីយកម្មគណនីដើមទុន និងសេរីភាវូបនីយកម្មវិស័យហិរញ្ញវត្ថុ ។

ទន្ទឹមនោះ ការចរចាជុំទី៥នៃការបើកចំហវិស័យហិរញ្ញវត្ថុក៏បានចាប់ផ្តើមឡើងដែរ ហើយគ្រោងនឹងបញ្ចប់នាដំណាច់ឆ្នាំនេះ ។

លើសពីនេះ អាស៊ានកំពុងរៀបចំ "ផែនការយុទ្ធសាស្ត្ររយៈកាល ១០ឆ្នាំ សម្រាប់សមាហរណកម្មអាស៊ាន ២០១១-២០២០" លើវិស័យហិរញ្ញវត្ថុ រួមទាំងប្រព័ន្ធទូទាត់ក្នុងតំបន់ ផងដែរ ។ ផែនការយុទ្ធសាស្ត្រនេះ រំពឹងថានឹងធ្វើការអនុម័តនៅខែមេសា ឆ្នាំ២០១១ ខាងមុខ ។

#### ១.៣.២- សហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន+៣

នៅក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការអាស៊ាន+៣ ការបង្កើតមូលនិធិរួមក្នុងតំបន់ ហៅថា "ពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ (CMIM)" ដែលជាកិច្ចសម្របសម្រួលស្វប់ពហុភាគីរវាងប្រទេសអាស៊ាន+៣ និងអាជ្ញាធររូបិយវត្ថុហុងកុង មានវឌ្ឍនភាពជាច្រើន ។ មកទល់បច្ចុប្បន្ននេះ "កិច្ចព្រមព្រៀងពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ" បានចូលជាធរមានរួចរាល់ហើយសម្រាប់ប្រទេសអាស៊ាន+៣ និងអាជ្ញាធររូបិយវត្ថុហុងកុង និងបានប្រកាសជាផ្លូវការនៅក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីហិរញ្ញវត្ថុនៅទីក្រុងតាស្សកិនកាលពីដើមខែឧសភា ឆ្នាំ២០១០ កន្លងមកនេះ ។ ការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (AMRO) ដែលជាសេនាធិការសំខាន់នៃ CMIM នេះ មានទីតាំងនៅប្រទេសសឹង្ហបុរី ។

បន្ថែមលើកិច្ចខិតខំខាងលើនេះ ប្រទេសអាស៊ាន+៣ ក៏បានប្រឹងប្រែងផងដែរ ឆ្ពោះទៅអនុវត្តគំនិតផ្តួចផ្តើមទីផ្សារសញ្ញាប័ណ្ណអាស៊ាន ។ គំនិតផ្តួចផ្តើមនេះ មានគោលដៅអភិវឌ្ឍន៍និងពង្រឹងរូបិយវត្ថុ និងទីផ្សារ

សញ្ញាប័ណ្ណក្នុងតំបន់ ដើម្បីអនុញ្ញាតឲ្យមានការប្រើប្រាស់សញ្ញ័យរបស់ប្រទេសអាស៊ីផ្ទាល់ ។ ដើម្បីសម្រេចនូវគោលដៅនោះ ប្រទេសអាស៊ានរួមជាមួយនឹងធនាគារអភិវឌ្ឍន៍អាស៊ីបានបង្កើតនូវ **"យន្តការធានាលើឥណទាននិងវិនិយោគ"** ក្នុងគោលបំណងបង្កើនការផ្តល់ឥណទានព្រមទាំងជំរុញការធ្វើវិនិយោគតាមរយៈការផ្តល់លទ្ធភាពចំពោះវិស័យឯកជនណាដែលមានគុណវុឌ្ឍិឲ្យអាចបោះផ្សាយមូលប័ត្រនៅលើទីផ្សារសញ្ញាប័ណ្ណជារូបិយវត្ថុតំបន់ ហើយដូចនេះ អាចជៀសវាងបាននូវអតុល្យភាពរូបិយវត្ថុ និងឥណប្រតិទាន តាមរយៈការបោះផ្សាយនៅក្នុងតំបន់ ។ ខ្លឹមសារនៃកិច្ចព្រមព្រៀងបង្កើតយន្តការនេះបានឯកភាព និងប្រកាសជាផ្លូវការរួចហើយនៅក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីហិរញ្ញវត្ថុនៅទីក្រុងតាស្សកិន ខែឧសភា ឆ្នាំ២០១០ កន្លងមកនេះ ដែលរំពឹងថានឹងចុះហត្ថលេខាឆាប់ៗខាងមុខនេះ ។

### ១.៤- ទំនាក់ទំនងជាមួយមជ្ឈមណ្ឌលធនាគារកណ្តាលអាស៊ីអាគ្នេយ៍ (**ស៊ាសិន** - SEACEN)

សមាជិកភាពរបស់ធនាគារជាតិនៃកម្ពុជានៅក្នុងមជ្ឈមណ្ឌលស៊ាសិន (SEACEN) បានផ្តល់ឱកាសជាច្រើនចំពោះធនាគារជាតិនៃកម្ពុជាក្នុងការបណ្តុះបណ្តាលធនធានមនុស្ស និងការស្រាវជ្រាវលើវិស័យហិរញ្ញវត្ថុនិងធនាគារ ក្នុងគោលបំណងបង្កើនប្រសិទ្ធភាព និងជំនឿទុកចិត្តលើប្រតិបត្តិការនៃធនាគារកណ្តាលជាសមាជិកក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ និងពង្រឹងវិស័យធនាគារ ។

ដើម្បីពង្រឹងនូវកិច្ចសហប្រតិបត្តិការជាមួយបណ្តាសមាជិកនៃមជ្ឈមណ្ឌលស៊ាសិន ធនាគារជាតិនៃកម្ពុជា មានកិត្តិយសទទួលធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំសន្និសីទថ្នាក់ទេសាភិបាលលើកទី៤៥ និងកិច្ចប្រជុំក្រុមប្រឹក្សាទេសាភិបាល លើកទី២៩ កាលពីថ្ងៃទី២៦-២៧ ខែកុម្ភៈ ឆ្នាំ២០១០ នៅខេត្តសៀមរាប ក្រោមប្រធានបទ ស្តីពី "តួនាទីរបស់ធនាគារកណ្តាលក្នុងការស្តារសេដ្ឋកិច្ចឡើងវិញប្រកបដោយចីរភាពក្រោយពេលមានវិបត្តិ និងការសម្រេចបាននូវស្ថិរភាពហិរញ្ញវត្ថុ" ។

ជាមួយគ្នានេះដែរ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយមជ្ឈមណ្ឌលស៊ាសិនរៀបចំសិក្ខាសាលាពីរ ស្តីពី "គោលការណ៍គ្រឹះនៃការគ្រប់គ្រងទ្រព្យសកម្ម/បំណុល" កាលពីថ្ងៃទី២-៧ ខែឧសភា ឆ្នាំ២០១០ និងស្តីពី "ការគ្រប់គ្រងហានិភ័យរបស់ធនាគារកណ្តាល" កាលពីថ្ងៃទី១-៦ ខែសីហា ឆ្នាំ២០១០ នៅខេត្តសៀមរាប ។

ធនាគារជាតិនៃកម្ពុជាក៏បានបញ្ជូនមន្ត្រីជាបន្តបន្ទាប់ឲ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំសំខាន់ៗនានានៅក្នុងក្របខ័ណ្ឌសហប្រតិបត្តិការស៊ាសិន ដែលបានប្រព្រឹត្តទៅនៅបណ្តាប្រទេសសមាជិកស៊ាសិន ផងដែរ ។

លើសពីនេះទៀត នាពេលបច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាកំពុងត្រៀមរៀបចំទទួលធ្វើជាម្ចាស់ផ្ទះក្នុងកិច្ចប្រជុំគណៈកម្មការប្រតិបត្តិនៃមជ្ឈមណ្ឌលស៊ាសិន (EXCO) លើកទី៩ ដែលនឹងធ្វើឡើងនៅថ្ងៃទី១៩ ដល់ថ្ងៃទី ២១ ខែមករា ឆ្នាំ២០១១ ខាងមុខនេះ ។

### ១.៥- ទំនាក់ទំនងជាមួយសមាគមធនាគារកណ្តាលនៃបណ្តាប្រទេសនិយាយភាសា

**បារាំង** ( Francophone: **ហ្វ្រង់កូហ្វូន** )

សមាគមធនាគារកណ្តាលនៃបណ្តាប្រទេសនិយាយភាសាបារាំង (ហ្វ្រង់កូហ្វូន) បានបង្កើតឡើងតាមគំនិតផ្តួចផ្តើមរបស់ធនាគារកណ្តាលបារាំង និងមានធនាគារកណ្តាលចំនួន ៥៤ ប្រទេសជាសមាជិក ។ ធនាគារជាតិនៃកម្ពុជាបានចូលជាសមាជិកនៃសមាគមនេះតាំងពីឆ្នាំ១៩៩៣ និងបានរក្សាសមាជិកភាពនោះមកទល់បច្ចុប្បន្ន ក្នុងគោលបំណងពង្រឹងទំនាក់ទំនង ផ្លាស់ប្តូរបទពិសោធន៍និងព័ត៌មានទៅវិញទៅមក និងស្វែងរកការជួយឧបត្ថម្ភពីសំណាក់ធនាគារកណ្តាលជាដៃគូ ជាពិសេស លើវិស័យបណ្តុះបណ្តាលធនធានមនុស្ស និងទំនាក់ទំនងធនាគារ ។ កន្លងមក ថ្នាក់ដឹកនាំជាន់ខ្ពស់នៃធនាគារជាតិនៃកម្ពុជា តែងចូលរួមជាប្រចាំនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់សមាគមហ្វ្រង់កូហ្វូន ដែលនៅក្នុងឱកាសនោះ ធនាគារជាតិនៃកម្ពុជាតែងត្រូវបានអញ្ជើញឲ្យធ្វើបទអន្តរាគមន៍លើប្រធានបទនានាពាក់ព័ន្ធនឹងគោលនយោបាយរូបិយវត្ថុ ការគ្រប់គ្រងប្រព័ន្ធធនាគារ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ជាដើម ។

នៅក្នុងកិច្ចប្រជុំលើកទី១៧ កាលពីថ្ងៃទី១២-១៥ ខែឧសភា ឆ្នាំ២០១០ នៅទីក្រុងម៉ុងត្រេអាល ប្រទេសកាណាដា ប្រទេសជាសមាជិកហ្វ្រង់កូហ្វូនបានផ្តល់កិត្តិយសជូនធនាគារជាតិនៃកម្ពុជាឲ្យធ្វើជាម្ចាស់ផ្ទះសម្រាប់កិច្ចប្រជុំលើកទី១៨ ដែលគ្រោងនឹងប្រព្រឹត្តទៅនៅថ្ងៃទី១១-១៣ ខែឧសភា ឆ្នាំ២០១១ នាខេត្តសៀមរាប ។

## ២- ទំនាក់ទំនងទ្វេភាគី

ទន្ទឹមនឹងកិច្ចសហប្រតិបត្តិការជាពហុភាគី ធនាគារជាតិនៃកម្ពុជាក៏បានបង្កើនកិច្ចសហការជាទ្វេភាគីដ៏ជិតស្និទ្ធបន្ថែមទៀត ជាមួយបណ្តាធនាគារកណ្តាល និងស្ថាប័នអន្តរជាតិមួយចំនួន តាមរយៈការសិក្សាអង្កេតរួមគ្នា ការផ្លាស់ប្តូរព័ត៌មាន និងការបណ្តុះបណ្តាលមន្ត្រី ជាដើម ។

កិច្ចសហប្រតិបត្តិការជាមួយនឹងធនាគារកណ្តាលកូរ៉េក៏ត្រូវបានពង្រឹងថែមទៀត តាមរយៈដំណើរទស្សនកិច្ចរបស់ឯកឧត្តមទេសាភិបាលធនាគារជាតិនៃកម្ពុជា នាទីក្រុងសេអ៊ូល កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០ ដើម្បីចូលរួមអបអរសាទរខួបលើកទី ៦០ ឆ្នាំ របស់ធនាគារកណ្តាលកូរ៉េ ។ បច្ចុប្បន្ន មានមន្ត្រីជំនាញធនាគារកណ្តាលកូរ៉េពីររូបកំពុងជួយផ្នែកប្រព័ន្ធទូទាត់ ។

កាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១០ កិច្ចប្រជុំទ្វេភាគីរវាងធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលថៃ បានរៀបចំឡើងនៅទីក្រុងសៀមរាប ក្នុងគោលបំណងរឹតចំណងសាមគ្គីភាព និងបន្តកិច្ចសហប្រតិបត្តិការដែលមានកន្លងមក តាមរូបភាពជាការផ្លាស់ប្តូរបទពិសោធន៍ក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ និងការអភិវឌ្ឍធនធានមនុស្ស ។ ក្នុងឆ្នាំ២០១០ នេះដែរ ធនាគារជាតិនៃកម្ពុជាបានបញ្ជូនមន្ត្រីចំនួនពីររូបទៅទទួលការបណ្តុះបណ្តាលនៅធនាគារកណ្តាលថៃ ស្តីអំពីការត្រួតពិនិត្យធនាគារពាណិជ្ជ ។ ដោយឡែក ធនាគារកណ្តាលថៃក៏បានបញ្ជូនមន្ត្រីជំនាញរបស់ខ្លួនមកជួយការបណ្តុះបណ្តាលនៅធនាគារជាតិនៃកម្ពុជាចំនួនពីរលើកដែរ ស្តីពី ការគ្រប់គ្រងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងរូបិយវត្ថុ និងប្រព័ន្ធទូទាត់ និងផាត់ទាត់ ។

កាលពីថ្ងៃទី៦-៨ ខែសីហា ឆ្នាំ២០១០ កិច្ចប្រជុំទ្វេភាគីជាលើកដំបូងរវាងធនាគារជាតិនៃកម្ពុជា និង ធនាគារកណ្តាលម៉ាឡេស៊ី បានធ្វើឡើងនៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ក្នុងគោលដៅបង្កើនចំណង មិត្តភាព និងកិច្ចសហប្រតិបត្តិការលើវិស័យធនាគារនិងហិរញ្ញវត្ថុ និងជួយពង្រឹងវិស័យធនធានមនុស្ស តាមរយៈការបណ្តុះបណ្តាលដល់មន្ត្រីធនាគារជាតិនៃកម្ពុជា ។ នៅក្នុងអំឡុងកិច្ចប្រជុំនោះ ស្ថាប័នទាំងពីរ បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីអំពីកិច្ចសហប្រតិបត្តិការទ្វេភាគី និងការត្រួតពិនិត្យធនាគារ ឆ្លងដែន ។

ចំពោះកិច្ចសហប្រតិបត្តិការជាមួយធនាគាររដ្ឋវៀតណាម កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០ នាឱ កាសទស្សនកិច្ចនៃនាយករដ្ឋមន្ត្រីវៀតណាមនៅកម្ពុជា ធនាគារជាតិនៃកម្ពុជា និងធនាគាររដ្ឋវៀតណាម បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីពី ការធ្វើបច្ចុប្បន្នកម្មកិច្ចព្រមព្រៀងប្រព័ន្ធទូទាត់ឆ្លងដែនរវាង ប្រទេសទាំងពីរ ។

ក្នុងឆ្នាំ២០១០ នេះដែរ អាជ្ញាធររូបិយវត្ថុសឹង្ហបុរីក៏បានផ្តល់ជំនួយបច្ចេកទេសទ្វេភាគីដល់ធនាគារ ជាតិនៃកម្ពុជាដែរ ក្រោមរូបភាពជាទស្សនកិច្ចសិក្សាលើផ្នែកត្រួតពិនិត្យ ប្រព័ន្ធទូទាត់ និងការវិភាគស្ថិរភាព ម៉ាក្រូហិរញ្ញវត្ថុ ។

ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាលឡាវបន្ថែមទៀត កិច្ចប្រជុំទ្វេភាគីដែល ដឹកនាំដោយប្រតិភូជាន់ខ្ពស់រវាងធនាគារកណ្តាលទាំងពីរត្រូវបានធ្វើឡើងកាលពីថ្ងៃទី៣-៦ ខែធ្នូ ឆ្នាំ២០១០ នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ ក្នុងគោលបំណងពិនិត្យលើការអនុវត្តអនុស្សរណៈយោគយល់ និងការផ្លាស់ ប្តូរបទពិសោធន៍លើការងារមួយចំនួន ។

សម្រាប់ឆ្នាំ២០១០ នេះ ធនាគារកណ្តាលលុចហ្សំបួរ បានបន្តផ្តល់ជំនួយផ្នែកបណ្តុះបណ្តាលធនធាន មនុស្សតាមរយៈការផ្តល់អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងផ្តល់វគ្គបណ្តុះបណ្តាលរយៈពេលខ្លីលើ ប្រធានបទស្តីពីសវនកម្មផ្ទៃក្នុងដល់មន្ត្រីធនាគារជាតិនៃកម្ពុជា ។

## សន្និដ្ឋាន

ក្នុងខណៈដែលកំណើនសេដ្ឋកិច្ចពិភពលោកបានបង្ហាញសញ្ញាងើបឡើងវិញពីវិបត្តិ ការងើបឡើងវិញនេះ នៅមានលក្ខណៈមិនស្មើតាមតំបន់ និងមិនទាន់មានភាពរឹងមាំនៅឡើយ ។ កំណើនភាគច្រើននៅពឹងផ្អែកលើវិធានការវិត្ថារកម្មសារពើពន្ធ ដោយសារតម្រូវការរបស់វិស័យឯកជននៅទន់ខ្សោយ ហើយអត្រានិកម្មភាពនៅខ្ពស់នៅឡើយ ។ គោលនយោបាយរូបិយវត្ថុរបស់ប្រទេសជាច្រើន ជាពិសេស ប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើនត្រូវបានអនុវត្តក្នុងគោលដៅទ្រទ្រង់យ៉ាងសកម្ម ដោយបន្ថយអត្រាការប្រាក់ដល់កម្រិតទាបដែលមិនធ្លាប់មានពីមុនមក ។

ប្រទេសកម្ពុជាបានងើបចេញពីការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោកក្នុងល្បឿនមួយដ៏រឹងប៉ឹង ហើយបច្ចុប្បន្នកំពុងស្ថិតលើវិថីនៃភាពរីកចម្រើនទៅមុខ ។ កំណើនសេដ្ឋកិច្ចកំពុងមានល្បឿនជាបន្ត អតិផរណាមានកម្រិតអាចគ្រប់គ្រងបាន អត្រាប្តូរប្រាក់មានស្ថិរភាពល្អ ឯទុនបម្រុងអន្តរជាតិក៏កំពុងត្រូវបានបន្តគរពូន ។ ជាងមួយទសវត្សរ៍នៃកំណែទម្រង់រចនាសម្ព័ន្ធ ប្រព័ន្ធហិរញ្ញវត្ថុរឹងមាំនិងមានស្ថិរភាព ព្រមទាំងគោលនយោបាយវិត្ថារកម្មដែលបានដាក់ចេញទាន់ពេលវេលា និងចំគោលដៅ គឺជាកម្លាំងចលករផ្តល់ការទ្រទ្រង់យ៉ាងសំខាន់ចំពោះសេដ្ឋកិច្ចកម្ពុជា ។

ប៉ុន្តែ នៅមានកិច្ចការជាច្រើនទៀតដែលត្រូវធ្វើ និងស្ថិតក្រោមការយកចិត្តទុកដាក់និងប្រុងប្រយ័ត្ននៅឡើយ ដើម្បីបង្កើតកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព រក្សាស្ថិរភាពថ្លៃ និងកសាងសមត្ថភាពស្ថាប័ន ។ ទម្រាំខឿនសេដ្ឋកិច្ចត្រូវបានពង្រីក ទស្សនវិស័យចំពោះកំណើនរយៈកាលខ្លីរបស់កម្ពុជា នឹងនៅតែពឹងផ្អែកលើសន្ទុះនៃការងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោក និងវិនិយោគបរទេស ។ ទន្ទឹមនេះ គោលនយោបាយរូបិយវត្ថុត្រូវពិចារណាលើតុល្យភាពរវាងសម្ពាធអតិផរណា និងតម្រូវការក្នុងការជំរុញសកម្មភាពសេដ្ឋកិច្ច ។

ផ្អែកលើមូលដ្ឋាននៃយុទ្ធសាស្ត្រដ៏ទូលំទូលាយក្នុងការអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា នឹងបន្តបោះជំហានទៅមុខដោយការកសាងក្របខ័ណ្ឌគតិយុត្តិ-ស្ថាប័ន និងហេដ្ឋារចនាសម្ព័ន្ធ ដើម្បីឲ្យប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុដើរតួនាទីយ៉ាងមានប្រសិទ្ធភាព ខណៈផ្តោតការយកចិត្តទុកដាក់ផងដែរទៅលើការអភិវឌ្ឍសមត្ថភាពធនធានមនុស្សក្នុងវិស័យនេះ ។ លើសពីនេះទៅទៀត ធនាគារជាតិនៃកម្ពុជានឹងបន្តពង្រឹងបទប្បញ្ញត្តិ និងការត្រួតពិនិត្យចំពោះវិស័យហិរញ្ញវត្ថុ ។ ការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពលើទីផ្សារហិរញ្ញវត្ថុ ទាមទារនូវវត្តមាននៃគោលនយោបាយ និងដំណើរការគ្រប់គ្រងហានិភ័យសមស្របក្នុងគោលបំណងធានាថា គ្រឹះស្ថានហិរញ្ញវត្ថុមិនប្រឈមនឹងហានិភ័យខ្ពស់ ដែលអាចបង្កើនភាពងាយរងគ្រោះរបស់ប្រទេសទៅនឹងការប៉ះទង្គិចពីខាងក្រៅ ។

វិស័យមីក្រូហិរញ្ញវត្ថុ នឹងនៅតែជាសមាសភាពសំខាន់មួយក្នុងរបៀបវារៈកំណែទម្រង់របស់ធនាគារជាតិនៃកម្ពុជានាពេលអនាគត ។ វិស័យនេះ ត្រូវបានចាត់ទុកជាឧបករណ៍អភិវឌ្ឍន៍ដ៏មានប្រសិទ្ធភាពមួយចំពោះការកាត់បន្ថយភាពក្រីក្រ ដោយសារហេតុផលយ៉ាងសាមញ្ញមួយគឺ សេវាកម្មហិរញ្ញវត្ថុធ្វើឲ្យប្រជាជនក្រីក្រ និងគ្រួសារដែលមានចំណូលទាបអាចទាញយកផលប្រយោជន៍ពីឱកាសសេដ្ឋកិច្ច ដើម្បីបង្កើតទ្រព្យនិងកាត់បន្ថយភាពងាយរងគ្រោះទៅនឹងការប៉ះទង្គិចខាងក្រៅ ដែលអាចមានឥទ្ធិពលដល់ជីវភាពរស់នៅរបស់

ពួកគេ ។

ជាប្រត្យក្ស កិច្ចការឆ្ពោះទៅមុខមិនងាយស្រួលទេ ព្រមទាំងទាមទារនូវពេលវេលា និងភាពអត់ធ្មត់ ទោះបីជាយើងមានការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការអនុវត្តវិធានការគោលនយោបាយក៏ដោយ ពីព្រោះថា សកម្មភាពកំណែទម្រង់ជាច្រើនទាក់ទិននឹងបញ្ហាទស្សនទាន ព្រមទាំងយន្តការថ្មីៗចំពោះប្រទេសកម្ពុជា ដែលទាមទារឲ្យមានការយកចិត្តទុកដាក់ និងការគ្រប់គ្រងជាពិសេស ។ ហេតុដូចនេះ ធនាគារជាតិនៃកម្ពុជាមានសេចក្តីសង្ឃឹមក្នុងការពង្រឹងទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធទាំងអស់ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីទប់ទល់នឹងបញ្ហាប្រឈមចំពោះការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ដែលនឹងជួយកម្ពុជាឲ្យអាចមានវិស័យធនាគារនិងហិរញ្ញវត្ថុទំនើប ដែលមានលទ្ធភាពទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ច ក៏ដូចជារួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រដែលជាគោលបំណងចុងក្រោយរបស់រាជរដ្ឋាភិបាលកម្ពុជា ។

# ខ- ទិសដៅការងារ ឆ្នាំ២០១១

## ទិសដៅការងារ ឆ្នាំ២០១១

សភាពធ្ងន់ធ្ងរនៃវិបត្តិសេដ្ឋកិច្ចពិភពលោកបានកន្លងផុតហើយ បន្ទាប់ពីអាជ្ញាធរនៃបណ្ដាប្រទេសនានាចាត់វិធានការទប់ស្កាត់ទាន់ពេលវេលា និងមានប្រសិទ្ធភាពរួចមក ។ ទស្សនវិស័យសេដ្ឋកិច្ចពិភពលោកមានភាពប្រសើរឡើងវិញ ទោះបីជាកំណើនសកម្មភាពសេដ្ឋកិច្ចនៅមានភាពផុយស្រួយនៅឡើយក្ដី ។ ជាទិសដៅអនាគត ដើម្បីជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព អាជ្ញាធរនៃប្រទេសជាច្រើន បាននឹងកំពុងបន្តធ្វើកំណែទម្រង់សាធារណៈ ពង្រឹងសុខភាពនិងភាពរឹងមាំនៃប្រព័ន្ធធនាគារ និងហិរញ្ញវត្ថុ ស្ដារនិកម្មភាពឡើងវិញ និងពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងតំបន់ ។

ដោយឡែក ចំពោះស្ថានភាពប្រទេសកម្ពុជា ការងើបឡើងវិញនៃសេដ្ឋកិច្ចសកល និងការខិតខំអនុវត្តកំណែទម្រង់គ្រប់ជ្រុងជ្រោយរបស់រាជរដ្ឋាភិបាលនឹងជួយឲ្យកម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចមួយខ្ពស់ និងមានចីរភាព ព្រមទាំងការកាត់បន្ថយភាពក្រីក្រ ដែលនឹងទ្រទ្រង់ដោយស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងលើកស្ទួយវិស័យសំខាន់ៗ ដូចជា កសិកម្ម អភិវឌ្ឍន៍ជនបទ ឧស្សាហកម្ម ហេដ្ឋារចនាសម្ព័ន្ធ ថាមពល និងទេសចរណ៍ ។ ជាបន្ថែមលើនេះ ផ្អែកលើគោលនយោបាយដ៏ត្រឹមត្រូវ និងការប្ដេជ្ញាខ្ពស់របស់រាជរដ្ឋាភិបាល ក្នុងការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ សេដ្ឋកិច្ចកម្ពុជាគ្រោងនឹងមានកំណើនក្នុងអត្រាប្រមាណ ៦% នៅឆ្នាំ២០១១ ហើយអត្រាអតិផរណាប្រចាំឆ្នាំនឹងរំពឹងថា ស្ថិតក្នុងរង្វង់ ៥% ខណៈដែលអត្រាប្ដូរប្រាក់នឹងបន្តមានស្ថិរភាពសមស្រប ។

ដើម្បីចូលរួមចំណែកសម្រេចទិសដៅសេដ្ឋកិច្ច និងគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជានឹងបន្តអនុវត្តគោលនយោបាយរូបិយវត្ថុប្រុងប្រយ័ត្នប្រកបដោយភាពទន់ភ្លន់ និងមានលក្ខណៈស៊ីសង្វាក់គ្នាជាមួយគោលនយោបាយសារពើពន្ធ ទៅតាមការវិវត្តជាក់ស្ដែងនៃសេដ្ឋកិច្ច ។ ទន្ទឹមគ្នានេះដែរ ធនាគារជាតិនៃកម្ពុជានឹងបន្តរួមចំណែករក្សាស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ តាមរយៈការពង្រឹងបទប្បញ្ញត្តិ ការងារត្រួតពិនិត្យ និងយន្តការដោះស្រាយវិបត្តិដែលអាចកើតមានឡើង ដើម្បីធានាបាននូវប្រព័ន្ធធនាគារ និងហិរញ្ញវត្ថុមួយប្រកបដោយសុខភាពល្អ និងភាពរឹងមាំ ។

ដោយឡែក ក្នុងការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិលើវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុវិញ ធនាគារជាតិនៃកម្ពុជានឹងបន្តសហការជាមួយដៃគូនិងស្ថាប័នអន្តរជាតិសំខាន់ៗមួយចំនួន ដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារពិភពលោក ធនាគារទូទាត់អន្តរជាតិ ធនាគារអភិវឌ្ឍន៍អាស៊ី អាស៊ាន អាស៊ាន+៣ មជ្ឈមណ្ឌលធនាគារកណ្ដាលអាស៊ីអាគ្នេយ៍ និងដៃគូជាទ្វេភាគីមួយចំនួនទៀត ។

ផ្អែកលើល័ក្ខខ័ណ្ឌសេដ្ឋកិច្ចជាក់ស្ដែងនៅឆ្នាំ២០១០ នេះ ធនាគារជាតិនៃកម្ពុជាបានពិនិត្យ និងកែសម្រួលនូវទិសដៅទាំងឡាយ ព្រមទាំងកំណត់ទិសដៅសម្រាប់ឆ្នាំ២០១១ លើផ្នែកសំខាន់ៗ ដូចខាងក្រោមៈ

**១.ការងាររូបិយវត្ថុ** (បម្រែបម្រួលជាភាគរយប្រចាំឆ្នាំ)

| | |
|---|---|
| - រូបិយវត្ថុទូទៅ (M2) | ២០,៤% |
| - រូបិយវត្ថុក្នុងចរាចរណ៍ | ១៩,៤% |
| - ប្រាក់បញ្ញើជារូបិយប័ណ្ណ | ២១,០% |
| - ទ្រព្យសកម្មក្នុងស្រុកសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា | -១០,៦% |
| - ឥណទានសុទ្ធចំពោះរាជរដ្ឋាភិបាលពីវិស័យឯកជន | -១៧,៦% |
| - ទុនបម្រុងផ្លូវការសុទ្ធ | ១០,០% ។ |

**២.ការងារប្តូរប្រាក់ និងគ្រប់គ្រងទុនបម្រុង**

- បន្តអនុវត្តនយោបាយអត្រាប្តូរប្រាក់អណ្តែតមានការគ្រប់គ្រង និងធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់តាមការចាំបាច់ ដើម្បីរក្សាស្ថិរភាពអត្រាប្តូរប្រាក់
- បន្តពង្រឹងការវិនិយោគដោយខ្លួនឯងតាម Portfolio Indexation ដើម្បីឈានទៅធ្វើ enhance indexation
- រៀបចំប្រមូលព័ត៌មានសម្រាប់ជាមូលដ្ឋានក្នុងការបែងចែកទ្រព្យសកម្មជាយុទ្ធសាស្ត្រ (Strategic Assets Allocation) ។

**៣. ការងារអភិវឌ្ឍប្រព័ន្ធទូទាត់ និងប្រព័ន្ធធនាគារស្នូល**

- អនុវត្តគម្រោងអភិវឌ្ឍប្រព័ន្ធទូទាត់និងផាត់ទាត់ដែលមានលក្ខណៈប្រមូលផ្តុំ
- បង្កើតក្រុមប្រឹក្សាជាតិទូទាត់សងប្រាក់ ដើម្បីសម្រួលដល់ការពិភាក្សាពាក់ព័ន្ធនឹងប្រព័ន្ធផាត់ទាត់ និងទូទាត់សងប្រាក់
- បន្តរៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធជាតិទូទាត់សងប្រាក់
- បន្តពង្រីកការបំពាក់ប្រព័ន្ធធនាគារស្នូលនៅគ្រប់សាខាទូទាំងប្រទេស ។

**៤. ការងារត្រួតពិនិត្យ**

- បន្តពង្រឹងការអនុវត្តច្បាប់ បទប្បញ្ញត្តិផ្សេងៗ ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើនផ្នែកសេវាធនាគារ
- បន្តពង្រឹងអនុវត្តលើការងារ COBRA ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់
- បន្តពង្រឹងការកសាងសមត្ថភាពមន្ត្រីត្រួតពិនិត្យ តាមរយៈការបង្កើតឲ្យមានវគ្គបណ្តុះបណ្តាលភ្នាក់ងារត្រួតពិនិត្យជាប្រព័ន្ធនិងទៀងទាត់ និងវគ្គបណ្តុះបណ្តាលរយៈកាលខ្លីនៅក្នុង និងក្រៅប្រទេស ។

**៥. ការងារគណនេយ្យ**

- អនុវត្តគម្រោងកំណែទម្រង់ការងារគណនេយ្យ ដើម្បីត្រួតពិនិត្យលើការចុះកិច្ចបញ្ជិកាក្នុងប្រព័ន្ធធនាគារស្នូល (CBS) ដើម្បីធានាកិច្ចចុះបញ្ជិការបានសមស្របតាមគោលការណ៍គណនេយ្យ និងអាចកំណត់កំហុសឆ្គងបានទាន់ពេលវេលា និងធ្វើការកែតម្រូវដើម្បីឲ្យកិច្ចដំណើរការមានការល្អប្រសើរ

- បង្កើតប្រភេទរបាយការណ៍វិភាគហិរញ្ញវត្ថុដែលសមស្របទៅតាមតម្រូវការ ដើម្បីរៀបចំផែនការប្រចាំឆ្នាំ
- បូកសរុប និងវិភាគរបាយការណ៍គណនេយ្យឱ្យបានឆាប់រហ័ស និងទាន់ពេលវេលា ។

## ៦. ការងារប្រតិបត្តិការ

- បន្តរៀបចំនូវតម្រូវការចាំបាច់មួយចំនួនដែលប្រព័ន្ធ CBS ផ្តល់ឲ្យមិនទាន់ពេញលេញ
- បន្តសហការចុះជួយបណ្តុះបណ្តាលដល់សាខាធនាគារជាតិនៃកម្ពុជាក្នុងការប្រើប្រាស់ប្រព័ន្ធ CBS
- សិក្សារៀបចំប្រព័ន្ធចុះបញ្ជីនិងគ្រប់គ្រងមូលប័ត្រចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា
- បន្តសហការរៀបចំបង្កើតសភាផាត់ទាត់នៅតាមបណ្តាសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត
- បន្តពង្រឹងការអនុវត្តប្រព័ន្ធផាត់ទាត់ក្នុងតំណាក់កាលអន្តរកាល (Interim Solution) ដោយសហការជាមួយនាយកដ្ឋានព័ត៌មានុសាស្ត្រ កែលម្អ Internet នៃប្រព័ន្ធផាត់ទាត់ ដើម្បីឲ្យដំណើរការបញ្ជូនទិន្នន័យផាត់ទាត់អនុវត្តកាន់តែល្អប្រសើរ និងឈានទៅអនុវត្តកម្មវិធីផាត់ទាត់តំណាក់កាលពេញលេញ (Full Solution) នាពេលខាងមុខ
- បន្តពង្រីកការបំពាក់ប្រព័ន្ធធនាគារស្នូលនៅគ្រប់សាខាទូទាំងប្រទេស ។

## ៧. ការងារបោះផ្សាយ និងឃ្លាំងបេឡា

- បន្តពង្រឹងការងារបម្រើអតិថិជនក្នុងការបើក-បង់ប្រាក់នៅបញ្ជរបេឡាឲ្យបានលឿន និងកាន់តែប្រសើរឡើង
- បន្តណែនាំអំពីការងារគ្រប់គ្រងសាច់ប្រាក់ ការថែរក្សាការពារឃ្លាំងប្រាក់ ដោយតាមដានជាប្រចាំនូវសមតុល្យសាច់ប្រាក់ និងតម្រូវការសាច់ប្រាក់របស់សាខាធនាគារជាតិនៃកម្ពុជា
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ច រាំងខ្ទប់ចរាចរណ៍ប្រាក់ក្លែងក្លាយ
- បង្កើនការប្រមូលក្រដាសប្រាក់ចាស់ៗដែលពិបាកធ្វើចរាចរណ៍ ដោយបញ្ចេញនូវក្រដាសប្រាក់ថ្មីជំនួសវិញតាមប្រភេទឲ្យបានសមស្របទៅនឹងតម្រូវការទីផ្សារ
- បន្តពង្រឹងការងារដឹកជញ្ជូនធនប័ត្រ ។

## ៨. ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច

- ចុះធ្វើសវនកម្មនៅនាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ នាយកដ្ឋានប្រតិបត្តិការ នាយកដ្ឋានបោះផ្សាយ និងឃ្លាំងបេឡា និងនៅសាខាធនាគារជាតិនៃកម្ពុជាចំនួន៥ ព្រមទាំងចុះតាមដានការអនុវត្តតាមអនុសាសន៍នៅតាមសាខាធនាគារជាតិនៃកម្ពុជា ដែលបានចុះធ្វើសវនកម្មក្នុងឆ្នាំ២០១០
- បន្តចុះពង្រឹងការងារ និងធ្វើអធិការកិច្ចនៅសាខាធនាគារជាតិនៃកម្ពុជា ។

## ៩. ការងារបណ្តុះបណ្តាល

- ចូលរួមសហការ និងរៀបចំកម្មវិធីបណ្តុះបណ្តាល សិក្ខាសាលា និងប្រជុំផ្សេងៗនៅធនាគារជាតិនៃកម្ពុជា និង
- ចាត់បញ្ជូនមន្ត្រីបុគ្គលិកទៅចូលរួមសិក្ខាសាលា វគ្គសិក្សានានានៅក្នុងនិងក្រៅប្រទេស ។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ ១

## តារាង ១ -  ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញ និងសេវា

(គ្រាគោល តុលា-ធ្នូ ២០០៦=១០០)

| សន្ទស្សន៍ថ្លៃទំនិញ | ២០០៩ | ២០១០ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| **មុខទំនិញគ្រប់មុខ** | **១៣៤,០៣** | **១៣៤,០៦** | **១៣៤,៣៧** | **១៣៥,២៦** | **១៣៤,៨៧** | **១៣៥,១៩** | **១៣៥,១៥** | **១៣៥,៨៤** | **១៣៧,០២** | **១៣៧,៩៩** | **១៣៩,៩៣** | **១៣៨,៤៦** | **១៣៨,២៥** |
| អាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង | ១៤៨,៧១ | ១៤៨,៣៨ | ១៤៨,៨៩ | ១៤៩,៦៧ | ១៤៩,២១ | ១៤៩,៦៦ | ១៤៩,៩៤ | ១៥១,៣៩ | ១៥៣,៦៥ | ១៥៥,៣១ | ១៥៨,៥០ | ១៥៦,២៥ | ១៥៤,១១ |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | ១២២,៤៨ | ១២២,២១ | ១២៣,២៤ | ១២២,៩៦ | ១២៣,១៥ | ១២២,៩០ | ១២២,៦៤ | ១២២,២២ | ១២៣,៣៦ | ១២២,៥២ | ១២៣,២៨ | ១២២,៥៥ | ១២១,៨៩ |
| សម្លៀកបំពាក់ និងស្បែកជើង | ១១១,៧៥ | ១១២,៨០ | ១១៣,៨៣ | ១១៤,០២ | ១១៣,៦៥ | ១១៣,៨៦ | ១៣៣,៧១ | ១១៣,៦០ | ១១៤,៣៣ | ១១៥,៣៨ | ១១៥,១៥ | ១១៤,៦៧ | ១១៤,៦១ |
| ផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | ១១៧,៦២ | ១១៨,៧៨ | ១១៩,១៣ | ១១៩,៨៣ | ១១៩,៤១ | ១១៩,៦៥ | ១១៩,២០ | ១១៨,៨៦ | ១១៨,៧៣ | ១១៧,៤៥ | ១១៨,៩២ | ១១៨,១៣ | ១២១,០៣ |
| គ្រឿងសង្ហារិម សម្ភារៈប្រើប្រាស់គ្រួសារនិងការថែទាំផ្ទះជាប្រចាំ | ១២០,០១ | ១២០,៨៣ | ១២១,៤៨ | ១២១,៥២ | ១២០,៦១ | ១២០,៦៤ | ១២០,៣៥ | ១២០,៨៥ | ១២១,៤២ | ១២១,៨៥ | ១២១,៨៦ | ១២១,៧៧ | ១២១,៧៦ |
| សុខាភិបាល | ១១៦,៣១ | ១១៥,០៥ | ១១៥,៨១ | ១១៥,៧៥ | ១១៦,២២ | ១១៥,៦១ | ១១៥,៧៨ | ១១៥,៩៩ | ១១៥,៥៥ | ១១៦,២៤ | ១១៦,៥៣ | ១១៦,៦៥ | ១១៧,០៩ |
| ការដឹកជញ្ជូន | ១១៦,៦៦ | ១១៦,១១ | ១១៦,០៧ | ១១៨,២៥ | ១១៨,០៩ | ១១៨,៤១ | ១១៨,៥៥ | ១១៨,៦៩ | ១១៨,៤០ | ១១៩,២០ | ១២០,១៣ | ១១៨,៨៤ | ១២០,៥៩ |
| គមនាគមន៍ | ៧២,៩៩ | ៧២,៨៨ | ៧២,១០ | ៧១,៣៩ | ៧១,៣៩ | ៧១,៩២ | ៧១,៤៦ | ៧១,៤៣ | ៧០,៤១ | ៧៤,៤៤ | ៧៤,៤៦ | ៧៣,៧៤ | ៧៣,៣៥ |
| ការកម្សាន្ត និងវប្បធម៌ | ១០៣,០៩ | ១០៣,៨៦ | ១០២,៩០ | ១០៤,៤០ | ១០៤,៧១ | ១០៤,៧៨ | ១០៣,៩១ | ១០៤,១០ | ១០៣,៥៧ | ១០៤,៣៧ | ១០៣,៩២ | ១០៣,០៦ | ១០៣,៥៧ |
| ការសិក្សា | ១៣៨,៧៦ | ១៣៩,៣៩ | ១៤០,១៦ | ១៣៩,៣៩ | ១៤០,១៦ | ១៤០,១៦ | ១៤០,១៦ | ១៤០,១៦ | ១៤០,១៦ | ១៤០,១៦ | ១៤០,១៦ | ១៤០,១៦ | ១៤០,១៦ |
| ភោជនីយដ្ឋាន | ១៧១,៩៧ | ១៧២,១៩ | ១៧០,៥៤ | ១៧២,៤៨ | ១៧០,៥៤ | ១៧១,១១ | ១៦៩,៤៨ | ១៧០,៦០ | ១៧៤,០៩ | ១៧៧,៤០ | ១៧៨,១៩ | ១៧៥,៨១ | ១៧៦,១២ |
| ទំនិញ និងសេវាកម្មផ្សេងៗ | ១២៦,៧៥ | ១២៧,៤៤ | ១២៩,៧០ | ១៣០,២១ | ១៣០,៣៤ | ១៣១,៦៩ | ១៣២,៧៧ | ១៣២,៨៦ | ១៣៣,២៩ | ១៣៤,៥០ | ១៣៨,៣៦ | ១៣៩,៥៥ | ១៣៩,៤០ |
| **បម្រែបម្រួលភាគរយខែលើខែ** | | | | | | | | | | | | | |
| **មុខទំនិញគ្រប់មុខ** | **-០,០៩** | **០,០២** | **០,២៣** | **០,៦៦** | **-០,២៩** | **០,២៤** | **-០,០៣** | **០,៥១** | **០,៨៧** | **០,៧១** | **១,៤០** | **-១,០៥** | **-០,១៦** |
| អាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង | -១,០០ | -០,២២ | ០,៣៤ | ០,៥២ | -០,៣០ | ០,៣០ | ០,១៩ | ០,៩៦ | ១,៤៩ | ១,០៨ | ២,០៦ | -១,៤២ | -១,៣៧ |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | -០,៥១ | -០,២២ | ០,៨៥ | -០,២៣ | ០,១៦ | -០,២១ | -០,២១ | -០,៣៤ | ០,៩៤ | -០,៦៨ | ០,៦២ | -០,៥៩ | -០,៥៥ |
| សម្លៀកបំពាក់ និងស្បែកជើង | -០,២៥ | ០,៩៤ | ០,៩១ | ០,១៦ | -០,៣២ | ០,១៨ | -០,១៤ | -០,១០ | ០,៦៥ | ០,៩១ | -០,២០ | -០,៤២ | -០,០៥ |
| ផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | ២,២៥ | ០,៩៩ | ០,២៩ | ០,៥៩ | -០,៣៥ | ០,២០ | -០,៣៨ | -០,២៨ | -០,១១ | -១,០៨ | ១,២៥ | -០,៦៦ | ២,៤៥ |
| គ្រឿងសង្ហារិម សម្ភារៈប្រើប្រាស់គ្រួសារនិងការថែទាំផ្ទះជាប្រចាំ | ០,៣៩ | ០,៦៨ | ០,៥៤ | ០,០៣ | -០,៧៥ | ០,០៣ | -០,២៤ | ០,៤១ | ០,៤៧ | ០,៣៦ | ០,០១ | -០,០៧ | -០,០១ |
| សុខាភិបាល | -០,០៣ | -១,០៨ | ០,៦៦ | -០,០៥ | ០,៤១ | -០,៥៣ | ០,១៥ | ០,១៨ | -០,៣៨ | ០,៦០ | ០,២៥ | ០,១០ | ០,៣៨ |
| ការដឹកជញ្ជូន | ០,៣១ | -០,៤៧ | -០,០៤ | ១,៨៨ | -០,១៣ | ០,២៧ | ០,១១ | ០,១១ | -០,២៤ | ០,៦៧ | ០,៧៨ | -១,០៨ | ១,៤៨ |
| គមនាគមន៍ | -០,៨១ | -០,១៥ | -១,០៧ | -០,៩៩ | ០,០០ | ០,៧៥ | -០,៦៥ | -០,០៤ | -១,៤៣ | ៥,៧២ | ០,០៣ | -០,៩៧ | -០,៥៣ |
| ការកម្សាន្ត និងវប្បធម៌ | -១,៨៨ | ០,៧៥ | -០,៩៣ | ១,៤៦ | ០,២៩ | ០,០៧ | -០,៨៣ | ០,១៨ | -០៥១ | ០,៧៧ | -០,៤៣ | -០,៨២ | ០,៤៩ |
| ការសិក្សា | ០,០០ | ០,៤៥ | ០,៥៦ | -០,៥៥ | ០,៥៦ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,០០ |
| ភោជនីយដ្ឋាន | ១,១១ | ០,១២ | -០,៩៦ | ១,១៤ | -១,១៣ | ០,៣៤ | -០,៩៥ | ០,៦៦ | ២,០៤ | ១,៩០ | ០,៤៤ | -១,៣៣ | ០,១៨ |
| ទំនិញ និងសេវាកម្មផ្សេងៗ | ០,៩៥ | ០,៥៤ | ១,៧៨ | ០,៣៩ | ០,១១ | ១,០៣ | ០,៨២ | ០,០៧ | ០,៣២ | ០,៩១ | ២,៨៧ | ០,៨៦ | -០,១១ |
| **បម្រែបម្រួលភាគរយឆ្នាំលើឆ្នាំ** | | | | | | | | | | | | | |
| **មុខទំនិញគ្រប់មុខ** | **៥,៣២** | **៦,៩២** | **៧,៣១** | **៦,៦៥** | **៥,៣០** | **៤,៤៦** | **២,៥៨** | **១,៦២** | **១,៧៥** | **១,៩៣** | **៣,៦៩** | **៣,២១** | **៣,១៤** |
| អាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង | ៥,៤២ | ៧,៨៤ | ៨,៥៩ | ៧,០៤ | ៥,១៣ | ៣,៨៦ | ១,៧៥ | ១,៤០ | ២,០៣ | ២,២៦ | ៤,៥៩ | ៤,០៣ | ៣,៦៣ |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | ១០,៣៤ | ៧,៤៥ | ៥,៩៣ | ៣,៧៨ | ៣,៦៤ | ៣,០៨ | ២,៥៧ | ១,១៦ | ១,៧០ | -០,២៦ | ០,២៦ | -០,៤៥ | -០,៤៨ |
| សម្លៀកបំពាក់ និងស្បែកជើង | ២,៦០ | ៣,០៤ | ៤,៤០ | ៣,៤៣ | ១,៨៧ | ២,៤៥ | ២,៦០ | -០,៤០ | -០,៣០ | ០,១៣ | ០,៥២ | ២,៣៥ | ២,៥៦ |
| ផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | ១,៩៨ | ៤,៧៦ | ៤,៣៧ | ៤,៦២ | ៥,៣២ | ៥,៣១ | ៤,១០ | ៣,៣២ | ២,៩៤ | ២,០៥ | ៣,៦០ | ២,៧០ | ២,៩០ |
| គ្រឿងសង្ហារិម សម្ភារៈប្រើប្រាស់គ្រួសារនិងការថែទាំផ្ទះជាប្រចាំ | ៤,៨១ | ៤,៨៦ | ៥,៥៥ | ៤,៩៤ | ៣,០៩ | ១,៦៣ | ០,៥១ | ០,៦៥ | -០,០៧ | -០,៦៥ | ០,៦៤ | ១,៨៦ | ១,៤៦ |
| សុខាភិបាល | ៥,៨០ | ៤,៨៦ | ៣,៨៨ | ៤,១១ | ៣,៨៣ | ២,៦១ | ០,៤០ | -២,៦៧ | -២,២៧ | -១,៧២ | -០,១៧ | ០,២៦ | ០,៦៧ |
| ការដឹកជញ្ជូន | ១១,៩៤ | ១៤,០៧ | ១២,១១ | ១២,៤៨ | ១០,៧០ | ៩,៣១ | ៦,២០ | ៤,៧៨ | ២,១៣ | ២,៧២ | ៣,៨៥ | ២,១៨ | ៣,៣៧ |
| គមនាគមន៍ | -៦,៩៥ | -៤,៤៧ | -៦,៦២ | -៦,០៥ | -៣,០៩ | -២,១១ | -៥,៣៨ | -៤,១៣ | -៤,៦៧ | ០,៣៥ | ០,៧៤ | ០,២១ | ០,៤៩ |
| ការកម្សាន្ត និងវប្បធម៌ | -១,៥៤ | -០,១៧ | -០,៤៣ | ០,៩៤ | ១,៧៧ | ២,២២ | ០,៤៣ | ១,៦៨ | -០,១៤ | ០,៥៦ | -០,៤៣ | -១,៩១ | ០,៤៦ |
| ការសិក្សា | ៨,៩២ | ៥,៩១ | ១០,០៩ | ៥,៣៨ | ២,៦៧ | ២,៦៧ | ២,៦៤ | ១,០១ | ១,០១ | ១,០១ | ១,០១ | ១,០១ | ១,០១ |
| ភោជនីយដ្ឋាន | ៣,៨៤ | ១,៨៦ | ៤,៧១ | ៦,២២ | ៣,០៨ | ២,៩៩ | ១,១១ | -២,១៩ | -០,០៩ | ១,០៥ | ២,៤៩ | ៣,៣៦ | ២,៤១ |
| ទំនិញ និងសេវាកម្មផ្សេងៗ | ១១,៣២ | ១០,៥៣ | ១១,៧៥ | ១០,៧៤ | ១០,៥៨ | ១០,៧១ | ១០,៦៩ | ៨,៩៣ | ៩,៥៨ | ៩,៩២ | ១១,២៥ | ១១,១៤ | ៩,៩៨ |
| **ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញមធ្យមរំកិល ៣ខែ** | | | | | | | | | | | | | |
| **មុខទំនិញគ្រប់មុខ** | **១៣៤,៣៨** | **១៣៤,០៨** | **១៣៤,១៥** | **១៣៤,៥៦** | **១៣៤,៨៣** | **១៣៥,១០** | **១៣៥,០៧** | **១៣៥,៣៩** | **១៣៦,០០** | **១៣៦,៩៥** | **១៣៨,៣១** | **១៣៨,៧៩** | **១៣៨,៨៨** |
| បម្រែបម្រួលជាភាគរយឆ្នាំលើឆ្នាំ | ១,៥៩ | ៤,៤៥ | ៦,៥១ | ៦,៩៦ | ៦,៤១ | ៥,៤៦ | ៤,១០ | ២,៨៧ | ១,៩៨ | ១,៧៧ | ២,៤៦ | ២,៩៤ | ៣,៣៥ |
| **ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញមធ្យមរំកិល ១២ខែ** | | | | | | | | | | | | | |
| **មុខទំនិញគ្រប់មុខ** | **១៣១,១២** | **១៣១,៨៥** | **១៣២,៦១** | **១៣៣,៣១** | **១៣៣,៨៨** | **១៣៤,៣៦** | **១៣៤,៦៤** | **១៣៤,៨២** | **១៣៥,០២** | **១៣៥,២៤** | **១៣៥,៦៥** | **១៣៦,០១** | **១៣៦,៣៦** |
| បម្រែបម្រួលជាភាគរយឆ្នាំលើឆ្នាំ | -០,៦៦ | -០,៧០ | -០,៥៨ | ០,០០ | ០,៧៦ | ១,៦២ | ២,២៧ | ២,៧៦ | ៣,១៧ | ៣,៥៥ | ៤,០១ | ៤,១៨ | ៤,០០ |

ឧបសម្ព័ន្ធ ២

## តារាង ២ - ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញ និងសេវា (ធ្នូ-២០០៦-ធ្នូ-២០១០)

(គ្រាគោល តុលា-ធ្នូ ២០០៦=១០០)

| សន្ទស្សន៍ថ្លៃទំនិញ | ធ្នូ-០៦ | ធ្នូ-០៧ | ធ្នូ-០៨ | ធ្នូ-០៩ | ធ្នូ-១០ |
|---|---|---|---|---|---|
| **មុខទំនិញគ្រប់មុខ** | **៩៩,២៥** | **១១៣,១០** | **១២៧,២៦** | **១៣៤,០៣** | **១៣៨,២៥** |
| អាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង | ៩៩,០៣ | ១១៨,៤៧ | ១៤១,០៦ | ១៤៨,៧១ | ១៥៤,១១ |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | ៩៩,២៨ | ១០២,២០ | ១១១,០០ | ១២២,៤៨ | ១២១,៨៩ |
| សម្លៀកបំពាក់ និងស្បែកជើង | ៩៨,៤៤ | ១០១,៩៩ | ១០៨,៩២ | ១១១,៧៥ | ១១៤,៦១ |
| ផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | ៩៩,៩៣ | ១១២,៦៦ | ១១៥,៣៤ | ១១៧,៦២ | ១២១,០៣ |
| គ្រឿងសង្ហារិម សម្ភារៈប្រើប្រាស់គ្រួសារនិងការថែទាំផ្ទះជាប្រចាំ | ១០០,៣៩ | ១០៦,៦៤ | ១១៤,៥០ | ១២០,០១ | ១២១,៧៦ |
| សុខាភិបាល | ១០០,០៣ | ១០៥,៥២ | ១០៩,៩៤ | ១១៦,៣១ | ១១៧,០៩ |
| ការដឹកជញ្ជូន | ៩៨,៨០ | ១១២,៥១ | ១០៤,២១ | ១១៦,៦៦ | ១២០,៥៩ |
| គមនាគមន៍ | ៩៦,៨៩ | ៨៥,២៤ | ៧៨,៤៥ | ៧២,៩៩ | ៧៣,៣៥ |
| ការកម្សាន្ត និងវប្បធម៌ | ៩៩,៧០ | ៩៨,៦៥ | ១០៤,៧១ | ១០៣,០៩ | ១០៣,៥៧ |
| ការសិក្សា | ៩៩,៣៣ | ១០៦,០០ | ១២៧,៤០ | ១៣៨,៧៦ | ១៤០,១៦ |
| ភោជនីយដ្ឋាន | ៩៩,១៣ | ១០៨,១៩ | ១៦៥,៦២ | ១៧១,៩៧ | ១៧៦,១២ |
| ទំនិញ និងសេវាកម្មផ្សេងៗ | ៩៩,៥៩ | ១១០,០៦ | ១១៣,៨៦ | ១២៦,៧៥ | ១៣៩,៤០ |
| **បម្រែបម្រួលភាគរយខែលើខែ** | | | | | |
| **មុខទំនិញគ្រប់មុខ** | **-០,៧៩** | **១,០៦** | **-៣,៩៣** | **-០,០៩** | **-០,១៦** |
| អាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង | -១,០០ | ០,៣២ | -៤,៥៦ | -១,០០ | -១,៣៧ |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | -១,០០ | ០,៣១ | ០,៩៤ | -០,៥១ | -០,៥៥ |
| សម្លៀកបំពាក់ និងស្បែកជើង | -១,៨១ | ០,៤៤ | -០,៧១ | -០,២៥ | -០,០៥ |
| ផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | -០,១៥ | ៣,៧៨ | -៤,៧៦ | ២,២៥ | ២,៤៥ |
| គ្រឿងសង្ហារិម សម្ភារៈប្រើប្រាស់គ្រួសារនិងការថែទាំផ្ទះជាប្រចាំ | ០,៣២ | ០,៤០ | -០,៧៦ | ០,៣៩ | -០,០១ |
| សុខាភិបាល | ០,៤២ | ០,០៦ | -០,៤៨ | -០,០៣ | ០,៣៨ |
| ការដឹកជញ្ជូន | -១,០០ | ២,៦៥ | -៨,៤៦ | ០,៣១ | ១,៤៨ |
| គមនាគមន៍ | -៣,៦៤ | -០,៧៩ | -១,២៧ | -០,៨១ | -០,៥៣ |
| ការកម្សាន្ត និងវប្បធម៌ | -០,៧០ | -០,២៦ | -០,២៤ | -១,៨៨ | ០,៤៩ |
| ការសិក្សា | -០,២៨ | ០,០០ | ០,០០ | ០,០០ | ០,០០ |
| ភោជនីយដ្ឋាន | -១,៤១ | ០,០៩ | ០,៥៣ | ១,១១ | ០,១៨ |
| ទំនិញ និងសេវាកម្មផ្សេងៗ | -០,០៩ | -២,៣១ | ០,០៩ | ០,៩៥ | -០,១១ |
| **បម្រែបម្រួលភាគរយឆ្នាំលើឆ្នាំ** | | | | | |
| **មុខទំនិញគ្រប់មុខ** | **៤,២០** | **១៣,៩៥** | **១២,៥២** | **៥,៣២** | **៣,១៤** |
| អាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង | ៥,២១ | ១៩,៦២ | ១៩,០៨ | ៥,៤២ | ៣,៦៣ |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | ០,២៤ | ២,៩៤ | ៨,៦០ | ១០,៣៤ | -០,៤៨ |
| សម្លៀកបំពាក់ និងស្បែកជើង | ១,២០ | ៣,៦០ | ៦,៨០ | ២,៦០ | ២,៥៦ |
| ផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | ៧,៨២ | ១២,៧៤ | ២,៣៨ | ១,៩៨ | ២,៩០ |
| គ្រឿងសង្ហារិម សម្ភារៈប្រើប្រាស់គ្រួសារនិងការថែទាំផ្ទះជាប្រចាំ | ៧,១៦ | ៦,២៣ | ៧,៣៧ | ៤,៨១ | ១,៤៦ |
| សុខាភិបាល | ១,៦៣ | ៥,៤៨ | ៤,១៩ | ៥,៨០ | ០,៦៧ |
| ការដឹកជញ្ជូន | ៣,៣៨ | ១៣,៨៨ | -៧,៣៨ | ១១,៩៤ | ៣,៣៧ |
| គមនាគមន៍ | -៥,៥៣ | -១២,០៣ | -៧,៩៧ | -៦,៩៥ | ០,៤៩ |
| ការកម្សាន្ត និងវប្បធម៌ | ០,៤៣ | -១,០៦ | ៦,១៥ | -១,៥៤ | ០,៤៦ |
| ការសិក្សា | -១,៧០ | ៦,៧២ | ២០,១៩ | ៨,៩២ | ១,០១ |
| ភោជនីយដ្ឋាន | -១,១៩ | ៩,១៤ | ៥៣,០៩ | ៣,៨៤ | ២,៤១ |
| ទំនិញ និងសេវាកម្មផ្សេងៗ | -០,១៨ | ១០,៥១ | ៣,៤៥ | ១១,៣២ | ៩,៩៨ |
| **ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញមធ្យមរំកិល ៣ខែ** | | | | | |
| **មុខទំនិញគ្រប់មុខ** | **១០០,០** | **១១២,៣៣** | **១៣២,២៧** | **១៣៤,៣៨** | **១៣៨,៨៨** |
| បម្រែបម្រួលជាភាគរយឆ្នាំលើឆ្នាំ | ៤,៧១ | ១២,៣៣ | ១៧,៧៦ | ១,៥៩ | ៣,៣៥ |
| **ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញមធ្យមរំកិល ១២ខែ** | | | | | |
| **មុខទំនិញគ្រប់មុខ** | **៩៨,០៨** | **១០៥,៦០** | **១៣២,០០** | **១៣១,១២** | **១៣៦,៣៦** |
| បម្រែបម្រួលជាភាគរយឆ្នាំលើឆ្នាំ | ៦,១៤ | ៧,៦៧ | ២៥,០០ | -០,៦៦ | ៤,០០ |

# តារាង ៣ - ប្រាក់រៀលធៀបជាមួយរូបិយប័ណ្ណផ្សេងៗ (អត្រាទិញចុងខែ)

| រូបិយប័ណ្ណ | ២០០៩ | ២០១០ | | | | | | | | | | | | បម្រែបម្រួល % |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ធ្នូ-១០ /ធ្នូ-០៩ |
| **មូលនិធិរូបិយវត្ថុអន្តរជាតិ** | | | | | | | | | | | | | | |
| អេស ដេ អែរ | ៦.៥១២ | ៦.៤៩២ | ៦.៤០៤ | ៦.៣៦១ | ៦.៣៤១ | ៦.២២០ | ៦.២៥៣ | ៦.៤៥៤ | ៦.៤០៥ | ៦.៥៦៨ | ៦.៦២៥ | ៦.២៤៧ | ៦.២៤២ | -៤,១ |
| **អាស៊ី** | | | | | | | | | | | | | | |
| ដុល្លារ-អូស្ត្រាលី | ៣.៧៣៦ | ៣.៧១៤ | ៣.៧០៩ | ៣.៨៤៨ | ៣.៩០៧ | ៣.៥៦៣ | ៣.៥៨៤ | ៣.៨១១ | ៣.៧៧៤ | ៤.០៩៧ | ៤.១១១ | ៣.៩១៩ | ៤.១១៤ | ១០,១ |
| ដុល្លារ-ហុងកុង | ៥៣៧ | ៥៣៦ | ៥៣៩ | ៥៣៩ | ៥៤១ | ៥៤១ | ៥៤២ | ៥៤៥ | ៥៤៤ | ៥៤៥ | ៥៤៤ | ៥២៥ | ៥២១ | -៣,០ |
| យ៉េន-ជប៉ុន | ៤៥,០៤ | ៤៦,៤១ | ៤៦,៨៥ | ៤៥,០១ | ៤៤,៧០ | ៤៦,២២ | ៤៧,៦៣ | ៤៨,៨២ | ៥០,០៨ | ៥០,៤៧ | ៥១,៧១ | ៤៨,៣៩ | ៤៩,៧០ | ១០,៣ |
| វ៉ុន-កូរ៉េ | ៣,៥៧ | ៣,៦០ | ៣,៥៩ | ៣,៦៩ | ៣,៧៧ | ៣,៥៣ | ៣,៤០ | ៣,៥៧ | ៣,៥៣ | ៣,៧០ | ៣,៧៤ | ៣,៥៣ | ៣,៥៩ | ០,៦ |
| ដុល្លារ-ញូ៉ស៊ីឡែន | ៣.០១៩ | ២.៩៣១ | ២.៨៨៨ | ២.៩៧៤ | ៣.០៤២ | ២.៨៥៤ | ២.៩២០ | ៣.០៦១ | ២.៩៧៣ | ៣.១១២ | ៣.១៥៨ | ៣.០៣៥ | ៣.១២៣ | ៣,៤ |
| យ៉ន់ចិន | ៦១០ | ៦១០ | ៦១៣ | ៦១៣ | ៦១៥ | ៦១៧ | ៦២១ | ៦២៥ | ៦២៣ | ៦៣២ | ៦៣២ | ៦១២ | ៦១៣ | ០,៥ |
| ដុល្លារ-តៃវ៉ាន់ | ១២៩ | ១៣០ | ១៣០ | ១៣២ | ១៣៤ | ១៣២ | ១៣១ | ១៣២ | ១៣២ | ១៣៥ | ១៣៧ | ១៣៤ | ១៣៩ | ៧,៨ |
| **អាស៊ាន** | | | | | | | | | | | | | | |
| រ៉ូពី-ឥណ្ឌូណេស៊ី | ០,៤៤ | ០,៤៥ | ០,៤៥ | ០,៤៦ | ០,៤៧ | ០,៤៦ | ០,៤៦ | ០,៤៧ | ០,៤៧ | ០,៤៧ | ០,៤៧ | ០,៤៥ | ០,៤៥ | ២,០ |
| រីងហ្គីត-ម៉ាឡេស៊ី | ១.២១៦ | ១.២១៧ | ១.២២៨ | ១.២៧៩ | ១.៣១៣ | ១.២៨០ | ១.២៩២ | ១.៣២៦ | ១.៣៤៥ | ១.៣៧០ | ១.៣៥៧ | ១.២៨៩ | ១.៣១៨ | ៨,៤ |
| ប៉េសូ-ហ្វីលីពីន | ៩០,១៣ | ៨៩,៤២ | ៩០,៣៨ | ៩២,៣៣ | ៩៤,០៦ | ៩១,៣២ | ៩១,០៥ | ៩២,៧០ | ៩៣,៦៧ | ៩៥,៩៧ | ៩៧,៧៥ | ៩២,៣៦ | ៩២,៤៨ | ២,៦ |
| ដុល្លារ-សាំងហ្គាពួរ | ២.៩៦៦ | ២.៩៦៤ | ២.៩៦៨ | ២.៩៨៨ | ៣.០៦៩ | ២.៩៩៦ | ៣.០០៧ | ៣.១០៦ | ៣.១២២ | ៣.២១០ | ៣.២៤១ | ៣.០៨៨ | ៣.១៤៣ | ៦,០ |
| បាត-ថៃ | ១២៥ | ១២៦ | ១២៦ | ១២៩ | ១៣០ | ១២៩ | ១៣០ | ១៣១ | ១៣៥ | ១៣៩ | ១៤១ | ១៣៥ | ១៣៤ | ៧,២ |
| ដុង-វៀតណាម | ០,២២៥ | ០,២២៥ | ០,២២២ | ០,២១៩ | ០,២២១ | ០,២២២ | ០,២២១ | ០,២២២ | ០,២១៧ | ០,២១៧ | ០,២១៧ | ០,២០៩ | ០,២០៨ | -៧,៦ |
| **អឺរ៉ុប** | | | | | | | | | | | | | | |
| អឺរ៉ូ | ៥.៩៧៨ | ៥.៨១៥ | ៥.៦៦១ | ៥.៦១៣ | ៥.៥៦៩ | ៥.១៧៨ | ៥.១៤២ | ៥.៥៣៣ | ៥.៣៥០ | ៥.៧៦១ | ៥.៨២០ | ៥.៣៤១ | ៥.៣៨៧ | -៩,៩ |
| **ផ្សេង** | | | | | | | | | | | | | | |
| ផោន-អង់គ្លេស | ៦.៦៩៤ | ៦.៧២០ | ៦.៣៧៣ | ៦.៣០៦ | ៦.៤៥០ | ៦.០៩៥ | ៦.៣៥៣ | ៦.៦១១ | ៦.៥៤៦ | ៦.៦៨២ | ៦.៦៦១ | ៦.៣៤០ | ៦.២៥២ | -៦,៦ |

## ឧបសម្ព័ន្ធ ៤

# តារាង ៤ - ស្ថានភាពរូបិយវត្ថុ

(គិតជាពាន់លានរៀល)

| | ធ្នូ-០៦ | ធ្នូ-០៧ | ធ្នូ-០៨ | ធ្នូ-០៩ | ធ្នូ-១០ |
|---|---|---|---|---|---|
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **៧.២២៤** | **១០.៧៣៥** | **១០.៣៤៦** | **១៤.៦៥៥** | **១៦.៦៩៨** |
| ទ្រព្យសកម្មបរទេស | ៧.៦៥០ | ១១.៨៩០ | ១២.៨៨៦ | ១៦.៥១៤ | ១៨.៩១៨ |
| ទ្រព្យអកម្មបរទេស | -៤២៦ | -១.១៥៦ | -២.៥៤០ | -១.៨៥៨ | -២.២២០ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **-២៨២** | **៥៧៦** | **១.៥១៣** | **១.៥៧៣** | **២.៧៧៩** |
| **ឥណទានក្នុងស្រុក** | **២.៦៧៦** | **៤.៥៧០** | **៦.៩០៧** | **៨.២៨០** | **១១.២០៦** |
| **ឥណទេយ្យសុទ្ធចំពោះរដ្ឋាភិបាល** | **-៩៥៣** | **-១.៨១៦** | **-២.៩៨៧** | **-២.២៥២** | **-២.១២៧** |
| ឥណទេយ្យចំពោះរដ្ឋាភិបាល | ២៨៧ | ២៩៧ | ២៧០ | ២៧០ | ២៧០ |
| ប្រាក់បញ្ញើរដ្ឋាភិបាល | -១.២៤០ | -២.១១៣ | -៣.២៥៧ | -២.៥២២ | -២.៣៩៧ |
| **ឥណទានផ្នែកមិនមែនរដ្ឋាភិបាល** | **៣.៦៣០** | **៦.៣៨៦** | **៩.៨៩៤** | **១០.៥៣២** | **១៣.៣៣៣** |
| សហគ្រាសរដ្ឋ | ២ | ១ | ១ | ០ | ២ |
| ផ្នែកឯកជន | ៣.៦២៨ | ៦.៣៨៥ | ៩.៨៩៣ | ១០.៥៣២ | ១៣.៣៣១ |
| ក្នុងនោះ - ជារូបិយប័ណ្ណបរទេស | ៣.៤៧៦ | ៦.១៦១ | ៩.៦០៣ | ១០.២១៤ | ១២.៨៨៦ |
| **ខ្ទង់ផ្សេងៗសុទ្ធ** | **-២.៩៥៩** | **-៣.៩៩៤** | **-៥.៣៩៤** | **-៦.៧០៧** | **-៨.៤២៨** |
| ប្រាក់បញ្ញើហាមឃាត់ | -១៥៥ | -២៥៥ | -២៨៨ | -៣៤១ | -៤៧៦ |
| មូលធននិងទុនបម្រុង | -៣.២៤១ | -៤.៣១២ | -៥.៧៧៦ | -៧.២៥៨ | -៨.៦៧៤ |
| ផ្សេងៗ | ៤៣៨ | ៥៧២ | ៦៧០ | ៨៩២ | ៧២២ |
| **រូបិយវត្ថុទូទៅ** (M2) | **៦.៩៤២** | **១១.៣១១** | **១១.៨៥៩** | **១៦.២២៨** | **១៩.៤៧៧** |
| **រូបិយវត្ថុ** (M1) | **១.៦៥៨** | **២.០៥២** | **២.៤០០** | **៣.១២០** | **៣.២២១** |
| រូបិយវត្ថុក្រៅធនាគារ | ១.៦០០ | ១.៩៩០ | ២.២៩៥ | ៣.០០២ | ៣.០៩៩ |
| ប្រាក់បញ្ញើចរន្ត | ៥៨ | ៦២ | ១០៥ | ១១៩ | ១២២ |
| **រូបិយវត្ថុផ្សេងៗ** | **៥.២៨៥** | **៩.២៥៩** | **៩.៤៥៩** | **១៣.១០៨** | **១៦.២៥៦** |
| ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ | ៨៩ | ១២១ | ១៨៥ | ៣៥៩ | ៤០៨ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ | ៥.១៩៦ | ៩.១៣៨ | ៩.២៧៤ | ១២.៧៤៩ | ១៥.៨៤៨ |
| **អនុស្សរណៈ** | | | | | |
| **ទ្រព្យសកម្មបរទេសសុទ្ធ** (លានដុល្លារ) | **១.៧៧៩** | **២.៦៨២** | **២.៥៣៥** | **៣.៥១៥** | **៤.១២០** |
| ធនាគារជាតិនៃកម្ពុជា | ១.៤១១ | ២.១៤៣ | ២.៦៤១ | ៣.១៨១ | ៣.៦៩៧ |
| ធនាគារទទួលប្រាក់បញ្ញើ | ៣៦៨ | ៥៣៨ | -១០៦ | ៣៣៤ | ៤២៣ |
| **រង្វិលជុំនៃរូបិយវត្ថុ** | **៤,៩** | **៣,៩** | **៣,៤** | **៦,៥** | **១៣,៥** |

**ឧបសម្ព័ន្ធ ៥**

# តារាង ៥ - ស្ថានភាពរូបិយវត្ថុ

(បម្រែបម្រួលប្រចាំឆ្នាំជាភាគរយ)

| | ធ្នូ-០៦ | ធ្នូ-០៧ | ធ្នូ-០៨ | ធ្នូ-០៩ | ធ្នូ-១០ |
|---|---|---|---|---|---|
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **៣១,៩** | **៤៨,៦** | **-៣,៦** | **៤១,៧** | **១៣,៩** |
| ទ្រព្យសកម្មបរទេស | ២៤,៥ | ៥៥,៤ | ៨,៤ | ២៨,២ | ១៤,៦ |
| ទ្រព្យអកម្មបរទេស | -៣៦,២ | ១៧១,៥ | ១១៩,៨ | -២៦,៨ | ១៩,៤ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **៣៧,៤** | **៣០៤,២** | **១៦២,៧** | **៤,០** | **៧៦,៦** |
| **ឥណទានក្នុងស្រុក** | **៣៥,៧** | **៧០,៧** | **៥១,១** | **១៩,៩** | **៣៥,៣** |
| **ឥណទេយ្យសុទ្ធចំពោះរដ្ឋាភិបាល** | **-១២៦,៤** | **-៩០,៥** | **-៦៤,៥** | **២៤,៦** | **៥,៦** |
| ឥណទេយ្យចំពោះរដ្ឋាភិបាល | -១២,២ | ៣,៦ | -៨,៩ | ០,០ | ០,០ |
| ប្រាក់បញ្ញើរដ្ឋាភិបាល | ៦៥,៨ | ៧០,៤ | ៥៤,២ | -២២,៦ | -៥,០ |
| **ឥណទានផ្នែកមិនមែនរដ្ឋាភិបាល** | **៥១,៦** | **៧៥,៩** | **៥៤,៩** | **៦,៤** | **២៦,៦** |
| សហគ្រាសរដ្ឋ | ០,០ | -៤៣,៥ | -៤៩,៨ | -១០០,០ | ១០០,០ |
| ផ្នែកឯកជន | ៥១,៦ | ៧៦,០ | ៥៥,០ | ៦,៥ | ២៦,៦ |
| ក្នុងនោះ - ជារូបិយប័ណ្ណបរទេស | ៥២,៨ | ៧៧,៣ | ៥៥,៩ | ៦,៤ | ២៦,២ |
| **ខ្ទង់ផ្សេងៗសុទ្ធ** | **-២២,១** | **-៣៥,០** | **-៣៥,០** | **-២៤,៣** | **-២៥,៧** |
| ប្រាក់បញ្ញើហាមឃាត់ | ២៦,១ | ៦៤,២ | ១៣,១ | ១៨,៥ | ៣៩,៦ |
| មូលធននិងទុនបម្រុង | ២២,៨ | ៣៣,០ | ៣៤,០ | ២៥,៧ | ១៩,៥ |
| ផ្សេងៗ | ២៨,៥ | ៣០,៨ | ១៧,១ | ៣៣,២ | -១៩,១ |
| **រូបិយវត្ថុទូទៅ** (M2) | **៣៨,២** | **៦២,៩** | **៤,៨** | **៣៦,៨** | **២០,០** |
| **រូបិយវត្ថុ** (M1) | **២៥,៣** | **២៣,៨** | **១៦,៩** | **៣០,០** | **៣,២** |
| រូបិយវត្ថុក្រៅធនាគារ | ២៤,៨ | ២៤,៤ | ១៥,៣ | ៣០,៨ | ៣,២ |
| ប្រាក់បញ្ញើចរន្ត | ៤៣,០ | ៧,១ | ៦៨,៣ | ១៣,២ | ៣,១ |
| **រូបិយវត្ថុផ្សេងៗ** | **៤២,៧** | **៧៥,២** | **២,២** | **៣៨,៦** | **២៤,០** |
| ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ | -២១,៤ | ៣៦,៦ | ៥២,៧ | ៩៤,១ | ១៣,៨ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ | ៤៤,៨ | ៧៥,៩ | ១,៥ | ៣៧,៥ | ២៤,៣ |
| **អនុស្សរណៈ** | | | | | |
| **ទ្រព្យសកម្មបរទេស** (**ជាលានដុល្លារ**) | **៣៣,៧** | **៥០,៧** | **-៥,៥** | **៣៨,៧** | **១៧,២** |
| ធនាគារជាតិនៃកម្ពុជា | ៣១,០ | ៥១,៩ | ២៣,២ | ២០,៥ | ១៦,២ |
| ធនាគារទទួលប្រាក់បញ្ញើ | ៤៥,៦ | ៤៦,២ | -១១៩,៦ | -៤១៦,៧ | ២៦,៧ |
| **រង្វិលជុំនៃរូបិយវត្ថុ** | **-៩,៩** | **-២០,៦** | **-១១,៦** | **៨៩,៩** | **១០៧,៨** |

# តារាង ៦ - តារាងគណនីវិភាគធនាគារជាតិនៃកម្ពុជា

| | ធ្នូ-០៦ | ធ្នូ-០៧ | ធ្នូ-០៨ | ធ្នូ-០៩ | ធ្នូ-១០ |
|---|---|---|---|---|---|
| | | | គិតជាពាន់លានរៀល | | |
| **រូបិយវត្ថុបម្រុង** | **៣.៣៨៣** | **៥.០១៨** | **៦.១០០** | **៨.៧៤១** | **១០.២៤៥** |
| **រូបិយវត្ថុក្រៅធនាគារ** | **១.៦០០** | **១.៩៩០** | **២.២៩៥** | **៣.០០២** | **៣.០៩៩** |
| **បេឡាធនាគារពាណិជ្ជ** | **៣០** | **៤៧** | **៩០** | **៨៦** | **១៤០** |
| **ប្រាក់បញ្ញើធនាគារ** | **១.៧៣៦** | **២.៩៦៨** | **៣.៦៨៨** | **៥.៦២១** | **៦.៩៧៨** |
| ប្រាក់បម្រុងកាតព្វកិច្ច | ៤២៨ | ៧៧៨ | ១.៦៣២ | ១.៦៧៧ | ២.១៣៤ |
| ប្រាក់បញ្ញើផ្សេងៗ | ១.៣០៨ | ២.១៩១ | ២.០៥៥ | ៣.៩៤៥ | ៤.៨៤៤ |
| **ផ្សេងៗ** | **១៧** | **១៣** | **២៨** | **៣២** | **២៨** |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **៥.៧២៩** | **៨.៥៧៩** | **១០.៧៧៦** | **១៣.២៦២** | **១៤.៩៨២** |
| ទ្រព្យសកម្មបរទេស | ៥.៧២៩ | ៨.៥៧៩ | ១០.៧៧៦ | ១៣.៧១០ | ១៥.៤១០ |
| ទ្រព្យអកម្មបរទេស | ០ | ០ | ០ | ៤៤៨ | ៤២៨ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **-២.៣៤៦** | **-៣.៥៦១** | **-៤.៦៧៦** | **-៤.៥២០** | **-៤.៧៣៨** |
| **ឥណទេយ្យសុទ្ធចំពោះរដ្ឋាភិបាល** | **-៨០៧** | **-១.៦៣២** | **-២.៦៩៦** | **-១.៩៧៦** | **-១.៧៨៥** |
| ឥណទេយ្យចំពោះរដ្ឋាភិបាល | ២៨៦ | ២៩៧ | ២៧០ | ២៧០ | ២៧០ |
| ប្រាក់បញ្ញើរដ្ឋាភិបាល | -១.០៩៣ | -១.៩២៩ | -២.៩៦៦ | -២.២៤៦ | -២.០៥៥ |
| **ឥណទានសុទ្ធចំពោះធនាគារពាណិជ្ជ** | **-៩២** | **-១៥១** | **-១៩៤** | **-២៩៦** | **-៤៣៩** |
| **ឥណទានចំពោះផ្នែកឯកជន** | **២** | **២** | **២** | **២** | **០** |
| **ខ្ទង់ផ្សេងៗសុទ្ធ** | **-១.៤៤៩** | **-១.៧៧៩** | **-១.៧៨៨** | **-២.២៥០** | **-២.៥១៤** |
| | | | បម្រែបម្រួលប្រចាំឆ្នាំជាភាគរយ | | |
| **រូបិយវត្ថុបម្រុង** | **២៨,៣** | **៤៨,៣** | **២១,៦** | **៤៣,៣** | **១៧,២** |
| **រូបិយវត្ថុក្រៅធនាគារ** | **២៤,៨** | **២៤,៤** | **១៥,៣** | **៣០,៨** | **៣,២** |
| **បេឡាធនាគារពាណិជ្ជ** | **១០,៦** | **៥៨,៨** | **៩០,៨** | **-៤,០** | **៦២,៦** |
| **ប្រាក់បញ្ញើធនាគារ** | **៣១,៣** | **៧១,០** | **២៤,២** | **៥២,៤** | **២៤,១** |
| ប្រាក់បម្រុងកាតព្វកិច្ច | ៤១,៦ | ៨១,៧ | ១០៩,៨ | ២,៨ | ២៧,៣ |
| ប្រាក់បញ្ញើផ្សេងៗ | ២៨,៣ | ៦៧,៥ | -៦,២ | ៩១,៩ | ២២,៨ |
| **ផ្សេងៗ** | **១៨៣,០** | **-២៥,៨** | **១១៨,៦** | **១៥,១** | **-១៤,១** |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **២៩,២** | **៤៩,៨** | **២៥,៦** | **២៣,១** | **១៣,០** |
| ទ្រព្យសកម្មបរទេស | ២០,២ | ៤៩,៨ | ២៥,៦ | ២៧,២ | ១២,៤ |
| ទ្រព្យអកម្មបរទេស | -១០០,០ | ០ | ០ | ១០០,០ | -៤,៥ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **-៣០,៦** | **-៥១,៨** | **-៣១,៣** | **៣,៣** | **-៤,៨** |
| **ឥណទេយ្យសុទ្ធចំពោះរដ្ឋាភិបាល** | **-៩៨,៤** | **-១០២,២** | **-៦៥,២** | **២៦,៧** | **៩,៧** |
| ឥណទេយ្យចំពោះរដ្ឋាភិបាល | ៥,៩ | ៣,៦ | -៨,៩ | -០,១ | ០,០ |
| ប្រាក់បញ្ញើរដ្ឋាភិបាល | ៦១,៥ | ៧៦,៤ | ៥៣,៨ | -២៤,៣ | -៨,៥ |
| **ឥណទានសុទ្ធចំពោះធនាគារពាណិជ្ជ** | **-៩,១** | **៦៤,៦** | **២៨,១** | **៥២,៨** | **៤៨,១** |
| **ឥណទានចំពោះផ្នែកឯកជន** | **-១១,៩** | **-៣,៥** | **-២,២** | **-៤,២** | **-១០០,០** |
| **ខ្ទង់ផ្សេងៗសុទ្ធ** | **-១២,៥** | **-២២,៨** | **-០,៥** | **-២៥,៩** | **-១១,៧** |

## តារាង ៧ - តារាងគណនីវិភាគធនាគារពាណិជ្ជ

| | ធ្នូ-០៦ | ធ្នូ-០៧ | ធ្នូ-០៨ | ធ្នូ-០៩ | ធ្នូ-១០ |
|---|---|---|---|---|---|
| | | | គិតជាពាន់លានរៀល | | |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **១.៤៩៦** | **២.១៥៦** | **-៤៣១** | **១.៣៩៣** | **១.៧១៥** |
| ទ្រព្យសកម្មបរទេស | ១.៩២១ | ៣.៣១១ | ២.១១០ | ២.៨០៤ | ៣.៥០៨ |
| ទ្រព្យអកម្មបរទេស | -៤២៦ | -១.១៥៦ | -២.៥៤០ | -១.៤១១ | -១.៧៩២ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **១.៩៦២** | **៤.០២០** | **៥.៩៦២** | **៥.៧៣៣** | **៧.១៨៥** |
| **ឥណទានក្នុងស្រុកសុទ្ធ** | **៣.៤៩០** | **៦.១៦០** | **៩.៥៦១** | **១០.២៥៤** | **១២.៩៩១** |
| ឥណទេយ្យសុទ្ធចំពោះរដ្ឋាភិបាល | -១៤៦ | -១៨៤ | -២៩២ | -២៧៦ | -៣៤២ |
| ឥណទានចំពោះសហគ្រាសរដ្ឋ | ២ | ១ | ១ | ០ | ២ |
| ឥណទានចំពោះផ្នែកឯកជន | ៣.៦២៦ | ៦.៣៨៣ | ៩.៨៩២ | ១០.៥៣០ | ១៣.៣៣១ |
| ឥណទេយ្យសុទ្ធចំពោះធនាគារជាតិនៃកម្ពុជា | ៨ | -៤០ | -៤០ | ០ | ២ |
| **ខ្ទង់ផ្សេងៗសុទ្ធ** | **-១.៥២៧** | **-២.១៤០** | **-៣.៥៩៨** | **-៤.៥២១** | **-៥.៨០៦** |
| **ទុនបម្រុង** | **១.៨៦៨** | **៣.១៣២** | **៤.០០៥** | **៦.០៦៨** | **៧.៤៥០** |
| សាច់ប្រាក់នៅធនាគារពាណិជ្ជ | ៣០ | ៤៧ | ៩០ | ៨៦ | ១៤០ |
| ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា | ១.៨៣៨ | ៣.០៨៥ | ៣.៩១៥ | ៥.៩៨២ | ៧.៣០៩ |
| **ប្រាក់បញ្ញើ** (**ទ្រព្យអកម្មក្នុងស្រុកសុទ្ធ**) | **៥.៣២៥** | **៩.០៣៨** | **៩.៥៣៧** | **១៣.១៩៤** | **១៦.៣៥០** |
| ប្រាក់បញ្ញើចរន្ត | ៤១ | ៤៩ | ៧៧ | ៨៦ | ៩៥ |
| ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ | ៨៩ | ១២១ | ១៨៥ | ៣៥៩ | ៤០៨ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ | ៥.១៩៦ | ៩.១៣៨ | ៩.២៧៥ | ១២.៧៤៩ | ១៥.៨៤៨ |
| **ទ្រព្យសកម្មសរុប = ទ្រព្យអកម្មសរុប** | **៧.៩៦៣** | **១៣.៥៤៣** | **១៧.៣០៨** | **២១.៣៤៤** | **២៦.៣៧២** |
| | | | បម្រែបម្រួលប្រចាំឆ្នាំជាភាគរយ | | |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **៤៣,៦** | **៤៤,១** | **-១២០,០** | **-៤២៣,៦** | **២៣,១** |
| ទ្រព្យសកម្មបរទេស | ៣៩,៨ | ៧២,៣ | -៣៦,៣ | ៣២,៩ | ២៥,១ |
| ទ្រព្យអកម្មបរទេស | ២៧,៨ | ១៧១,៥ | ១១៩,៨ | -៤៤,៥ | ២៧,០ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **៥៣,៩** | **១០៤,៩** | **៤៨,៣** | **-៣,៨** | **២៥,៣** |
| **ឥណទានក្នុងស្រុកសុទ្ធ** | **៤៦,៣** | **៧៦,៥** | **៥៥,២** | **៧,៣** | **២៦,៧** |
| ឥណទេយ្យសុទ្ធចំពោះរដ្ឋាភិបាល | -៩១៥,០ | -២៥,៦ | -៥៨,៥ | ៥,៣ | -២៣,៩ |
| ឥណទានចំពោះសហគ្រាសរដ្ឋ | ១០០,០ | -៤៣,៦ | -៤៩,០ | -១០០,០ | ១០០,០ |
| ឥណទានចំពោះផ្នែកឯកជន | ៥១,៦ | ៧៦,០ | ៥៥,០ | ៦,៥ | ២៦,៦ |
| ឥណទេយ្យសុទ្ធចំពោះធនាគារជាតិនៃកម្ពុជា | -១,៣ | -៥៧៩,៧ | ០,០ | -១០០,០ | ០,០ |
| **ខ្ទង់ផ្សេងៗសុទ្ធ** | **-៣៧,៦** | **-៤០,១** | **-៦៨,២** | **-២៥,៦** | **-២៨,៤** |
| **ទុនបម្រុង** | **៣១,៥** | **៦៧,៧** | **២៧,៩** | **៥១,៥** | **២២,៨** |
| សាច់ប្រាក់នៅធនាគារពាណិជ្ជ | ១០,៦ | ៥៨,៨ | ៩០,៨ | -៤,០ | ៦២,៦ |
| ប្រាក់បញ្ញើនៅធនាគារជាតិនៃម្ពុជា | ៣១,៩ | ៦៧,៩ | ២៦,៩ | ៥២,៨ | ២២,២ |
| **ប្រាក់បញ្ញើ** (**ទ្រព្យអកម្មក្នុងស្រុកសុទ្ធ**) | **៤២,៥** | **៧៤,៨** | **២,៥** | **៣៨,៤** | **២៣,៩** |
| ប្រាក់បញ្ញើចរន្ត | ១៨,៦ | ២១,០ | ៥៦,១ | ១១,៨ | ៩,៥ |
| ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ | -២១,៤ | ៣៦,៦ | ៥២,៧ | ៩៤,១ | ១៣,៨ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ | ៤៤,៨ | ៧៥,៩ | ១,៥ | ៣៧,៥ | ២៤,៣ |
| **ទ្រព្យសកម្មសរុប = ទ្រព្យអកម្មសរុប** | **៤២,៧** | **៧០,១** | **២៧,៨** | **២៣,៣** | **២៣,៦** |

## តារាង ៨ - ឥណទានតាមប្រភេទជំនួញក្នុងវិស័យសេដ្ឋកិច្ច

(ឯកតា: ពាន់លានរៀល)

| | ធ្នូ-០៨ | ធ្នូ-០៩ | តុលា-១០ | វិច្ឆិកា-១០ | ធ្នូ-១០ |
|---|---|---|---|---|---|
| **១- គ្រឹះស្ថានហិរញ្ញវត្ថុ** | **១៣៥** | **១៤៥** | **១៥៩** | **១៤៣** | **១៧៧** |
| ធនាគារជាតិនៃកម្ពុជា | ០ | ០ | ០ | ០ | ០ |
| គ្រឹះស្ថានហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | ៩ | ១០ | ១៧ | ១៦ | ១៨ |
| គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗទៀត | ១២៦ | ១៣៥ | ១៤២ | ១២៧ | ១៦០ |
| **២- គ្រឹះស្ថានមិនបម្រើសេវាហិរញ្ញវត្ថុ** | **៨.៣០០** | **៩.២០៨** | **១១.១៧៧** | **១១.១៦៦** | **១១.៦៩៥** |
| កសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ | ៥១៦ | ៧០៩ | ៨២៦ | ៨១៦ | ៨៨៤ |
| ឧស្សាហកម្មរ៉ែ | ៧ | ១១ | ៥៦ | ៥៤ | ៥៥ |
| កម្មន្តសាលកម្ម | ៩៨៤ | ៩២០ | ១.១២៣ | ១.១៤៣ | ១.១៥០ |
| ការផ្គត់ផ្គង់សេវាសាធារណៈ | ៧៧ | ៥៦ | ៧៦ | ៧១ | ៧៣ |
| សំណង់ | ៧៧៤ | ៩០៤ | ៩៤៤ | ៩៣៩ | ៩៣១ |
| ការជួញដូរដុំ | ១.៦១៨ | ១.៣៥៣ | ២.០៤៥ | ២.០៧៤ | ២.៣១៦ |
| ការជួញដូររាយ | ១.២៤៥ | ១.៩២២ | ២.២៣២ | ២.១៨៤ | ២.៣៦៩ |
| សណ្ឋាគារនិងភោជនីយដ្ឋាន | ១.២៧៧ | ១.២៦២ | ១.៣៦៤ | ១.៣១៨ | ១.២៨៨ |
| ដឹកជញ្ជូននិងស្តុកបណ្តោះអាសន្ន | ១៣៧ | ១៧៦ | ២២៦ | ២៤១ | ២៥២ |
| បណ្តាញព័ត៌មាននិងទូរគមនាគមន៍ | ២៤៤ | ៣០៨ | ៣២៤ | ៣១៤ | ៣៥៦ |
| អាជីវកម្មជួលនិងភតិសន្យាប្រតិបត្តិការ មិនរាប់បញ្ចូលភតិសន្យានិងការជួលអចលនទ្រព្យ | ២៤ | ៤៦ | ៥២ | ១០២ | ៩៩ |
| ការជួញដូរអចលនទ្រព្យ | ៧៣៧ | ៦៦៣ | ៧០១ | ៦៥៨ | ៦១៣ |
| សេវាកម្មមិនមែនហិរញ្ញវត្ថុផ្សេងៗទៀត | ៦៥៩ | ៨៧៩ | ១.២០៧ | ១.២៥២ | ១.៣០៩ |
| **៣- គម្រោងការផ្ទាល់ខ្លួន** | **១.៣១៦** | **១.១៤២** | **១.២៤៩** | **១.១៩០** | **១.១៨៣** |
| ការឲ្យខ្ចីជាបុគ្គល | ៥៨៤ | ៧៤៨ | ៧៧០ | ៧០៨ | ៦៨៤ |
| ការឲ្យខ្ចីតាមប័ណ្ណឥណទាន | ១៦ | ១៧ | ២៤ | ២៦ | ២៤ |
| ការឲ្យខ្ចីទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន | ៧១៦ | ៣៧៨ | ៤៥៥ | ៤៥៥ | ៤៧៦ |
| **៤- ឥណទានផ្សេងៗ** | **៨១** | **៤៦** | **១១៨** | **១១៤** | **១៦៥** |
| **សរុបឥណទានដុល** | **៩.៨៣៣** | **១០.៥៤១** | **១២.៧០៤** | **១២.៦១៤** | **១៣.២២១** |

## តារាង ៨ - សរុបប្រតិបត្តិការប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ

(ឯកតា: ពាន់លានរៀល)

| | ធ្នូ-០៨ | ធ្នូ-០៩ | តុលា-១០ | វិច្ឆិកា-១០ | ធ្នូ-១០ |
|---|---|---|---|---|---|
| **ប្រាក់បញ្ញើជារៀល** | | | | | |
| ប្រាក់បញ្ញើជារៀល | ៤១ | ១០២ | ១៣៦ | ១៨១ | ១៤១ |
| ប្រាក់បញ្ញើសន្សំ | ៦៣ | ២៣៣ | ១៨១ | ១៨៨ | ១៩៨ |
| ប្រាក់បញ្ញើមានកាលកំណត់ | ៤២ | ១៣៩ | ២១៩ | ២០៨ | ២០១ |
| ប្រាក់បញ្ញើផ្សេងៗ | ២ | ១ | ១ | ១ | ១ |
| **សរុប** | **១៤៨** | **៤៧៦** | **៥៣៦** | **៥៧៨** | **៥៤១** |
| **ប្រាក់បញ្ញើជារូបិយប័ណ្ណ** | | | | | |
| ប្រាក់បញ្ញើជារៀល | ៩៥៩ | ២.៧១៤ | ៣.៤៧៦ | ៣.៥៣៩ | ៣.២១៩ |
| ប្រាក់បញ្ញើសន្សំ | ១.៧០៣ | ៤.២៥៦ | ៥.៦៦២ | ៥.៦៣៦ | ៦.០៧៤ |
| ប្រាក់បញ្ញើមានកាលកំណត់ | ១.០៧២ | ៦.៣០៨ | ៧.៧២៨ | ៧.៣៦១ | ៧.៥៦៥ |
| ប្រាក់បញ្ញើផ្សេងៗ | ៤៦ | ៨៩ | ៧៩ | ៦៩ | ៨០ |
| **សរុប** | **៣.៧៨០** | **១៣.៣៦៦** | **១៦.៩៤៥** | **១៦.៦០៥** | **១៦.៩៣៨** |
| **សរុបរួម** | **៣.៩២៧** | **១៣.៨៤២** | **១៧.៤៨២** | **១៧.១៨៣** | **១៧.៤៧៩** |

# **ជញ្ជីងទូទាត់ប្រទេសកម្ពុជា**

ឆ្នាំ២០០៧ ដល់ ២០១០

(គិតជាលានដុល្លារអាមេរិក)

| | ២០០៧ | ២០០៨ | ២០០៩ | ២០១០[ព] |
|---|---|---|---|---|
| **ជញ្ជីងពាណិជ្ជកម្ម** | **-១.៣៤៣,៤** | **-១.៨០០,៤** | **-១.៦៣៤,២** | **-១.៦៩៧,៥** |
| នាំចេញ (FOB) | ៤.០៨៨,៥ | ៤.៧០៨,០ | ៤.១៩៦,២ | ៤.៦៨៦,៦ |
| នាំចេញផលិតផលក្នុងស្រុក | ៣.៨៧៣,៩ | ៤.៤២៣,៧ | ៣.៨៧៩,៤ | ៤.៣៦៣,៤ |
| នាំចេញតាមប្រព័ន្ធ GSP ( ភាគច្រើនសម្លៀកបំពាក់ ) | ២.៩៤២,៣ | ៣.០០៦,៤ | ២.៥១៤,៨ | ២.៨៩៨,៣ |
| នាំចេញផលិតផលក្នុងស្រុកផ្សេងៗ | ៩៣១,៦ | ១.៤១៧.៣ | ១.៣៦៤,៦ | ១.៤៦៥,១ |
| នាំចេញបន្ត ( រាប់បញ្ចូលចំណេញ និងចំណាយដឹកជញ្ជូន ) | ២១៤,៦ | ២៨៤,៣ | ៣១៦,៨ | ៣២៣,២ |
| នាំចូល (FOB) | -៥.៤៣១,៩ | -៦,៥០៨,៤ | -៥.៨៣០,៥ | -៦.៣៨៤,២ |
| នាំចូលសម្រាប់ប្រើប្រាស់ក្នុងស្រុក | -៥.២៥០,៥ | -៦.២៧១,០ | -៥.៥៦៥,៤ | -៦.១០៩,៥ |
| សម្លៀកបំពាក់ | -១.៣៧៦,៦ | -១.៤០៤,១ | -១.១៩១,៨ | -១.៣៦៦,៨ |
| ប្រេងឥន្ធនៈ | -១.៣៤៧,៦ | -១.៩២៤,៣ | -១.៨០៥,៤ | -១.៩៦៨,០ |
| នាំចូលសម្រាប់ប្រើប្រាស់ក្នុងស្រុកផ្សេងៗ | -២.៥២៦,២ | -២.៩៤២,៦ | -២.៥៦៨,១ | -២.៧៧៤,៧ |
| នាំចូលសម្រាប់នាំចេញបន្ត | -១៨១,៤ | -២៣៧,៤ | -២៦៥,១ | -២៧៤,៧ |
| **សេវា (សុទ្ធ)** | **៦៣២,១** | **៦០៩,៤** | **៦០៦,៤** | **៦៣៣,០** |
| ចំណូល | ១.៥៤៧,៥ | ១.៦៤៥,១ | ១.៦២៤,៩ | ១.៦៥២,៦ |
| ក្នុងនោះ : សេវាធ្វើដំណើរ | ១.១៣៤,៨ | ១.២១៨,៨ | ១.១៨៤,៦ | ១.២៤៩,៨ |
| ចំណាយ | -៩១៥,៤ | -១.០៣៥,៨ | -១.០១៨,៤ | -១.០១៩,៥ |
| ក្នុងនោះ : សេវាធ្វើដំណើរ | -១២២,៧ | -៩៦,៨ | -១០៣,៥ | -១១២,៨ |
| **ប្រាក់ចំណូល (សុទ្ធ)** | **-៣៦៣,៩** | **-៤៧៤,៦** | **-៤៦៨,២** | **-៤៨១,២** |
| ចំណូល | ១១២,២ | ១០៨,៤ | ៥៥,៦ | ៥៨,៣ |
| ក្នុងនោះ : ការប្រាក់ | ៦៨,៩ | ៦២,៦ | ២៦,២ | ២៧,៥ |
| ចំណាយ | -៤៧៦,២ | -៥៨៣,០ | -៥២៣,៨ | -៥៣៩,៥ |
| ក្នុងនោះ : - ការបង់ការប្រាក់ | -៤២,៣ | -៤៦,៥ | -៤៨,៨ | -៥០,២ |
| - ចំណូលពីហ៊ុន | -៣៣៩,៤ | -៣៨៩,៩ | -៣៣៥,២ | -៣៤៥,៣ |
| **បង្វែរឯកជន (សុទ្ធ)** | **៣៨២,៥** | **២៨៤,៣** | **២៩៣,១** | **៣០៧,៨** |
| ចំណូល | ៤៧៥,៣ | ៣៧១,៨ | ៣៧០,៤ | ៣៨៨,៩ |
| ចំណាយ | ៩២,៧ | ៨៧,៤ | ៧៧,២ | ៨១,១ |
| **សមតុល្យគណនីចរន្ត** (មិនរាប់បញ្ចូលបង្វែរផ្លូវការ) | **-៦៩២,៧** | **-១.៣៨១,៣** | **-១.២០២,៩** | **-១.២៣៧,៩** |
| **បង្វែរផ្លូវការ (សុទ្ធ)** | **៤៧០,៣** | **៥៦៣,៣** | **៥៩២,៦** | **៧៩៩,៧** |
| ចំណូល | ៤៧០,៦ | ៥៦៣,៦ | ៥៩២,៩ | ៨០០,០ |
| ចំណាយ | -០,៣ | -០,៣ | -០,៣ | -០,៣ |
| **សមតុល្យគណនីចរន្ត និងបង្វែរផ្លូវការ** | **-២២២,៤** | **-៨១៨,០** | **-៦១០,៣** | **-៤៣៨,១** |
| **គណនីហិរញ្ញវត្ថុ** | **៦៨១,៥** | **១.៣៨៦,៣** | **៥៩៩,៣** | **៦៣៤,៦** |
| **ឥណទានផ្លូវការ** (មិនរាប់បញ្ចូល IMF) **សុទ្ធ*** | ១៩៩,៦ | ២៣៤,៧ | ១៥៣,១ | ១៨៨,០ |
| ដកប្រាក់ | ២០៨,៥ | ២៤៤,៩ | ១៦៤,១ | ២០០,០ |
| ទូទាត់ | -៨,៩ | -១០,២ | -១១,០ | -១២,០ |
| **វិនិយោគមិនផ្លូវការ** | **៤៨១,៩** | **១.១៥១,៧** | **៤៤៦,២** | **៤៤៦,៦** |
| វិនិយោគផ្ទាល់ (សុទ្ធ) * | ៨៦៦,២ | ៧៩៤,៧ | ៥១១,៣ | ៥៥៣,០ |
| វិនិយោគលើផលប័ត្រ (សុទ្ធ) * | -៦,៥ | -១១,៦ | -៧,៦ | -៧,៦ |
| វិនិយោគផ្សេងទៀត (សុទ្ធ) * | -៣៧៧,៩ | ៣៦៨,៦ | -៥៧,៥ | -៩៨,៨ |
| **កំហុស និងរំលង** | **-៣៦,៦** | **-៤៦,៣** | **៦,៣** | **-៥៣,៣** |
| **សមតុល្យរួម** | **៤២២,៥** | **៥២២,០** | **-៤,៧** | **១៤៣,២** |
| **ហិរញ្ញប្បទាន** | **-៤២២,៥** | **-៥២២,០** | **៤,៧** | **-១៤៣,២** |
| ទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិ * | -៤៣៥,២ | -៥៣៤,៨ | -៨,១ | -១៥៦,០ |
| បម្រែបម្រួលទ្រព្យសកម្មជាទុនបម្រុងបរទេស | -៤៣៥,២ | -៥៣៤,៨ | -១១៦,៦ | -១៥៦,០ |
| ការប្រើប្រាស់ឥណទានរបស់ IMF | -- | -- | -- | -- |
| ការបែងចែក SDR | -- | -- | ១០៨,៥ | -- |
| ហិរញ្ញប្បទានពិសេស | ១២,៨ | ១២,៨ | ១២,៨ | ១២,៨ |

** តម្លៃវិជ្ជមានតំណាងឲ្យកំណើនទ្រព្យអកម្មបរទេស ឬថយចុះទ្រព្យសកម្មបរទេស និងតម្លៃអវិជ្ជមានតំណាងឲ្យកំណើនទ្រព្យសកម្មបរទេស ឬការថយចុះទ្រព្យអកម្មបរទេស*

***ប្រភព :*** ទិន្នន័យទទួលបានពីអាជ្ញាធរកម្ពុជានិងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

***កំណត់សំគាល់ :*** - ទិន្នន័យបណ្តោះអាសន្នសម្រាប់ឆ្នាំ២០០៧-*២០០៩ ( ទិន្នន័យទាំងនេះអាចនឹងត្រូវបានកែប្រែឡើងវិញក្នុងពេលអនាគត)*

- ព = ព្យាករណ៍ទិន្នន័យសម្រាប់ឆ្នាំ*២០១០*